ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ

# COMMUNITY PARTICIPATION IN SCHOOL DEVELOPMENT AT THE HIGH SCHOOL LEVEL IN KAMPONG SPEU PROVINCE

ដោយ/by

សឹម ភក្តី/SOEM  PHEAKKDEY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ១០
ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ

# COMMUNITY PARTICIPATION IN SCHOOL DEVELOPMENT AT THE HIGH SCHOOL LEVEL IN KAMPONG SPEU PROVINCE

ដោយ/by
សឹម ភក្តី/SOEM PHEAKKDEY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ១០

ឯកទេស៖ គ្រប់គ្រងអប់រំ
ឆ្នាំសិក្សា ២០២១-២០២៣

គ្រូណែនាំគោល ៖ បណ្ឌិត គួយ សុគាន
គ្រូណែនាំរង ៖ បណ្ឌិត នី រដ្ឋា

# **សេចក្ដីអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា « **ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ** » សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬ សាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន ។

ថ្ងៃ **សុក្រ ១១ រោច** ខែ **កត្ដិក** ឆ្នាំ **ថោះ** បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ **ធ្នូ** ឆ្នាំ២០២៣

**ហត្ថលេខា**



**សឹម ភក្ដី**

# លិខិតបញ្ជាក់

**គ្រូណែនាំគោល ៖ បណ្ឌិត គួយ សុគាន**

**គ្រូណែនាំរង ៖ បណ្ឌិត នី រដ្ឋា**

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **សឹម ភក្តី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី « **ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ** » ពិតប្រាកដមែន។

ថ្ងៃ **សុក្រ ១១ រោច** ខែ កត្តិក **ឆ្នាំ ថោះ** បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០២៣



..........................................

**បណ្ឌិត គួយ សុគាន**

គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ



..........................................

**បណ្ឌិត នី រដ្ឋា**

ប្រធានការិយាល័យសិក្សានៅវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៧៤៧៧ **អយក.ខុទ្ទ**

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នួវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួលៈ**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ** ៧៥០១ **អយក.**[illegible]

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ុំម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ជឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ កត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្ដមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «**ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ**» ការសិក្សានេះមានគោលបំណង សិក្សាឈ្វេងយល់ពីការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនក្នុងខេត្តកំពង់ស្ពឺ និងកំណត់ពីបញ្ហាប្រឈមរបស់សាលារៀនក្នុងការទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍន៍សាលារៀន។

ចំពោះវិធីសាស្ត្រស្រាវជ្រាវដែលបានយកមកប្រើដើម្បីប្រមូលទិន្នន័យនេះ គឺជាវិធីសាស្ត្របែបបរិមាណវិស័យ។ នៅក្នុងការស្រាវជ្រាវនេះបានប្រើប្រាស់នូវកម្រងសំណួរដើម្បីទទួលបាននូវទិន្នន័យព័ត៌មានដែលជាចម្លើយពីគោលដៅសម្ភាសន៍ដែលជាចំនួនសំណាកទាំងបួនគឺ គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សិស្ស និងសហគមន៍។ ក្នុងការវិភាគទិន្នន័យដែលទទួលបានពីកម្រងសំណួរ ត្រូវបានប្រើប្រាស់កម្មវិធី Microsoft Excel និង Microsoft Word ដើម្បីពិពណ៌នាបកស្រាយមធ្យមភាគចំនួនសំណាកដែលបានចូលរួមក្នុងការបំពេញកម្រងសំណួរ នៅកម្រិតវិទ្យាល័យទាំងបីក្នុងខេត្តកំពង់ស្ពឺ ដែលមានចំនួនសំណាកសរុប ២៧៩ នាក់ ក្នុងនោះផងដែរមានគណៈគ្រប់គ្រងសាលារៀន ៩នាក់ គ្រូបង្រៀន ៦០ នាក់ សហគមន៍៦០ នាក់ និងសិស្សានុសិស្សថ្នាក់ទី១០ ដល់ថ្នាក់ទី១២ មានចំនួន ១៥០ នាក់។

ជាលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ មានស្ថានភាពល្អ តម្លៃមធ្យមភាគស្មើ ៣.៦៧។ ផ្នែកទៅលើការគ្រប់គ្រងដឹកនាំ និងការបង្កើតទំនាក់ទំនងជាមួយសហគមន៍និងភាគីពាក់ព័ន្ធដើម្បីអភិវឌ្ឍន៍សាលារៀន។ តាមលទ្ធផលស្រាវជ្រាវបានឆ្លុះបញ្ចាំងថាគណៈគ្រប់គ្រង និងភាគីពាក់ព័ន្ធនានាត្រូវពង្រឹងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ បន្ថែមការយល់ដឹងតាមរយៈការបណ្តុះបណ្តាលផ្សេងៗ បង្កើតសេចក្តីទុកចិត្តជាមួយភាគីពាក់ព័ន្ធ ដើម្បីពង្រឹងនិងពង្រីកការអភិវឌ្ឍសាលារៀន និងការអប់រំប្រកបដោយប្រសិទ្ធភាព ដែលជាកន្លែងថ្នាលសម្រាប់បណ្តុះបណ្តាលធនធានមនុស្សឱ្យមានសមត្ថភាពខ្ពស់ និងមកចូលរួមអភិវឌ្ឍន៍ប្រទេសជាតិឱ្យរុងរឿងនិងចម្រុងចម្រើន។

# Abstract

The research on **"Community Participation in School Development at the High School Level in Kampong Speu Province"** The purpose of this study was to understand community participation in school development in Kampong Speu province and to identify of school to conduct community in school school development.

The research method used to collect this data is a quantitative method. In this research, questionnaires were used to obtain information data that was the answer to the interview objectives of the four samples: school management, teachers, students and the community. In analyzing the data obtained from the questionnaire, Microsoft Excel and Microsoft Word were used to describe the average number of samples that participated in completing the questionnaire at the three high school levels in Kampong Speu province, with a total of 279 samples in There are 9 school administrators, 60 teachers, 60 community members and 150 students from 10th to 12th grade.

As a result of the research, the community participation in the development of schools at the high school level in Kampong Speu was good, with an average value of 3.67. Management, leadership and building relationships with the community and stakeholders to develop the school. According to the research results, the management and stakeholders need to strengthen the dissemination of awareness through various trainings, build trust with stakeholders to strengthen and expand the development of schools and education effectively. A nursery for training human resources to be highly capable and to participate in the development of a prosperous and prosperous nation.

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងអប់រំជំនាន់ទី១០ ក្នុងឆ្នាំសិក្សា ២០២១-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ សុំលំអោនលំទោនគោរព និងថ្លែងអំណរគុណចំពោះ៖

- ព្រះមហាក្សត្រ និងថ្នាក់ដឹកនាំរដ្ឋាភិបាលដែលខិតខំប្រឹងប្រែងតស៊ូ ការពារប្រទេសជាតិ និងរក្សាសុខសន្តិភាពជូនជាតិមាតុភូមិ និងប្រជានុរាស្ត្រទាំងអស់គ្នា។
- ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកនៃវិទ្យាស្ថានជាតិអប់រំ និងនាយករង/ នាយិការងនៃវិទ្យាស្ថានជាតិអប់រំទាំងមូល ដែលជាម្លប់ដ៏ត្រជាក់ និងកក់ក្ដៅសម្រាប់វិទ្យាស្ថាន និងជាអ្នកដឹកនាំមគ្គុទ្ទេសក៍បង្កើតរោងចក្រ សម្រាប់ផលិតធនធានមនុស្សក្នុងការអភិវឌ្ឍសង្គមជាតិ។
- ជាពិសេសពិសាលសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត គួយ សូគាន** និង **បណ្ឌិត នី រដ្ឋា** ដែលបានជួយជ្រោមជ្រែងដឹកនាំកែសម្រួល និងអនុសាសន៍យ៉ាងល្អៗក្នុងការធ្វើសារណាបទ ដល់រូបខ្ញុំបាទចាប់តាំងពីដើមរហូតដល់ចប់ ហើយថែមទាំងទទួលបានជោគជ័យជាស្ថាពរ។
- សូមអរគុណចំពោះគណៈគ្រប់គ្រងគ្រូឧទ្ទេស និងសិស្សានុសិស្សនៃវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺដែលបានយកចិត្តទុកដាក់ ចូលរួមនិងបកស្រាយរាល់កម្រងសំណួររបស់ខ្ញុំបាទដែលបានដាក់ចេញក្នុងការស្រាវជ្រាវនេះបានជាទីគាប់ចិត្ត។
- លោកឪពុក **សៀង ចាន់** និង អ្នកម្ដាយ **និន ឃីន** ដែលបានចិញ្ចឹមបីបាច់មើលថែរក្សាផ្ដល់ចំណីអាហារ សម្លៀលបំពាក់ បញ្ជូនកូនទៅសាលារៀន ទូន្មានប្រៀនប្រដៅដើម្បីឱ្យកូនបានចេះដឹង តាំងពីដើមរហូតមកដល់នាពេលបច្ចុប្បន្ន។

ជាទីចុងបញ្ចប់នេះដែរ ខ្ញុំបាទសូមគោរពជូនពរដល់អ្នកមានគុណទាំងទ្វេរ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា នាយក លោកគ្រូ អ្នកគ្រូទាំងអស់ សូមជួបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើន មានសុខភាពល្អបរិបូណ៌ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងឡាយ ៤ប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈគ្រប់ៗគ្នាកុំបីឃ្លៀងឃ្លាតឡើយ និងជានិច្ចនិរន្តន៍។

**សូមអរគុណ!**

# មាតិកា

សេចក្តីអះអាងរបស់បេក្ខជន ........ i
លិខិតបញ្ជាក់ ........ ii
លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iii
មូលន័យសង្ខេប ........ vii
លិខិតថ្លែងអំណរគុណ ........ ix
បញ្ជីរូបភាព/ តារាង ឬការលើកឧទាហរណ៍ ........ xvi
បញ្ជីនៃសញ្ញា និង អក្សរកាត់ ........ xviii

## ជំពូក ១

## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 2
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 3
១.៤ សំណួរស្រាវជ្រាវ ........ 3
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ 4
១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ 5
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 5

# ជំពូក ២

# ការរំលឹកទ្រឹស្តី


២.១ និយមន័យ ....................................................................................................9

២.១.១ ការចូលរួម ......................................................................................................9

២.១.២ សហគមន៍....................................................................................................10

២.១.៣ ការអភិវឌ្ឍសាលារៀន.................................................................................... 11

២.២ ធាតុសំខាន់ៗនៃការអភិវឌ្ឍសាលារៀន ...................................................................12

២.២.១. តួនាទីរបស់គណៈគ្រប់គ្រងសាលារៀន ..............................................................13

២.២.២ កត្តាសហគមន៍ ............................................................................................ 18

២.២.៣ កត្តាសាលារៀន.............................................................................................29

២.២.៤ កត្តាសិស្ស ....................................................................................................33

២.២.៥ កត្តាគ្រូ.........................................................................................................34

២.៣ ការអភិវឌ្ឍសាលារៀនដោយសហគមន៍....................................................................38

២.៣.១ សកម្មភាពនៃការដឹកនាំសហគមន៍ចូលរួមអភិវឌ្ឍសាលារៀន ...................................39

២.៣.២ ការគាំទ្រ និងផ្សព្វផ្សាយរបស់សហគមន៍ ...........................................................40

២.៣.៣ សហគមន៍ចូលរួមកៀងគរដៃគូអភិវឌ្ឍន៍សាលារៀន.............................................. 41

២.៤ គោលការណ៍នៃការគ្រប់គ្រងសាលារៀន ...................................................................43

២.៤.១ វិមជ្ឈការនិងការអប់រំ.......................................................................................46

២.៤.២ គោលបំណងនៃការគ្រប់គ្រងសាលារៀន.............................................................46

២.៥ សកម្មភាពពាក់ព័ន្ធនិងការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន ....................47

២.៦ សន្និដ្ឋាន ....................50

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

៣.១ គម្រោងវិភាគ ....................53

៣.២ ការប្រមូលទិន្នន័យ....................54

៣.៣ ឧបករណ៍ស្រាវជ្រាវ....................55

៣.៣.១ កម្រិតចង្អុលបង្ហាញ ....................55

៣.៣.២ កម្រងសំណួរ....................58

៣.៣.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន....................58

៣.៣.២.២ កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ (គ្រូបង្រៀន) ....................59

៣.៣.២.៣ កម្រងសំណួរសម្រាប់សហគមន៍ និងអ្នកពាក់ព័ន្ធ....................60

៣.៣.២.៤ កម្រងសំណួរសម្រាប់សិស្ស ....................60

៣.៤ ការជ្រើសរើសភាគសំណាក....................60

៣.៥ ការវិភាគទិន្នន័យ ....................64

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

៤.១ ការវិភាគលើកម្រងសំណួរគណៈគ្រប់គ្រងសាលា ....................66

៤.១.១ ផ្នែកទី១៖ ព័ត៌មានទូទៅ ....................66

៤.១.២ ផ្នែកទី២៖ ការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ ........................................................................................................................68
៤.១.៣ ផ្នែកទី៣៖ ការបង្កើតបណ្ដាញទំនាក់ទំនង និងគ្រប់គ្រងដឹកនាំសម្របសម្រួលជាមួយសហគមន៍.......................................................................................................71
៤.១.៤ ផ្នែកទី៤៖ ការបង្កើតដៃគូសហការប្រកបដោយការអភិវឌ្ឍជាមួយអ្នកពាក់ព័ន្ធ ...............77
៤.២ ការវិភាគលើកម្រងសំណួររបស់គ្រូបង្រៀន..............................................................79
៤.២.១ ផ្នែកទី១៖ ព័ត៌មានទូទៅ ........................................................................................79
៤.២.២ ផ្នែកទី២៖ ក្នុងដំណើរការនៃការរៀន និងបង្រៀន...................................................80
៤.២.៣ ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ ........................................87
៤.២.៤ ផ្នែកទី៤៖ បញ្ហាប្រឈម និងសំណូមពរ ......................................................................89
៤.៣ ការវិភាគលើកម្រងសំណួរសហគមន៍ ..........................................................................90
៤.៣.១ ផ្នែកទី១៖ ព័ត៌មានទូទៅរបស់សហគមន៍......................................................................90
៤.៣.២ ការចូលរួមរបស់សហគន៍ក្នុងការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ....91
៤.៤ ការវិភាគលើកម្រងសំណួររបស់សិស្ស ........................................................................93
៤.៤.១ ផ្នែកទី១៖ អំពីព័ត៌មាន............................................................................................93
៤.៤.២ ផ្នែកទី២៖ អំពីការសិក្សារបស់សិស្ស.........................................................................94
៤.៤.៣ ផ្នែកទី៣៖ ការបង្កើតទំនាក់ទំនង និងការសហការគ្នា..................................................97
៤.៤.៤ បញ្ហាប្រឈម និងសំណូមពរ......................................................................................98
៤.៥ ការពិភាក្សា ..............................................................................................................99

៤.៥.១ ការពិភាក្សាលើសំណួរស្រាវជ្រាវទី១ ........ 99
៤.៥.២ ការពិភាក្សាលើសំណួរស្រាវជ្រាវទី២ ........ 100
៤.៦ ចំណុចខ្លាំង និងចំណុចខ្សោយ ........ 103
៤.៦.១ ចំណុចខ្លាំង ........ 103
៤.៦.២ ចំណុចខ្សោយ ........ 104

## ជំពូក ៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១ សេចក្តីសន្និដ្ឋាន ........ 106
៥.២ សំណូមពរ ........ 107
៥.២.១ ចំពោះគណៈគ្រប់គ្រងសាលារៀន ........ 107
៥.២.២ ចំពោះគ្រូបង្រៀន ........ 107
៥.២.៣ ចំពោះសហគមន៍ ........ 108
៥.២.៤ សម្រាប់សិស្សានុសិស្ស ........ 108
៥.២.៥ សំណូមពរដល់អ្នកជំនាន់ក្រោយ ........ 109
ឯកសារយោង ........ 110
ឧបសម្ព័ន្ធទី១៖ លិខិតបង្គាប់ការរបស់គណៈកម្មការការពារនិក្ខេបទ ........ 113
ឧបសម្ព័ន្ធទី២៖ លិខិតចាត់តាំងគ្រូដឹកនាំគោល និងគ្រូដឹកនាំរង សម្រាប់សរសេរនិក្ខេបទ ........ 122
ឧបសម្ព័ន្ធទី៣៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ 126
ឧបសម្ព័ន្ធទី៤៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ ........ 128

ឧបសម្ព័ន្ធទី៥៖ កម្រងសំណួរ.......................................................................................130

# បញ្ជីរូបភាព/ តារាង ឬការលើកឧទាហរណ៍


ក្រាបទី១ ៖ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន ....................66

ក្រាបទី២ ៖ ភាពជាអ្នកដឹកនាំការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀនជាមួយសហគមន៍....................68

ក្រាបទី៣ ៖ ការប្រាស្រ័យទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដើម្បីទទួលបានលទ្ធផលល្អប្រសើរ ....................69

ក្រាបទី៤ ៖ បង្កើតកម្មវិធីជួបជុំ និងពិគ្រោះយោបល់រវាងមាតាបិតាសិស្ស និងគណៈគ្រប់គ្រងសាលា ...70

ក្រាបទី៥ ៖ ការសហការ និងទំនាក់ទំនងជាមួយសហគមន៍....................71

ក្រាបទី៦៖ ការបង្កើតបណ្ដាញសកម្មភាព និងការចរចារសម្រុះសម្រួលជាមួយសហគមន៍ ....................72

ក្រាបទី៧៖ ផ្នែកដោះស្រាយវិវាទ និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ....................74

ក្រាបទី៨៖ ការកសាងការបង្កើតគំនិតរួមគ្នាដើម្បីអភិវឌ្ឍន៍សាលា....................75

ក្រាបទី៩៖ ផែនការអភិវឌ្ឍសាលារៀន និងការអនុវត្តជានិរន្តរ៍ភាពដើម្បីការអប់រំទាំងអស់គ្នា ....................76

ក្រាបទី១០៖ បរិយាកាសគាំពារសម្រាប់កម្មវិធីពីសហគមន៍....................77

ក្រាបទី១១៖ ការបោះផ្សាយ និងការប្រកាសលទ្ធផលទិន្នន័យដល់ភាគីពាក់ព័ន្ធ ....................78

ក្រាបទី១២៖ សំណាកគ្រូបង្រៀន....................79

ក្រាបទី១៣៖ ការប្រតិបត្តិនៃកម្មវិធីសិក្សា ....................80

ក្រាបទី១៤៖ ការដំណើរការសម្រាប់ការរៀន និងបង្រៀនតាមកម្រិតថ្នាក់ ....................82

ក្រាបទី១៥៖ វិធីសាស្រ្តបង្រៀន....................83

ក្រាបទី១៦៖ ការអនុវត្តជាក់ស្ដែងក្នុងដំណើរការរៀន និងសកម្មភាពបង្រៀន ....................84

ក្រាបទី ១៧៖ វង្វាយតម្លៃ និងលទ្ធផល....................86

ក្រាបទី១៨៖ ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ....................87

ក្រាបទី១៩៖ សំណាករបស់សហគន៍ ....................89

ក្រាបទី២០៖ ការចូលរួមរបស់សហគន៍ក្នុងការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ....90

ក្រាបទី២១៖ សំណាករបស់សិស្ស....................92

ក្រាបទី២២៖ ការប្រតិបត្តិនៃការបង្រៀន និងរៀន ....................93

ក្រាបទី២៣៖ រង្វាយតម្លៃលទ្ធផលនៃការសិក្សា ....................................................................95
ក្រាបទី២៤៖ ការបង្កើតទំនាក់ទំនង និងការសហការគ្នា .............................................................96
ក្រាបទី២៥៖ ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន ...............................................98

# បញ្ជីនៃសញ្ញា និង អក្សរកាត់

អ.យ.ក៖ ក្រសួងអប់រំ យុវជន និងកីឡា

GEIP ៖ គម្រោងកែលម្អការអប់រំមធ្យមសិក្សា ( Gifted Individualized Education Plan )

WB ៖ ធនាគារពិភពលោក ( World Bank )

SOP ៖ Standard Operative Procedure

SMC ៖ Strategy Management Committee

# ជំពូក ១

# សេចក្តីផ្តើម

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ជាសកលលោកការអប់រំ ត្រូវបានចាត់ទុកថាជាវិស័យមួយដែលមិនអាចខ្វះបាន ដើម្បីធ្វើការអភិវឌ្ឍ និងបណ្តុះបណ្តាលធនធានសម្រាប់សង្គមជាតិ។ ការអភិវឌ្ឍសាលារៀនមួយប្រកបដោយនិរន្តរភាពបាន ទាមទារឱ្យអ្នកដឹកនាំ គ្រប់គ្រងមានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន បង្កើតឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដូចជា សិក្សានុសិស្ស គ្រូបង្រៀន ឪពុកម្តាយ គណៈកម្មការទ្រទ្រង់សាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធជាច្រើនទៀតនៅមូលដ្ឋាន ក្នុងការអនុវត្តសកម្មភាពដោយត្រូវ ធ្វើស្វ័យវាយតម្លៃសាលារៀន ដើម្បីឱ្យដឹងពីចំណុចល្អ និងអ្វីត្រូវកែលម្អ រួចធ្វើផែនការអភិវឌ្ឍន៍សាលារៀនដោយផ្អែកលើចំណុចត្រូវកែលម្អ និងធ្វើការពិនិត្យតាមដាន វាយតម្លៃសាលារៀនក្នុងឆ្នាំសិក្សានីមួយៗ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។

សាលារៀនជាកន្លែងផ្តល់ចំណេះចំណេះដឹង និងពង្រឹងទំនាក់ទំនងល្អជាមួយសហគមន៍ ជាពិសេសគណៈគ្រប់គ្រងសាលារៀនគួរព្យាយាមឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីស្វែងយល់បន្ថែមអំពីសហគមន៍ តាមរយៈការប្រាស្រ័យទំនាក់ទំនងគ្នាជាមួយសមាជិករបស់ខ្លួន (Sa'ad, T. U., & Sadiq, A. M., 2014)។ ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីប្រែក្លាយ និងធានាឱ្យបាននូវការអប់រំមួយប្រកបទៅដោយភាពជឿទុកចិត្តបានគ្រប់សមាសភាពភាគី ទាំងគុណភាព បរិយាបន្ន ប្រសិទ្ធភាព និងដើម្បីគាំទ្រដល់ការអប់រំពេញមួយជីវិតដោយគ្មានការរើសអើង ជពិសេសទាមទារឱ្យគណៈគ្រប់គ្រងសាលាចេះបញ្ជ្រាបការយល់ដឹង និងទាញការចូលរួមពីសហគមន៍ ទទួលយកគំនិតយោបល់របស់សហគមន៍ ដើម្បីចូលរួមកែលម្អ អភិវឌ្ឍន៍សាលារៀបប្រកបដោយចីរភាព និងយូរអង្វែង (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ ជាមួយគ្នានេះ ក្រសួងបានចេញសេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្រ្ត សហគមន៍សាលារៀន (២០២១) បានលើកឡើងថា ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងល្អជាមួយសហគមន៍ ការចូលរួមចំណែកក្នុងការអប់រំ ការអភិវឌ្ឍសាលារៀន ការរៀបចំសិក្ខាសាលាគួរតែត្រូវបានរៀបចំឡើង សម្រាប់

សមាជិកសហគមន៍ និងគ្រូបង្រៀនពិភាក្សាអំពីសារសំខាន់នៃទំនាក់ទំនងរវាងសាលារៀន ការយកចិត្តទុកដាក់ថែរក្សា ការចូលរួមរបស់មាតាបិតា ឬអាណាព្យាបាល គ្រួសាររបស់សិស្សនិងសហគមន៍ក្នុងវិស័យអប់រំជាការជួយកែលម្អសាលា លទ្ធផលសិស្សទទួលបានជាទីគាប់ប្រសើរ ដោយសហគមន៍ធ្វើការរួមគ្នាក្នុងការគាំទ្រដល់សាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។ អ្នកស្រាវជ្រាវក៏បានលើកឡើងអំពីការចូលរួម របស់សហគមន៍ មាតាបិតា និងគ្រួសារដែលជាគន្លឹះមួយដើម្បីដោះស្រាយវិបត្តិផ្សេងៗ ដូចជាវិបត្តិបោះបង់ការសិក្សា បញ្ហាសាលារៀនជាដើម (Belfield & Levin, 2007) ហើយគួរឱ្យកត់សម្គាល់បានផងដែរថា ភាពជាដៃគូរវាងសាលារៀន គ្រួសារ និងសហគមន៍ បានជំរុញសេចក្តីប្រាថ្នាលើការអប់រំខ្ពស់ និងការលើកទឹកចិត្តច្រើនចំពោះសិស្សានុសិស្ស (Barton, 2003) ។

ដោយយោងតាមអំណោះអំណាងខាងលើមក ឃើញថាបញ្ហាក្នុងការអភិវឌ្ឍសាលារៀនជាបញ្ហាចម្បង ដែលតម្រូវត្រូវការគាំទ្រ និងគាំពារពីសហគមន៍ដែលមិនអាចខ្វះបាន។ ការចូលរួមរបស់សហគមន៍ដែលជាបដិភាគ និងការគាំទ្រមានដូចជា ចូលរួមជាគំនិត ចូលរួមថែរក្សាទ្រព្យសម្បត្តិសាលារៀន និងសហគមន៍ទៅកៀងគរកដៃគូមូលនិធិដទៃទៀត ដែលជាការជម្រុញឱ្យមានការអភិវឌ្ឍសាលារៀន។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងដំណាក់កាលដែលក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍន៍វិស័យអប់រំ ដើម្បីឆ្លើយតប ទៅនិងសកលលោក ក្នុងការពង្រីកវិសាលភាព សំដៅលើការលើកកម្ពស់គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេសស្របនឹងទស្សនវិស័យអភិវឌ្ឍន៍សហស្សវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ តាមរបាយការណ៍អភិវឌ្ឍន៍សាកលលោក (២០០៤) បានបង្ហាញថា ដើម្បីធ្វើការឆ្លើយតប នឹងតម្រូវការអប់រំតាមរយៈការសម្រេចចិត្តពីថ្នាក់កណ្តាលតែឯង គឺមិនអាចឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរៀនសូត្ររបស់សិស្សបានឡើយ ដូចនេះវិស័យអប់រំត្រូវផ្ទេរអំណាចទៅ សាលារៀន និងសហគមន៍ក្នុងការអនុវត្តសេចក្តីសម្រេចចិត្តដើម្បីដោះស្រាយតម្រូវការសិក្សារៀនសូត្រឱ្យបានទាន់ពេលវេលា។ ដោយមើលឃើញបញ្ហាប្រឈមក្នុងទំនាក់

ទំនងរវាងសាលារៀននិងសហគមន៍ពុំទាន់បានឯកភាពដើម្បីជាមូលដ្ឋានអភិវឌ្ឍសាលារៀន ដែលចំណុចអវិជ្ជមានទាំងនោះហើយ ដែលមានឥទ្ធិពលដល់ការអភិវឌ្ឍសាលារៀន ការកៀងគរមូលនិធិដើម្បីសាលារៀនមានការអភិវឌ្ឍប្រកបដោយចីរភាព ការធ្វើផែនការ ការគ្រប់គ្រងសាលារៀន ការសហការរបស់សហគមន៍ និងភាគីដទៃទៀត ដើម្បីទទួលបានលទ្ធផលផ្លែផ្កាសម្រាប់ការអប់រំក្នុងសាលារៀន។

បញ្ហាប្រឈមសំខាន់ៗនៃការចូលរួមរបស់សហគមន៍ ដែលមានជាអាទិ៍ដូចជា សកម្មភាពនៃការដឹកនាំសហគមន៍ចូលរួមអភិវឌ្ឍសាលារៀន ការគាំទ្រនិងផ្សព្វផ្សាយរបស់សហគមន៍ និងសហគមន៍ចូលរួមកៀងគរដៃគូដទៃទៀតដើម្បីអភិវឌ្ឍសាលារៀន។ ឆ្លងតាមរយៈការមើលឃើញនិងសង្កេតនូវចំណុចទាំងអស់នេះហើយ បាននាំឱ្យខ្ញុំបាទដែលជានិស្សិតបានកំពុងសិស្សានៅ វិទ្យាស្ថានជាតិអប់រំ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ បានធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសយកប្រធានបទមួយមកសិក្សាគឺ « ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ» មកធ្វើការសិក្សាស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម៖

១. សិក្សាឈ្វេងយល់ពីការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនក្នុងខេត្តកំពង់ស្ពឺ។

២. កំណត់អំពីបញ្ហាប្រឈមរបស់សាលារៀនក្នុងការទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍន៍សាលារៀន។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវបានធ្វើការកំណត់នូវសំណួរស្រាវជ្រាវ ដូចខាងក្រោម៖

១.តើការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនក្នុងខេត្តកំពង់ស្ពឺបានប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. តើបញ្ហាប្រឈមចម្បងៗអ្វីខ្លះ របស់សាលារៀនក្នុងការទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍន៍សាលារៀន?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីប្រធានបទ « **ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ** » ពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សាស្រាវជ្រាវក្នុងការពង្រឹង និងពង្រីកបន្ថែមទៅលើចំណេះដឹង មានភស្តុតាងនានាបានយ៉ាងច្បាស់លាស់ និងជាការបង្កើតនូវតម្លៃកាលានុវត្តន៍ភាពសម្រាប់ការចូលរួមរបស់សហគមន៍ដើម្បីអភិវឌ្ឍន៍ ដែលសមាសភាពដូចជា (មាតាបិតា អាណាព្យាបាល សហគមន៍ អាជ្ញាធរ សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀត)ដើម្បីឱ្យសហគមន៍មានការយល់ដឹងបានកាន់តែស៊ីជម្រៅបន្ថែមទៀត ក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀន ក្នុងន័យធ្វើឱ្យមានផលជាវិជ្ជមានដល់ការសិក្សា និងការអប់រំរបស់ប្រជាជននូវព័ទ្ធជុំវិញ និងទូទាំងខេត្តនៃសាលារៀន ហើយក៏ជាការឆ្លើយតបការចង់បានរបស់ក្រសួងអប់រំ យុវជន និងកីឡានូវដំណាក់កាលទី៤ផងដែរ។

លើសពីនេះទៀតនោះ បានជួយបង្កើតចំណងកាន់តែរឹងមាំរវាងគណៈគ្រប់គ្រងសាលារៀន និងសហគមន៍ក្នុងខេត្តកំពង់ស្ពឺទាំងមូល ពោពេញទៅដោយការតម្កល់ផលប្រយោជន៍រួម មានការសាមគ្គីដើម្បីជាបុព្វហេតុក្នុងអត្ថប្រយោជន៍រវាងសាលារៀន និងសហគមន៍ទាំងមូល។ មួយវិញទៀត មានសារៈប្រយោជន៍សម្រាប់ថ្នាក់ដឹកនាំគោលនយោបាយ មន្ត្រីអប់រំថ្នាក់ជាតិនិងក្រោមជាតិ នាយកសាលា និងគ្រូបង្រៀន បានបណ្តុះនូវសុជីវធម៌បុគ្គល ធ្វើអំពើល្អដើម្បីប្រយោជន៍សិស្សនិងសហគមន៍ ដូចជាការរួមសាមគ្គីជាមួយគ្នាដើម្បបុព្វហេតុតែមួយគឺផលប្រយោជន៍សិស្សនិងសហគមន៍ ហើយបច្ចុប្បន្នបានក្លាយទៅជាគុណតម្លៃរួមដែលទាំងអស់គ្នាទទួលស្គាល់។ ព្រមទាំងបង្កើតការយល់ដឹងកាន់តែស៊ីជម្រៅ និងជាយាន្តនៃចំណេះដឹង នៃការអភិវឌ្ឍផែនការសាលារៀនសម្រាប់ជាប្រយោជន៍ជាមួយមជ្ឈដ្ឋានទូទៅ។ សំខាន់ជាងនេះទៀតនោះ ទុកជាឯកសារសម្រាប់សិស្សានុសិស្ស ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ ដទៃទៀតបានសិក្សាឈ្វេងយល់បន្ថែមធ្វើការថ្លឹងថ្លែងដើម្បរកផលប្រយោជន៍ជូនសង្គមជាតិរបស់យើងទាំងមូល។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

គោលបំណងដំបូងក្នុងការសិក្សាស្រាវជ្រាវនេះ គឺសិក្សាពីការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ នៅទូទាំងខេត្តកំពង់ស្ពឺ ប៉ុន្តែដោយសារតែកត្តានៃពេលវេលា វិសាលភាពនៃការសិក្សាស្រាវជ្រាវជ្រាវនេះត្រូវបានបង្រួម ដោយផ្តោតទៅលើសាលាមធ្យមសិក្សាទុតិយភូមិចំនួនបីដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ដែលមានដូចជា វិទ្យាល័យហ៊ុនសែនភ្នំស្រួច វិទ្យាល័យម្តៃបួនកញ្ញា និងវិទ្យាល័យហ៊ុនសែនចំបក់ ដែលជាសាលាគោលដៅសម្រាប់សិក្សាស្រាវជ្រាវ។ ដើម្បីសិក្សាសិក្សាឈ្វេងយល់ពីការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនក្នុងខេត្តកំពង់ស្ពឺ និងកំណត់អំពីបញ្ហាប្រឈម និងអត្ថប្រយោជន៍របស់សហគមន៍ក្នុងការចូលរួមជាមួយសាលារៀន។

ចំពោះដែនកំណត់នៃការសិក្សាស្រាវជ្រាវក្នុងនិក្ខេបបទនេះ បានផ្តោតទៅលើ ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ ដោយកំណត់យកចាប់ពី ឆ្នាំ ២០២១ រហូតដល់ ២០២២។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះផងដែរត្រូវបានបែងចែកចេញជា ៥ ជំពូកធំៗ រួមមានការបរិយាយនូវជំពូកនីមួយៗដូចខាងក្រោម៖

**ជំពូកទី១៖ សេចក្តីផ្តើម** នៅក្នុងជំពូកនេះផងដែរ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ និងចុងបញ្ចប់នៃជំពូក រចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធាន« ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ» ។ ដោយផ្តោតទៅលើឫគល់នៃបញ្ហា គោលដៅនៃការសិក្សាស្រាវជ្រាវ ព្រមទាំងការបង្ហាញអំពីបញ្ហាការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់សហគមន៍ ហើយបានបង្ហាញនូវបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍គឺ សកម្មភាពនៃការដឹកនាំសហគមន៍ចូលរួមអភិវឌ្ឍសាលារៀន ការគាំទ្រនិងផ្សព្វផ្សាយរបស់សហគមន៍ និងសហគមន៍ចូលរួមកៀងគរដៃគូដទៃទៀតដើម្បីអភិវឌ្ឍសាលារៀន។ ក្នុង

អត្ថប្រយោជន៍បង្ហាញសារៈសំខាន់នៃការស្រាវជ្រាវ លើកកម្ពស់ការអភិវឌ្ឍសាលារៀន បង្កើតការចូលរួមរបស់សហគមន៍ និងចំណេះដឹងនៃការអភិវឌ្ឍផែនការសាលារៀន។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីដែលមានពីមុនហើយបានពាក់ព័ន្ធទៅនិងប្រធានបទស្រាវជ្រាវតាមរយៈឯកសារនានា ដែលមានជាសៀវភៅជាភាសាជាតិ និងអន្តរជាតិ តាមទស្សនាវដ្តី ការសែត ឯកសារតាមបណ្ណាល័យ កម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តរជាតិ សេចក្តីប្រកាស សារាចរណែនាំ ព្រមទាំងឯកសារផ្សេងៗទៀតរបស់ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នដែលពាក់ព័ន្ធដទៃផ្សេងទៀតដើម្បីយកមកធ្វើជាគំរូ និងជាដើមទុនសម្រាប់ធ្វើកិច្ចការស្រាវជ្រាវ និងវិភាគជាគំនិតដើម្បីបានជាសំអាងភស្តុតាង ហើយឆ្នៃបង្កើតទៅជាស្នាដៃថ្មីដើម្បីទុកជាមរតកដល់អ្នកសិក្សាជំនាន់ក្រោយៗទៀត។

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** នៅក្នុងជំពូកនេះអ្នកសិក្សានិងធ្វើការបង្ហាញអំពីឧបករណ៍ផ្សេងៗសម្រាប់ធ្វើការស្រាវជ្រាវ ដូចជា វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកនិងប្រភេទសំណាក ព្រមទាំងវិធីបញ្ចូល និងវិភាគទិន្នន័យផងដែរ។ ក្នុងការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវបានបង្ហាញពីវិធីសាស្ត្រដែលត្រូវប្រើ ប្រភេទទិន្នន័យនិងប្រភពទិន្នន័យ។ នៅក្នុងការជ្រើសរើសសំណាកជាការបង្ហាញការជ្រើសរើសចំនួនសំណាក ទីកន្លែងនៃការប្រមូលសំណាក មូលហេតុនៃការប្រមូលសំណាក និងរបៀបនៃការជ្រើសរើសសំណាក។ ចំពោះប្រភពទិន្នន័យវិញ បង្ហាញអំពីប្រភពទិន្នន័យដែលអ្នកសិក្សាស្រាវជ្រាវទៅសម្ភាសន៍ (អាចសម្ភាសន៍ដោយផ្ទាល់ រៀបចំជាកម្រងសំណួរ អង្កេត និងទិន្នន័យមានស្រាប់ ជាដើម)។ រីឯការប្រមូលទិន្នន័យ រៀបរាប់អំពីដំណើរការប្រមូលទិន្នន័យ បង្ហាញអំពីគោលបំណងនៃការប្រមូលទិន្នន័យ។ ម្យ៉ាងវិញទៀតការវិភាគទិន្នននន័យ បានប្រាប់អំពីដំណើរការទិន្នន័យ (ការសម្អាត បែងចែក និងវិភាគទិន្នន័យ) ប្រាប់ពីវិធីសាស្ត្រវិភាគទិន្នន័យ និងបកស្រាយទិន្នន័យ។ ជាចុងក្រោយនៃជំពូកបានលើកឡើង ក្រមសីលធម៌នៃការស្រាវជ្រាវ ហើយធានារក្សាការសម្ងាត់អត្តសញ្ញាណនៃការស្រាវជ្រាវនេះផងដែរ។

**ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ ព្រមទាំងយកទិន្នន័យដែលបានប្រមូលមកធ្វើការវិភាគ និងដើម្បីធ្វើការបកស្រាយឱ្យបានក្បោះក្បាយក្នុងន័យដើម្បីស្វែងរកឱ្យឃើញនូវចំណុចល្អ និងចំណុចត្រូវកែលម្អនៅក្នុងបរិបទជាក់ស្ដែងពាក់ព័ន្ធ និងបញ្ហាប្រឈមក៏ដូចជា ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន បញ្ហាប្រឈម និងអត្ថប្រយោជន៍នៃការចូលរួមរបស់សហគមន៍។ មួយវិញទៀត បានបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សាទៅលើខ្លឹមសារ នឹងការធ្វើសំយោគដើម្បីបង្កើតនូវទ្រឹស្ដីថ្មី ដើម្បីឱ្យមានការចូលរួមពីសហគមន៍បានយ៉ាងច្រើនកុះករ និងមានស្ថេរភាព ហើយដើម្បីធានាថាការចូលរួមមានសកម្មភាព ដើម្បីជួយដល់ដំណើរការសាលារៀន ការអភិវឌ្ឍសាលារៀន និងទទួលបានមកវិញអំពីផលជះនៃការសិក្សារបស់សិស្សានុសិស្ស។

**ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ** នៅក្នុងជំពូកនេះផងដែរ ជាផ្នែកមួយដែលអ្នកសិក្សាស្រាវជ្រាវប្រមូលគំនិត ទស្សនៈផ្សេងៗ លទ្ធផលពីការវិភាគទៅលើចំណុចរួមទាំងអស់ដែលបានវិភាគ ព្រមទាំងផ្ដល់ជាសំណូមពរមួយចំនួនដល់ក្រសួងអប់រំ យុវជន និងកីឡា និងការិយាល័យដែលពាក់ព័ន្ធ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន អាជ្ញាធរដែនដី ការចូលរួមរបស់សហគន៍ ហើយជាពិសេសជាងនេះទៀតនោះ ក៏ជាផែនទីមួយសម្រាបប់បង្ហាញផ្លូវមួយសម្រាប់អ្នកសិក្សាក្រោយៗផ្សេងទៀត ដែលនិងលើកយកប្រធានបទប្រហាក់ប្រហែលមកសិក្សាស្រាវជ្រាវ ដើម្បីក្នុងគោលដៅ និងគោលបំណងជួយអភិវឌ្ឍ និងកែលម្អនូវចំណុចផ្សេងៗឱ្យកាន់តែប្រសើរឡើង និងរីកដុះសាយបន្ថែមទៀត។

# ជំពូក ២

# ការរំលឹកទ្រឹស្តី

# ជំពូក ២
# ការរំលឹកទ្រឹស្តី

នៅក្នុងជំពូករំលឹកទ្រឹស្តីនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីដែលមានពីមុនហើយបានពាក់ព័ន្ធទៅនិងប្រធានបទស្រាវជ្រាវតាមរយៈឯកសារនានា ដែលមានដូចជាសៀវភៅជាភាសាជាតិ និងអន្តរជាតិ តាមទស្សនាវដ្តី ការសែត ឯកសារតាមបណ្ណាល័យ កម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តរជាតិ សេចក្តីប្រកាស សារាចរណែនាំ ព្រមទាំងឯកសារផ្សេងៗទៀតរបស់ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នដែលពាក់ព័ន្ធដទៃផ្សេងទៀតដើម្បីយកមកធ្វើជាគំរូ និងជាដើមទុនសម្រាប់ធ្វើកិច្ចការស្រាវជ្រាវ និងវិភាគជាគំនិតដើម្បីបានជាសំអាងកស្តុតាង ហើយឆ្នៃបង្កើតទៅជាស្នាដៃថ្មីដើម្បីទុកជាមរតកដល់អ្នកសិក្សាជំនាន់ក្រោយៗទៀត។

## ២.១ និយមន័យ

### ២.១.១ ការចូលរួម

**ការចូលរួម** អាចត្រូវបានបកស្រាយតាមវិធីផ្សេងៗគ្នា អាស្រ័យលើបរិបទ។ Shaeffer (1994) បញ្ជាក់ដឺក្រេផ្សេងគ្នា ឬក៏កម្រិតនៃការចូលរួម រួមមាន៖

- ការចូលរួមតាមរយៈការរួមចំណែកដូចជា ប្រាក់ សម្ភារៈ និងកម្លាំងពលកម្ម
- ការចូលរួមតាមរយៈ (អវត្តមាន attendance) ឧ.ការប្រជុំរបស់ឪពុកម្តាយនៅសាលារៀន បង្កប់ន័យការទទួលយកអកម្មនៃការសម្រេចចិត្តដែលធ្វើឡើងដោយកត្តាផ្សេងទៀត
- ការចូលរួមតាមរយៈការពិគ្រោះយោបល់លើបញ្ហាពិសេស
- ការចូលរួមក្នុងការផ្តល់សេវា ជាញឹកញាប់ជាដៃគូជាមួយតារាសម្តែងផ្សេងទៀត
- ការចូលរួមជាអ្នកអនុវត្តអំណាចផ្ទេរសិទ្ធិ និងការចូលរួម (នៅក្នុងការសម្រេចចិត្តពិតប្រាកដនៅគ្រប់ដំណាក់កាល) រួមទាំងការកំណត់អត្តសញ្ញាណបញ្ហា ជំហាននៃផែនការ ការអនុវត្ត និងការវាយតម្លៃ (Uemura, 1999) ។

**ការចូលរួម** គឺជាដំណើរការរួមផ្សំបញ្ចូលគ្នា ការចូលគ្នា ការសហការគ្នា ការប្រមូលឱ្យមូលគ្នា មូលមួយនឹងគ្នា រួមសេចក្តី ដាក់រួមគ្នា ធ្វើការរួមគ្នា រួមគំនិត រួមចិត្ត ចូលគំនិតគ្នា រួមដៃគ្នា ចូលដៃគ្នា (ជួន,

១៩៦៧)។ នៅក្នុងនិយមន័យផ្សេងទៀត ការចូលរួមគឺទាក់ទងនឹងការអភិវឌ្ឍន៍ និងការកើនឡើងអារម្មណ៍របស់មនុស្ស នៃការគ្រប់គ្រងរបស់មនុស្សលើបញ្ហាដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ ជួយពួកគេឱ្យរៀនពីរបៀបរៀបចំផែនការ និងអនុវត្តន៍ ហើយនៅផ្នែកខាងមុខបើកចំហទូលំទូលាយ ពួកគេរៀបចំសម្រាប់ការចូលរួមនៅថ្នាក់តំបន់ ឬថ្នាក់ជាតិ។ សរុបមក ការចូលរួមគឺជា រឿងល្អ ពីព្រោះវាបានបំបែកភាពឯកោរបស់មនុស្ស អង្គភាព និងដាក់ជាមូលដ្ឋានគ្រឹះសម្រាប់ពួកគេ ហើយឥទ្ធិពលយ៉ាងធំធេងលើការអភិវឌ្ឍន៍ ប៉ុន្តែក៏មានការឯករាជ្យភាព និងការគ្រប់គ្រងលើជីវិតរបស់ពួកគេ (Oakley, 1991; Warburton, 1997)។ បើគ្មានការចូលរួមពីសហគមន៍ទេ គឺជាក់ស្តែង គ្មានភាពជាដៃគូ គ្មានការអភិវឌ្ឍ និងគ្មានកម្មវិធី។ ដូច្នេះហើយការខ្វះការចូលរួមរបស់សហគមន៍ ក្នុងការសម្រេចចិត្តដើម្បីអនុវត្តការអភិវឌ្ឍ ការអប់រំអាចនាំទៅរកការបរាជ័យក្នុងការអភិវឌ្ឍន៍សហគមន៍សាលារៀន (Miranda, 2007)។

ការចូលរួម ជាសមាសធាតុមួយដ៏សំខាន់សម្រាប់ការអនុវត្តផែនការមួយ ឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាពក្នុងការងារ។ យ៉ាងណាការចូលរួមជាការរួមផ្គុំគ្នាទាំងគំនិតស្មារតី ការគាំទ្រ ការធ្វើបដិភាគធនធានសម្ភារៈ ថវិកា និងរួមកម្លាំងគ្នាជាធ្លុងមួយដើម្បីថែរក្សា គៀងគរដៃគូដទៃផ្សេងទៀតមកចូលរួម។ តួយ៉ាងដូចជាការ ចូលរួមថែរក្សានូវទ្រព្យសម្បត្តិសាលារៀន ឱ្យបានស្ថិតថេរគង់វង្ស និងយូរអង្វែង។

### ២.១.២ សហគមន៍

**សហគមន៍៖** គឺជាប្រភេទអន្តរកម្មដែលរស់នៅក្នុងតំបន់ជាក់លាក់មួយ ហើយត្រូវបានកំណត់ថាជាសារពាង្គកាយទាំងអស់ដែលរស់នៅក្នុងតំបន់ជាក់លាក់មួយ (Molles, 2010)។ **សហគមន៍** គឺជាក្រុមមនុស្សមួយក្រុម ដែលរស់នៅមានទំនាក់ទំនងគ្នា ដោយប្រពៃណី សាសនា ទំនៀមទំលាប់កំរិតជីវភាព និងគោបំណងប្រហាក់ប្រហែលគ្នា (សែម ២០១៩)។ **សហគមន៍** គឺជាដំណើរការរួមគ្នា ឬការរស់នៅផ្តុំគ្នា ការទៅជាមួយគ្នា ដំណើរជាមួយគ្នា ប្រជុំគ្នា ឬអ្នកស្រុកប្រកបមុខរបរចូលគ្នា ការប្រជុំភូមិតំបន់ អ្នកស្រុកដែលរស់នៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា និងធ្វើការងារអ្វីមួយរួមគ្នាជាប្រយោជន៍រួម ហើយបង្កើតឲ្យមានសហគមន៍ (ជួន, ១៩៦៧)។ **សហគមន៍** គឺសំដៅដល់ប្រជាជន ឬក៏ប្រជាពលរដ្ឋដែលបានរស់នៅក្នុងតំបន់មួយ ហើយស្ថិតនៅក្នុងក្របខ័ណ្ឌអនុវត្តច្បាប់តែមួយ ដែលមានទំនៀមទម្លាប់ប្រហាក់ប្រហែលគ្នា ឬ

ស៊ីចង្វាក់គ្នា ដើម្បីរស់នៅក្នុងសង្គមមួយ។ តួយ៉ាងដែលនៅក្នុងបរិបទនៃការសិក្សាអប់រំរបស់ប្រទេសកម្ពុជា សហគមន៍គឺសំដៅដល់ ភូមិ ឃុំ/សង្កាត់ ក្នុងការជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍសាលារៀនក្នុងសហគមន៍ ឱ្យសាលារៀនពោពេញទៅដោយសក្តានុពលភាព ការរីកចម្រើន ព្រមទាំងការអប់រំដើម្បីទាំងអស់គ្នា (គម្រោងកែលម្អការអប់រំមធ្យមសិក្សា GEIP, ២០២២)។ គួរបញ្ជាក់ថាការរៀបចំជាគម្រោងកែលម្អការអប់រំចំណេះទូទៅ បានឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងមូលធនមនុស្សកម្ពុជា ដូចមានចែង នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ព្រមទាំង ឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជា នៅឆ្នាំ ២០៣០ និង ២០៥០។ ជាមួយគ្នានេះ គម្រោងក៏បានឆ្លើយតបទៅនឹងកំណែទម្រង់ សំខាន់ៗដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសគម្រោងថ្មីនេះក៏ជាមូលដ្ឋានគ្រឹះ ក្នុងការសម្រេចបាននូវគោលនយោបាយ អប់រំទាំងពីររបស់ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៩-២០២៣។

សហគមន៍ជាការរស់នៅប្រជុំគ្នា ដែលរស់នៅក្នុងតំបន់មួយ ហើយមានទំនៀមទំលាប់ប្រហាក់ប្រហែលគ្នា ដើម្បីរស់នៅក្នុងសង្គមមួយ។ ដើម្បីបង្កើតជាសហគមន៍មួយប្រកបដោយ ចីរភាពត្រូវមានការសហការគ្នាជាធ្លង់មួយ ចេះសហការរួមគំនិតគ្នាដើម្បីបង្កើតអ្វីដែលជាផលប្រយោជន៍រួមគ្នា ក្នុងសហគមន៍ និងនៅក្នុងតំបន់របស់ខ្លួន។ តួយ៉ាងសហគមន៍ បានដើរតួនាទីយ៉ាងសំខាន់ ដែលជាស្នូលដែលមិនអាចខ្វះបានសម្រាប់ការចូលរួមអនុវត្តន៍ផែនការឱ្យទទួលបានជោគជ័យតាមផែនការដែលបានគ្រោងទុក។

**២.១.៣ ការអភិវឌ្ឍសាលារៀន**

**ការអភិវឌ្ឍសាលារៀន** គឺជាយន្តការសម្រាប់អភិវឌ្ឍន៍ផែនការអភិវឌ្ឍសាលារៀន ដោយមានការដឹកនាំដោយនាយកសាលារៀន គណៈកម្មការអភិវឌ្ឍសាលារៀន និងគណៈកម្មការប្រតិបត្តិសាលារៀន ហើយអ្នកចូលរួមមាន គណៈគ្រប់គ្រងសាលា អាជ្ញាធរដែនដី ប្រធានក្រុម មេភូមិ ក្រុមប្រឹក្សាឃុំនិងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្រុមប្រឹក្សាយុវជននិងកុមារ សិស្ស គ្រូពេទ្យ និងមាតាបិតាសិស្ស (ក្រសួងអប់រំ យុវជន និងកីឡា,២០១៧)។ ប្រព័ន្ធកម្រងសាលារៀន គឺជាយន្តការដែលជួយសម្របសម្រួលការងាររវាង

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និង សាលារៀន ។ ប្រព័ន្ធកម្រងសាលារៀនអាចមានដំណើរការល្អទៅបាន គឺអាស្រ័យ ទៅលើជំនឿទុកចិត្តរបស់លោកគ្រូ អ្នកគ្រូ និង នាយកសាលាដែលជាសមាសភាពសំខាន់បំផុតក្នុងការលើកកម្ពស់ គុណភាពអប់រំនៅក្នុងកម្រិតអប់រំមូលដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា។ កម្រងសាលារៀនបាន ដើរតួនាទី ជាវេទិកាសេរី ប្រជាធិបតេយ្យ ដែលផ្តល់ឱកាសឱ្យលោកគ្រូ-អ្នកគ្រូ នាយកសាលា និង សិស្សានុសិស្ស បានបញ្ចេញមតិពិភាក្សា ផ្លាស់ប្តូរយោបល់ អំពីការងារអប់រំនៅក្នុងមូលដ្ឋានរៀងៗខ្លួន និងបង្ហាញពីតួនាទីយ៉ាង សំខាន់បំផុតរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១០)។

ការអភិវឌ្ឍសាលារៀនមួយប្រកបដោយនិរន្តរភាពបាន ទាមទារឱ្យអ្នកដឹកនាំ គ្រប់គ្រងមានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន បង្កើនឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដូចជា សិស្សានុសិស្ស គ្រូបង្រៀន ឪពុកម្តាយ គណៈកម្មការទ្រទ្រង់សាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធជាច្រើនទៀតនៅមូលដ្ឋាន ក្នុងការអនុវត្តសកម្មភាពដោយត្រូវ ធ្វើស្វ័យវាយតម្លៃសាលារៀន ដើម្បីឱ្យដឹងពីចំណុចល្អ និងអ្វីត្រូវកែលម្អ រួចធ្វើផែនការអភិវឌ្ឍសាលារៀនដោយផ្អែកលើចំណុចត្រូវកែលម្អ និងធ្វើការពិនិត្យតាមដានវាយតម្លៃសាលារៀនក្នុងឆ្នាំសិក្សានីមួយៗ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។

ជាការពិតការអភិវឌ្ឍសាលារៀនពិតជាមានសារៈសំខាន់ តែការអភិវឌ្ឍសាលារៀនមួយទៅបានត្រូវមានការចូលរួម និងការសហការគ្រប់សមាភាពភាគីពាក់ព័ន្ធដទៃទៀតដើម្បីការអភិវឌ្ឍដោយរលូននិងនិរន្តរ៍ភាពយូរអង្វែង។ មួយវិញទៀត សាលារៀនមួយមានការអភិវឌ្ឍត្រូវមានការដឹកនាំដោយត្រឹមត្រូវតម្លាភាព សុច្ចរិតភាព និងគណនេយ្យភាព ជាពិសេសមានការចូលរួមសហការពីសហគមន៍ និងភាគីដៃគូដទៃទៀត ដែលជាកម្លាំងចលករក្នុងការជួយជម្រុញ ការអភិវឌ្ឍសាលារៀនឱ្យបានកាន់តែឆាប់រហ័យ និងវែងឆ្ងាយ។

## ២.២ធាតុសំខាន់ៗនៃការអភិវឌ្ឍសាលារៀន

ការអភិវឌ្ឍសាលារៀនត្រូវបានទទួលស្គាល់ជាការចាំបាច់ ដើម្បីការអប់រំមានសមត្ថភាពខ្ពស់សម្រាប់ជាការកសាងបុគ្គលិកលក្ខណៈមនុស្សឱ្យមានការអភិវឌ្ឍ ដើម្បីឱ្យក្លាយជាពលរដ្ឋថ្លៃថ្នូរ និងមាន

ប្រយោជន៍ដល់សង្គមជាតិ។ ដូច្នេះយើងគប្បីត្រូវស្វែងយល់ពីកត្តាទាំងឡាយ ដែលនាំឱ្យមានឥទ្ធិពលទៅលើការអភិវឌ្ឍសាលារៀន។ កត្តាដែលនាំឱ្យមានការអភិវឌ្ឍសាលារៀនរួមមាន៖

**២.២.១. តួនាទីរបស់គណៈគ្រប់គ្រងសាលារៀន**

តួនាទីគណៈកម្មការគ្រប់គ្រងសាលារៀន និងអភិបាលកិច្ចសាលារៀន ជាការគាំទ្រក្នុងការដោះស្រាយបញ្ហាដែលលើកឡើង ដោយមាតាបិតានិងសិស្សពីការពិនិត្យតាមដានសាលារៀននិងថ្នាក់រៀនមានតម្លាភាពក្នុងការចូលរួមរបស់សហគមន៍ និងជាការសម្របសម្រួលធានាដំណើរការដោយរលូននូវការអនុវត្តសកម្មភាព ជាតួនាទីរបស់សហគមន៍និងអភិបាលកិច្ចសាលារៀន ពិនិត្យឡើងវិញនិងដាក់ស្នើការកែសម្រួលដើម្បីធានានូវតម្លាភាពក្នុងការចូលរួមរបស់សហគមន៍(ក្រសួងអប់រំ យុវជន និងកីឡា,២០១៨)។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ត្រង់គោលដៅទី៤ ស្តីពីគុណភាពអប់រំ បានកំណត់អំពីចំណុចដៅយ៉ាងយូរឆ្នាំ២០៣០ ធ្វើយ៉ាងណាបង្កើនឱ្យបាននូវការបញ្ជូននាយក/គ្រូដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ឱ្យទៅគ្រប់សាលារៀនទាំងអស់(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។

គណៈកម្មការគ្រប់គ្រងសាលារៀន ជារចនាសម្ព័ន្ធផ្លូវការ ដើម្បីគ្រប់គ្រងការអនុវត្តប្រចាំថ្ងៃ នៃការគ្រប់គ្រងតាមសាលារៀន។ គណៈកម្មការគ្រប់គ្រងសាលារៀន មានសមាសភាពចំនួន៦រូប ដែលមន្ត្រីក្រុមការងារគ្រប់គ្រងតាមសាលារៀន របស់ក្រសួងអប់រំ យុវជន និងកីឡា ក្រុមគ្រូបង្គោលមុខវិជ្ជាថ្នាក់ជាតិ គ្រូបង្រៀន និងបុគ្គលិកសាលារៀន តំណាងមាតាបិតា រួមបញ្ចូលទាំងគ្រួសារ អ្នកក្រនិងយ៉ាប់យឺន និងសហគមន៍ ដែលមានប្រធានភូមិ អ្នកមានប្រជាប្រិយ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ ក្នុងវិស័យអប់រំ ជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូច្នេះនាយកសាលាត្រូវបានចាត់ទុកជាអ្នកមានសក្តានុពល និងជាកូនសោរគន្លឹះក្នុងការបង្កើនគុណភាពអប់រំ ហើយជាអ្នកកំណត់នូវចក្ខុវិស័យ បេសកកម្ម នៃផែនការរបស់សាលារៀន។ នាយកសាលារៀនត្រូវមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយមាតាបិតា អាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀតក្នុងការរៀបចំផែនការជាត្រីវិស័យគោល សម្រាប់អនុវត្តន៍ឈានទៅរកការអភិវឌ្ឍសាលារៀនបណ្តើរៗស្របតាមមជ្ឈដ្ឋានរស់នៅតាមបរិបទសង្គម និងការអភិវឌ្ឍ តាមភាពជឿនលឿនលើវិស័យអប់រំសកលលោកផង។ គណៈកម្មការ

គ្រប់គ្រងសាលារៀន ជារចនាសម្ព័ន្ធផ្លូវការ ដើម្បីគ្រប់គ្រងការអនុវត្តប្រចាំថ្ងៃ នៃការគ្រប់គ្រងតាមសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀនដែលជាមន្ត្រី ក្រុមការងារគ្រប់គ្រងតាមសាលារៀនរបស់ អ.យ.ក ក្រុមគ្រូបង្គោលមុខវិជ្ជាថ្នាក់ជាតិ គ្រូបង្រៀន និងបុគ្គលិកសាលារៀន តំណាងមាតាបិតារួមបញ្ចូលទាំងគ្រួសារ អ្នកក្រ និងយ៉ាប់យឺន និងសហគមន៍ដែលមានប្រធានភូមិ អ្នកប្រជាប្រិយ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ និងអ្នកពាក់ព័ន្ធផ្សេងទៀត ព្រមទាំងសមាសភាពនៃគណៈកម្មការគ្រប់គ្រងសាលារៀនមានៈ (១) ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនទទួលបន្ទុកមើលការខុសត្រូវប្រតិបត្តិការរួម (២) អនុប្រធានទទួលបន្ទុកការធ្វើផែនការ និងការគ្រប់គ្រងថវិការសាលារៀន (៣) អនុប្រធានទទួលបន្ទុកការគ្រប់គ្រងមន្ត្រី (៤)សមាជិកទទួលបន្ទុកការចូលរួមរបស់សហគមន៍ និងអភិបាលកិច្ចសាលារៀន (៥) សមាជិកទទួលបន្ទុកការវាយតម្លៃសាលារៀន និងសិស្ស (៦) សមាជិកទទួលបន្ទុក គណនេយ្យភាពសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

នាយកសាលារៀនត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ សមត្ថភាព ភាពច្នៃប្រឌិតខ្ពស់ និងការប្រាស្រ័យទាក់ទងល្អសម្រាប់ផ្តល់សេវាអប់រំ ប្រកបដោយគុណភាព និងភាពឆ្លើយតប ព្រមទាំងនាយកសាលារៀនត្រូវមានសមត្ថភាព និងគុណសម្បត្តិដែលបង្ហាញពីភាពខ្លាំង និងប្រសិទ្ធភាពរបស់ខ្លួន ក្នុងការបង្ហាញពីតម្លាភាព និងគណនេយ្យភាព អ្វីៗដែលបានធ្វើត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ មានមោទនភាពលើវិជ្ជាជីវៈរបស់ខ្លួនត្រូវបំពេញ ការងារឱ្យអស់ពីលទ្ធភាព និងសមត្ថភាព ចេះជ្រើសរើសចំណុចណាជាអាទិភាពមកធ្វើមុន ហ៊ានធ្វើសេចក្តីសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈម បង្ហាញឥរិយាបថ ភាពជាសហគ្រិនភាព ហើយនិងនាយកសាលារៀនចាំបាច់ត្រូវអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ក្នុងនោះមានស្វ័យសិក្សាស្រាវជ្រាវ គាំទ្រតម្លៃទស្សនវិស័យរបស់អាស៊ាន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។

តាមសៀវភៅ ស្តង់ដានាយកសាលារៀន (២០១៧) របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ដានាយកសាលារៀន សកម្មភាព សូចនាករ មាន៦ស្តង់ដាគឺ ៖

- ស្តង់ដាទី១ កម្រិតវប្បធម៌ និងបទពិសោធការងារ

- ស្តង់ដាទី២ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលារៀន (ក្រមសីលធម៌វិជ្ជាជីវៈ ភាពជាអ្នកដឹកនាំ ការប្តេជ្ញាចិត្ត )
- ស្តង់ដាទី៣ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ (ចក្ខុវិស័យ បេសកកម្ម គោលនយោបាយនិងផែនការការយុទ្ធសាស្ត្រ ការអនុវត្តចក្ខុវិស័យនិងផែនការសកម្មភាព ការត្រួតពិនិត្យនិងវាយតម្លៃការងារ)
- ស្តង់ដាទី៤ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន (ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ)
- ស្តង់ដាទី៥ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងរៀន (ការគ្រប់គ្រងការរៀននិងបង្រៀន ការស្រាវជ្រាវ ការសហការនិងទំនាក់ទំនង ការអភិវឌ្ឍសមត្ថភាព ការធ្វើអធិការកិច្ចផ្ទៃក្នុង
- ស្តង់ដាទី៦ ការផ្សារភ្ជាប់សាលារៀន និងសហគមន៍ (អាជ្ញាធរដែនដី មាតាបិតា ភាគីពាក់ព័ន្ធ )

គោលការណ៍សំខាន់ៗនៃស្តង់ដានាយកសាលារៀនៈ គុណវុឌ្ឍិ បទពិសោធការងារ ការគិតបែបយុទ្ធសាស្ត្រនិងនវានុវត្តន៍ ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងរដ្ឋបាលសាលារៀន ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សាការបង្រៀននិងរៀន ឧត្តមភាពរបស់នាយកសាលារៀន ការផ្សារភ្ជាប់សាលារៀននិងសហគមន៍។

យោងតាម ឧបករណ៍វាយតម្លៃនាយកសាលារៀនល្អ ជាឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ៧៦១ អ.យ.ក.ប្រកចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦បានចែងអំពីសូចនាករនាយសាលារៀនល្អដូចខាងក្រោមៈ

**១. គុណវុឌ្ឍិ** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬសញ្ញាបត្រសមមូលសញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រសមមូល សញ្ញាបត្រឬវិញ្ញាបនបត្របណ្តុះបណ្តាលបង្រៀន សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**២. ចំណេះដឹងមូលដ្ឋានផ្នែកព័ត៌មានវិទ្យានិងទូរគមនាគមន៍** ក្នុងលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើសមត្ថភាពប្រើប្រាស់កុំព្យូទ័រ បង្កលក្ខណៈឱ្យមានការបង្រៀនតាមអនឡាញដោយផ្សាយផ្ទាល់ ឬចាក់ផ្សាយក្នុងបណ្តាញសង្គមនានា ការប្រើប្រាស់បច្ចេកទេសព័ត៌មាននិងទូគមនាគមន៍ក្នុងការដឹកនាំនិងគ្រប់គ្រងការងាររដ្ឋបាល ការបង្រៀននិងរៀន ការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស។

**៣. សមត្ថភាពជំនាញ** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ការយល់ដឹងគោលនយោបាយអប់រំក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដឹកនាំគ្រប់គ្រងសម្របសម្រួលនិងច្នៃប្រឌិត ការធ្វើផែនការអធិការកិច្ចនិងអធិការកិច្ចថ្នាក់រៀន ភាសាបរទេស ប្រវត្តិនិងបទពិសោធចាប់ពី៥ឆ្នាំឡើងទៅ ជំនាញប្រមូល វិភាគ និងបកស្រាយព័ត៌មាន ការលើកទឹកចិត្តសិស្សគ្រូ និងបុគ្គលិកអប់រំ។

**៤. ការរៀបចំផែនការ** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ចក្ខុវិស័យ បេសកម្ម គោលបំណងច្បាស់លាស់ ការរៀបចំផែនការដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ការអនុវត្តការងារប្រកបដោយគុណតម្លៃ ការផ្សារភ្ជាប់សាលារៀន និងសហគមន៍។

**៥. ការដឹកនាំការបង្រៀន និងរៀន** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ការផ្តួចផ្តើមនិងគាំទ្រការប្រជុំក្រុមបច្ចេកទេស ការត្រួតពិនិត្យនិងវាយតម្លៃការបង្រៀននិងរៀនជាប្រចាំ កាបំប៉នវិធីសាស្ត្រ និងផ្តល់ប្រឹក្សាបច្ចេកទេសដល់គ្រូបង្រៀន ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន ការប្រើវិធីសាស្ត្រដោយមានភាពឆ្លើយតបនិងភាពច្នៃប្រឌិតសម្រាប់ការបង្រៀននិងរៀន ការលើកទឹកចិត្តនិងចេះធ្វើការជាក្រុមដើម្បីបង្កើតវប្បធម៌ចែករំលែក ការធានាឱ្យមានសម្ភារសិក្សានិងសម្ភារឧបទេសគ្រប់កម្រិតថ្នាក់និងគ្រប់មុខវិជ្ជា។

**៦.ការអភិវឌ្ឍខ្លួនឯងនិងអង្គភាព** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ការកសាងវប្បធម៌ការចែករំលែកនិងការចូលរួម ការធ្វើស្វ័យវង្វាយតម្លៃជាប្រចាំ ការបន្តអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈខ្លួនឯងជាប្រចាំ ការបន្តអភិវឌ្ឍន៍សមត្ថភាពអង្គភាព ការច្នៃប្រឌិតនិងបង្កើតថ្មីដើម្បីឧត្តមភាពការងារ។

**៧.ការគ្រប់គ្រងសាលារៀន** ការរៀបចំរចនាសម្ព័ន្ធនិងបំណែងចែកភារកិច្ច ការអនុវត្តផែនការអភិវឌ្ឍសាលារៀន ការកៀរគរនិងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ធនធានសម្ភារៈនិងធនធានមនុស្ស ការរៀបចំសេវាគ្រូបង្រៀននិងបុគ្គលិកអប់រំបានសមស្រប ការធានាសុវត្ថិភាពចំណីអាហារនិងសណ្តាប់ធ្នាប់ការលក់ដូរក្នុងសាលារៀន សាលារៀនអនុវត្តតាមគោលការណ៍ប្រតិបត្តិស្តង់ដាSOP ការរៀបចំបរិស្ថានសាលារៀននិងឯកសណ្ឋានគ្រូបង្រៀននិងសិស្ស ការធានាសុវត្ថិភាពគ្រូបង្រៀន បុគ្គលិកអប់រំ និងសិស្សានុសិស្ស។

**៨.ការជានាគណនេយ្យភាព** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ការពង្រឹងអភិបាលកិច្ចល្អ ការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និងទ្រព្យសម្បត្តិរដ្ឋ ការឆ្លើយតបព័ត៌មាននិងដោះស្រាយបញ្ហាទាន់ពេលវេលា ការប្រមូលនិងប្រើប្រាស់ទិន្នន័យដើម្បីវិភាគពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់សាលារៀន ការផ្តួចផ្តើមអភិវឌ្ឍន៍នូវក្រមចំណាយដោយផ្អែកទៅលើលទ្ធផលបំពេញការងារ បិតផ្សាយលទ្ធផលសិក្សារបស់សិស្សប្រកបដោយតម្លាភាព ការបិទផ្សាយតារាងតម្លាភាពហិរញ្ញវត្ថុ សម្ភារៈទ្រព្យសម្បត្តិនិងបុគ្គលិកអប់រំ។

**៩.ការពង្រឹងទំនាក់ទំនងជាមួយសហគមន៍និងអាជ្ញាធរដែនដី** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ ការបង្កើតនិងរក្សាស្នាដៃសិស្សដើម្បីជំរុញមាតាបិតា អ្នកអាណាព្យាបាលសិស្ស និងសហគមន៍ឱ្យចូលរួមឧបត្ថម្ភគាំទ្រ ការបង្កើតមូលនិធិសមធម៌អប់រំ តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន ការគោរពវិន័យការងារ ការទទួលខុសត្រូវនិងការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ មានសីលធម៌នៅល្អ សាមគ្គីភាពល្អ គុណធម៌និងយុត្តិធម៌ ការប្រាស្រ័យទាក់ទងល្អនិងការផ្តល់ព័ត៌មានត្រឡប់ដល់សិស្ស គ្រូបង្រៀន មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរដែនដី ការចូលរួមសកម្មភាពនានាក្នុងសង្គម។

**១០.លទ្ធផលគ្រប់គ្រង** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ គ្រូបង្រៀនយល់ដឹងពីកម្មវិធីសិក្សាតាមកម្រិតថ្នាក់ គ្រូបង្រៀនមានសមត្ថភាពលើវិធីសាស្ត្រនិងបច្ចេកទេសបង្រៀននិងរៀនតាមមុខវិជ្ជាបានត្រឹមត្រូវ អត្រាសិស្សបោះបង់ការសិក្សាទាបជាងឬស្មើថ្នាក់ជាតិ អត្រាសិស្សឡើងថ្នាក់ស្មើឬខ្ពស់ជាងថ្នាក់ជាតិ សិស្សមានសមត្ថភាពសមស្របនឹងកម្រិតថ្នាក់ បរិស្ថានសិក្សាមេត្រី ផ្គត់ផ្គង់ គ្រប់គ្រងនិងថែរក្សាសៀវភៅសិក្សាគោល។

**១១.ការអភិវឌ្ឍយុវជន** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ មានរចនាសម្ព័ន្ធនិងដំណើរការក្រុមប្រឹក្សាកុមារ/យុវជន មានក្លឹបសិក្សាមួយយ៉ាងតិច ក្នុងមួយកងកាយរឹទ្ធិ ដឹកនាំសម្របសម្រួលនិងចូលរួមសកម្មភាពនានាក្នុងការងារសង្គម សកម្មភាពក្នុងការបណ្តុះបណ្តាលកុមារ/យុវជន បូកសរុបនិងវាយតម្លៃលទ្ធផលការងារក្រុមប្រឹក្សាកុមារ/យុវជន។

សាលារៀនមានដំណើរការទៅបានដោយរលូន ត្រូវពឹងផ្អែកទៅលើគណៈគ្រប់គ្រងសាលារៀន ហើយក៏ត្រូវមានការគាំទ្រពីភាគីពាក់ព័ន្ធផងដែរ។ គណៈគ្រប់គ្រងសាលារៀនត្រូវមានគម្រោង និងផែនការមួយច្បាស់លាស់ ដើម្បីសម្រេចតាមការគ្រោងទុក។ ជាពិសេស ដើរឱ្យស្របជាមួយនិងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងគោលនយោបាយរបស់ក្រសួងអប់រំ ដែលជាការឆ្លើយតមក្នុងការអភិវឌ្ឍធនធានមនុស្ស។ ដើម្បីសម្រេចផែនការបាន គណៈគ្រប់គ្រងសាលារៀនត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ សមត្ថភាព ភាពច្នៃប្រឌិតខ្ពស់ និងការប្រាស្រ័យទាក់ទងល្អសម្រាប់ផ្តល់សេវាអប់រំ ប្រកបដោយគុណភាព និងភាពឆ្លើយតបរបស់សហគមន៍។

**២.២.២ កត្តាសហគមន៍**

ការចូលរួមរបស់សហគមន៍ ក្នុងការគ្រប់គ្រងសាលារៀនដែលមានសក្តានុពលខ្លាំងសម្រាប់ការលុបបំបាត់ការមិនទុកចិត្តរវាងសហគមន៍និងសាលារៀន ដោយការបណ្តុះនូវតម្លាភាពនៃព័ត៌មាន និងវប្បធម៌នៃការគោរពគ្នាទៅវិញទៅមក និងដោយការរួមគ្នាបន្តការកែលម្អសាលារៀនដោយការចែករំលែកចក្ខុវិស័យ ដំណើរការ និងលទ្ធផល ការផ្លាស់ប្តូរឥរិយាបទបុគ្គល និងអង្គការគឺមានសារៈសំខាន់ក្នុងការបង្កើនកម្រិតនៃការចូលរួម (Nishimura, 2017)។ នៅក្នុងប្រទេសដែលរចនាសម្ព័ន្ធរដ្ឋបាលមានភាពទន់ខ្សោយ វិធីសាស្ត្រខាងក្រោមដើម្បីពង្រីកឱកាសអប់រំ និងការរៀនសូត្រប្រកបដោយគុណភាពអាចជាជម្រើសតែមួយគត់។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលការចូលរួមរបស់សហគមន៍ត្រូវបានអនុវត្តដោយវិធីពីលើចុះក្រោម ដោយគ្មានការពិគ្រោះយោបល់ទូលំទូលាយលើគោលបំណង ដំណើរការ និងលទ្ធផលរំពឹងទុក ផលវិបាកទំនងជាមានជម្លោះរវាងតួអង្គ អារម្មណ៍ខ្លាំងនៃកាតព្វកិច្ចដ៏លើសលប់ អស់កម្លាំង និចលភាព និងភាពខុសគ្នានៅក្នុងកម្រិតនិងលទ្ធផលនៃការចូលរួមសហគមន៍ ដែលជាគម្លាតរវាងសហគមន៍និងសាលារៀន។ ទិដ្ឋភាពនយោបាយនៃការគ្រប់គ្រងសាលារៀន និងភាពខុសគ្នានៃវប្បធម៌សង្គមក្នុងចំណោមប្រជាជនទាមទារឱ្យមានការប្រុងប្រយ័ត្ន ព្រោះថាពួកគេទំនងជាជំរុញឱ្យមានការចូលរួមដោយផ្នែក ឬការមិនចូលរួមពីសហគមន៍ទាំងមូល (Mikiko, 2017)។

សហគមន៍អាចលើកកម្ពស់ការរួបរួមសង្គម នៅក្នុងសាលារៀនតាមរយៈការកែទម្រង់ផ្សេងៗ នៃការសហការនៅក្នុងខ្លួន ប៉ុន្តែអាចដកចេញ ឬប្រកួតប្រជែងជាមួយអ្នកដទៃលើធនធានដែលមាន។ ធនធានទាំងនោះរួមមាន ការបែងចែកធនធានហិរញ្ញវត្ថុសាធារណៈ ឬឯកជនដល់សាលារៀន ជំនួយពីម្ចាស់ជំនួយ និងការទទួលបានធនធាន ដូច្នេះការប្រើពាក្យថា ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀនទាមទារឱ្យមានការប្រុងប្រយ័ត្ន ចំពោះអ្វីដែលយើងមានន័យដោយសហគមន៍ និងការពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីបរិបទសង្គម (ក្រសួងអប់រំ យុវជន និងកីឡា, ២០១០)។ នៅក្នុងន័យគំនិតកាន់តែច្រើន មានភូមិសាស្ត្រ វប្បធម៌ និងសហគមន៍ (ឬមុខងារ)។ សហគមន៍ភូមិសាស្ត្រ គឺជាក្រុមមនុស្សដែលរស់នៅក្នុងព្រំដែនភូមិសាស្ត្រដូចគ្នា។ សហគមន៍វប្បធម៌ មានន័យថាក្រុមមនុស្សដែលមានប្រវត្តិជនជាតិភាគតិច ភាសា និង ឬសាសនាដូចគ្នា ដែលចែករំលែកបទដ្ឋាន និងការអនុវត្តទូទៅ។ ជាចុងក្រោយ សហគមន៍សាលារៀនបង្ហាញពីក្រុមមនុស្សដែលប្រមូលផ្តុំ និងធ្វើការក្នុងគោលបំណងនៃការគ្រប់គ្រងសាលារៀន ដោយមិនគិតពីទីតាំងភូមិសាស្ត្រ ឬប្រវត្តិវប្បធម៌របស់ពួកគេ។ សហគមន៍សាលារៀនអាចឬមិនរួមបញ្ចូលនូវភាពចម្រុះនៅក្នុងសាវតាសេដ្ឋកិច្ចសង្គម និងវប្បធម៌នៃសមាជិករបស់ខ្លួន សន្មតថាមុខងារសហគមន៍ជានិយមន័យប្រតិបត្តិការនៃការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន។

នៅក្នុងបរិបទសង្គម និងស្ថាប័នផ្សេងៗគ្នានៃប្រព័ន្ធអប់រំប៉ះពាល់ដល់លទ្ធផលនៃការចូលរួមរបស់សហគមន៍ខុសៗគ្នា ជាពិសេសនៅក្នុងតួនាទី និងទំនួលខុសត្រូវរបស់ពួកគេ កម្រិតនៃការចូលរួម តំណាងនៃសមាជិកសហគមន៍នៅក្នុងអង្គភាពគ្រប់គ្រងសាលា និងលទ្ធផលនៃការសិក្សារបស់សិស្ស និងដំណើរជីវិត(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ ដូចដែលបានបង្ហាញការកើនឡើងនាពេលថ្មីៗ នេះនៃវិមជ្ឈការបានបង្វែរអំណាច នៃការសម្រេចចិត្តទៅកម្រិតសហគមន៍ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងប្រទេសមួយចំនួន អំណាចជាក់ស្តែងដែលផ្តល់ដល់សហគមន៍មានកម្រិតស្មើភាព ដោយសារធនធានខ្វះខាតនៅកម្រិតសហគមន៍ និងការពឹងផ្អែកខ្ពស់លើគោលការណ៍ណែនាំការប្រើប្រាស់ជំនួយ ដែលបានបែងចែកសាលារៀនដោយរដ្ឋាភិបាល។ នៅក្នុងប្រទេសផ្សេងទៀត ជាកន្លែងដែលការចូលរួមរបស់សហគមន៍មានប្រវត្តិយូរអង្វែង ក្នុងការផ្តល់សំណាងសម្រាប់ការគ្រប់គ្រងនៃ

សាលារដ្ឋាភិបាល សហគមន៍បានចូលរួមយ៉ាងសកម្មក្នុងការជួលគ្រូបង្រៀនដោយខ្លួនឯង និងរួមចំណែកដល់សាលារៀនក្នុងទម្រង់ផ្សេងៗ។ ក្នុងករណីចុងក្រោយ ការត្រួតពិនិត្យវត្តមានរបស់សិស្ស និងគ្រូបង្រៀន ការសាងសង់ថ្នាក់រៀន និងបង្គន់អនាម័យ និងការរួមចំណែកផ្នែកហិរញ្ញវត្ថុដល់អាហារូបករណ៍សម្រាប់សិស្ស ដែលមកពីមជ្ឈដ្ឋានជួបការលំបាកទំនងជាស្ថិតនៅក្នុងដៃរបស់សមាជិកសហគមន៍។ ជាមួយនឹងការទទួលស្គាល់ថាមានវិធីផ្សេងៗគ្នា នៃការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀនក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងសៀវភៅដែលក៏បានរំលេចផងដែរថា ពិនិត្យមើលថាតើសហគមន៍បានចូលរួមក្នុងការគ្រប់គ្រងសាលារៀន ក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍន៍យ៉ាងដូចម្តេច និងរបៀបដែលការសិក្សាដែលមានស្រាប់បានចងក្រងឯកសារ បាតុភូតដោយយោងទៅលើបញ្ហាប្រឈម ឧបសគ្គ និងលទ្ធភាពជាក់ស្តែង។ ក្របខណ្ឌគំនិតនៃការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន បង្ហាញពីក្របខណ្ឌវិភាគនៃការចូលរួមរបស់សហគមន៍ រួមទាំងតួនាទីជាប្រវត្តិសាស្ត្ររបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ទ្រឹស្តីគ្រប់គ្រងសាលារៀន និងប្រភេទ និងកម្រិតនៃការចូលរួម។ ជាក់ស្តែងអំពីផលប៉ះពាល់នៃការចូលរួមរបស់សហគមន៍លើលទ្ធភាពទទួលបាន និងគុណភាពនៃការរៀនសូត្រនៅក្នុងសាលារៀនព្រមទាំងឧបសគ្គ និងកត្តាជំរុញឱ្យការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន។

ការចូលរួមរបស់សហគមន៍ គឺជាពាក្យដែលប្រើញឹកញាប់ និងត្រូវបានលើកឡើងជាញឹកញាប់នៅក្នុងការអភិវឌ្ឍន៍ការអប់រំអន្តរជាតិ។ នៅក្នុងអត្ថបទ Jennifer Swift-Morgan ( 2006 ) ត្រូវបានកំណត់ថាជាការចូលរួមរបស់សហគមន៍គឺជាការរួមចំណែករូបិយវត្ថុ ជាជាងការចូលរួមក្នុងការសម្រេចចិត្ត ឬការបង្រៀន និងការរៀន។ Swift-Morgan ក៏បង្ហាញផងដែរថាមានបញ្ហាប្រឈមពិសេសសម្រាប់ការចូលរួមរបស់ស្ត្រី និងជនក្រីក្រ ហើយការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសដែលលើកទឹកចិត្តដល់ការសម្រេចចិត្តដែលមានមូលដ្ឋានទូលំទូលាយបង្កើតការលើកទឹកចិត្ត សម្រាប់ការចូលរួមសហគមន៍កាន់តែទូលំទូលាយ។

ការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការសម្រេចត្រង់ចំណុចដៅ នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ដើម្បីឆ្លើយតបនឹងអាទិភាពនៃកាអភិវឌ្ឍប្រទេស តាមរយៈការដាក់ចេញនូវក្របខណ្ឌរួម និង

អភិក្រមរយៈពេលវែងត្រូវអនុវត្តទូទាំងវិស័យសម្រាប់អភិវឌ្ឍវិស័យអប់រំ និងផ្តល់សេវាអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ នៅក្នុងរបាយការណ៍របស់ ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) បានលើកឡើងថា សហគមន៍មានតួនាទីយ៉ាងសំខាន់ក្នុងការជួយអភិវឌ្ឍន៍សាលារៀន និងជួយអនុវត្តន៍នូវកម្មវិធីកំណែទម្រង់វិស័យអប់រំយ៉ាងមានប្រសិទ្ធភាព និងសក្តានុពល។ ជាអាទិ៍សហគមន៍ជាអ្នកចូលរួម និងធ្វើកិច្ចការងារយ៉ាងសកម្មដើម្បីបំរើដល់វិស័យអប់រំ ដោយពួកគាត់មិនទាមទារនូវប្រាក់កម្រៃ ផ្ទុយមកវិញពួកគាត់ថែមទាំងបានបរិច្ចាកថវិកាផ្ទាល់ខ្លួនដើម្បីអភិវឌ្ឍសាលារៀនទៀតផង។ តាមការចោទឡើងរបស់សហគមន៍ដែលពួកគេត្រូវការគឺ សិស្ស គ្រួសារសិស្ស និងសហគមន៍ទាំងមូលត្រូវការនូវសមត្ថភាពរស់នៅជាមួយជីវិតរីករាយ សមត្ថភាពចាកចេញពីភាពក្រីក្រដោយសារការបង្កើតនិងប្រើគំនិតមួយ គុណភាពសិក្សានិងលទ្ធផលសិក្សាសិស្សត្រូវតែមានកម្រិតល្អនិងល្អប្រសើរ រៀនចប់និងត្រូវមានសមត្ថភាពឆ្លើយតបតម្រូវការទីផ្សារការងារ យុវជនត្រូវក្លាយខ្លួនជាពលរដ្ឋពេញលេញ ឬពលរដ្ឋសកល គ្រូទាំងអស់ត្រូវបាននូវការបណ្តុះបណ្តាលពេញមួយជីវិត (កម្មវិធីលើកកម្ពស់គុណវុឌ្ឍិ និងកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងរយៈពេលវែង) សហគមន៍ត្រូវទទួលបាននូវគ្រូបង្រៀនមានគុណភាព ដែលអាចប្រើយុទ្ធសាស្ត្របង្រៀនដោយប្រាកដថាអាចជួយសិស្សបាន សាលាសម្ព័ន្ធត្រូវរឹងមាំ ដោយគ្រូពីសាលាមានស្តង់ដាត្រូវជួយគ្រូនៅសាលាមិនទាន់មានស្តង់ដា គុណភាពសិស្សត្រូវមានកម្រិតដូចគ្នាទៅនឹងសិស្សនៅក្នុងតំបន់អាស៊ី ធនធានដែលជាធាតុចូលត្រូវមានលក្ខណៈដូចគ្នា ការជួយសិស្សរៀនយឺតត្រូវតែផ្តោតលើសិស្សម្នាក់ៗ និងជួយឱ្យបានគ្រប់គ្នាដើម្បីរក្សានូវការសន្យានៃពាក្យសមធម៌ បរិយាប័ន្ន និងយុត្តិធម៌សម្រាប់សិស្ស (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១)។ តួយ៉ាងក្នុងការផ្សព្វផ្សាយ តាក់តែងសៀវភៅប្រតិបត្តិសហគមន៍សាលារៀន ក៏គេសង្កេតឃើញថាមានចំណុចវិជ្ជមាន និងចំណុចដែលជាបញ្ហាប្រឈមមួយចំនួន ដែលមិនអាចគេចផុតបានឡើយ។

តួនាទីរបស់សហគមន៍ជារឿយៗសង្កត់ធ្ងន់លើអត្ថប្រយោជន៍របស់ការអប់រំ ជាមធ្យោបាយមួយដើម្បីបំពេញគម្លាតហិរញ្ញវត្ថុដែលបន្សល់ទុកដោយរដ្ឋាភិបាល នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន សហគមន៍ជាប្រវត្តិសាស្ត្របានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការអប់រំ (Somerset, A., 2009)។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) បានលើឡើងថា សហគមន៍មានតួនាទីដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសលារៀន ទំនាក់ទំនងល្អរវាងសាលារៀននិងសហគមន៍ជាកត្តាចាំបាច់មិនអាចខ្វះបាន។ ប្រការនេះជាកម្លាំងចលករនិងជាប្រភពមិនចេះរីងស្ងួត ក្នុងការលើកកម្ពស់គុណភាពបង្រៀន រៀន និងលទ្ធផលសិក្សារបស់សិស្ស តាមរយៈការចូលរួមរៀបចំផែនការ ស្វែងរកធនធាន និងការពិនិត្យតាមដានវឌ្ឍនភាពក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំឱ្យមានជីវិតស្រស់បំព្រង ប្រកបដោយសុខដុមនីយកម្ម។

**ក.អាជ្ញាធរដែនដី**

- ការបង្កើនទំនាក់ទំនងជិតស្និទ្ធ និងយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធនានា ដើម្បីអភិវឌ្ឍន៍សាលារៀន
- ការដឹកនាំនិងសម្របសម្រួល ការកៀរគរធនធានពីប្រភពផ្សេងៗដើម្បីអភិវឌ្ឍន៍សាលារៀន
- ការពង្រឹងការគ្រប់គ្រង និងដឹកនាំដោយបង្ហាញឱ្យឃើញច្បាស់អំពីផែនការទទួលខុសត្រូវខ្ពស់តម្លាភាពនិងមិនប្រកាន់បក្សពួក
- ការកសាងទំនុកចិត្ត ដោយខិតខំបង្កើនសមិទ្ធផល លទ្ធផលសិក្សាល្អ គោរពឆន្ទៈរួម មានការលះបង់ មានចក្ខុវិស័យ បេសកកម្ម រចនាសម្ព័ន្ធច្បាស់លាស់ (ក្រសួងអប់រំ យុវជន និងកីឡា , ២០១៧)។

**ខ.មាតាបិតា**

- ការបង្កើតទំនាក់ទំនងល្អ ជាមួយមាតាបិតាសិស្ស ក្នុងការប្រមូលកុមារចូលរៀន និងលទ្ធផលសិក្សា
- ការពន្យល់ពីតម្លៃនៃការអប់រំដល់មាតាបិតាសិស្ស
- ការផ្សព្វផ្សាយរាល់សមិទ្ធផលការងាររបស់សាលាដែលសហគមន៍បានចូលរួមអភិវឌ្ឍន៍ (ក្រសួងអប់រំ យុវជន និងកីឡា ,២០១៧)។

**គ. ភាគីពាក់ព័ន្ធ**

- ការកសាងបណ្ដាញទំនាក់ទំនងជាមួយអ្នកឯកទេស និងអ្នកជំនាញលើគ្រប់វិស័យ ដើម្បីចូលរួមអភិវឌ្ឍន៍ការអប់រំ ក្នុងនោះមានវិស័យការងារ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ វិស័យសុខាភិបាល វិស័យកសិកម្ម វិស័យឧស្សាហកម្ម សិប្បកម្ម សុវត្ថិភាពចរាចរណ៍ វិស័យវប្បធម៌ ទេសចរណ៍ ព័ត៌មាន និងសាសនា
- ការបង្កលក្ខណៈងាយស្រួលដល់អ្នកពាក់ព័ន្ធចូលរួម ដោយផ្ដល់ការគាំទ្រ ការផ្ដល់កិត្តិយស និងការផ្ដល់ឱកាសចូលរួមក្នុងសកម្មភាពនានា
- ការស្ដាប់និងទទួលយកនូវគំនិត ឬយោបល់រិះគន់ដើម្បីស្ថាបនាពីសហគមន៍និងភាគីពាក់ព័ន្ធ (ក្រសួងអប់រំ យុវជន និងកីឡា ,២០១៧)។

មាតាបិតា អ្នកអាណាព្យាបាលសិស្សមានការរំពឹងទុកកាន់តែខ្ពស់អំពីលទ្ធផលនៃការអប់រំ និងនិយោជកតម្រូវឱ្យយុវជនកម្ពុជាមានសមត្ថភាពភាពគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនានាក្នុងសតវត្សទី២១ និងបដិវត្តន៍ឧស្សាហកម្ម ៤.០។ ការអប់រំបំពេញតួនាទីដ៏សំខាន់ ក្នុងដំណើរផ្លូវឆ្ពោះទៅសម្រេចកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិរបស់ប្រទេសទាំងអស់ ហើយនៅក្នុងយុគ្គសម័យសេដ្ឋកិច្ចសកលបច្ចុប្បន្នជោគជ័យរបស់ជាតិមួយពឹងអាស្រ័យយ៉ាងខ្លាំង លើចំណេះដឹង ជំនាញ និងសមត្ថភាពពលរដ្ឋរបស់ខ្លួន (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១)។

សហគមន៍អនុវត្តសកម្មភាពដែលមានការឯកភាពនៅក្នុងផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ឬដោយមានការប្ដេជ្ញាចិត្តពីសហគមន៍(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ តួនាទី និងភារកិច្ចរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនរួមមាន៖

១. **តួនាទីរបស់សហគមន៍** ជាគណៈកម្មការសាងសង់ និងឧបត្ថម្ភគាំទ្រសាលារៀន។ សហគមន៍សំដៅទៅលើ មាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងសហគមន៍ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។ ការចូលរួមក្នុងការគ្រប់គ្រង ការអនុវត្តការងាររបស់មន្ត្រី និងការពិនិត្យតាមដាន ដែលសហគមន៍អាចពិនិត្យតាមដានម៉ោងបង្រៀន ដូចជាអវត្តមានគ្រូបង្រៀន សិស្សអវត្តមាន ថ្នាក់រៀនបើក

យឺត ឬបិតមុនម៉ោង និងសាលារៀនបើក បិតមិនខុសប្រតិទិនសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

២. **ភារកិច្ចរបស់សហគមន៍** គឺ ប្រមូលកុមារឲ្យចូលរៀនស្វែងរកចំណូលថវិកា គ្រប់គ្រងថវិកា ថែរក្សាទ្រព្យសម្បត្តិសាលារៀន ចូលរួមសាងសង់ ជួសជុលសាលារៀន បំផុសកូនចៅឲ្យទៅសាលារៀន តាមដានការសិក្សារៀនសូត្ររបស់សិស្ស ក្នុងការចូលរួមតាមដានត្រួតពិនិត្យការអនុវត្តរបស់សាលារៀន ពង្រឹងពង្រីកសមត្ថភាពយល់ដឹងអំពីអភិវឌ្ឍសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

**ក. ការប្រមូលកុមារឲ្យចូលរៀនៈ**

- គ្រួសារនីមួយៗត្រូវជួយរំឭកគ្នា ដោយឲ្យកូនចៅដែលដល់អាយុសិក្សាទៅសាលារៀនបានទៀងទាត់ (មត្តេយ្យ ថ្នាក់ដំបូង បឋមសិក្សា)
- ប្រមូលកុមារដែលនៅក្រៅសាលារៀន និងជួយទំនាក់ទំនងជាមួយឪពុកម្ដាយ ដែលមិនបានឲ្យកូនចៅទៅរៀនដើម្បីបានទៅរៀន
- ជួយប្រមូល និងជួយបង្កលក្ខណៈងាយស្រួលដើម្បីឲ្យកុមារទីទ័លក្រពិការបានទៅរៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

**ខ. ការស្វែងរកចំណូលថវិកា និងគ្រប់គ្រងថវិកា**

សាលារៀនដំណើរការបានល្អ គឺអាស្រ័យដោយមានថវិកាទ្រទ្រង់ ។ សហគមន៍ត្រូវចូលរួមយ៉ាងសកម្មក្នុងការស្វែងរកថវិកាសម្រាប់ឧបត្ថម្ភសាលារៀន។ ការស្វែងថវិកាអាចធ្វើទៅបានតាមរយៈច្រើនរូបភាពៈ

- បុណ្យផ្សេងៗ (រស្មីសាមគ្គីជាតិ ផ្កា កំសាន្តផ្សេងៗ អង្គាសបច្ច័យ កឋិនទាន-ល-)
- ស៊ីវិភាគទាន ជាស្រូវ សម្ភារផ្សេងៗ ការប្រើទុន ឬទុនបង្វិលដោយទំនាក់ទំនង ជាមួយសប្បុរសជន ( គណៈកម្មការ អាចារ្យវត្ត មាតាបិតាសិស្សអ្នកមានទ្រព្យសម្បត្តិក្នុង និងក្រៅប្រទេស សហគមន៍ឯកជន ដូចជា ក្រុមហ៊ុនផ្សេងៗ និងទំនាក់ទំនងជាមួយរដ្ឋអំណាច....) និងតាមរយៈសកម្មភាពផ្សេងៗដូចជាបង្កើតកន្លែងរមណីយដ្ឋាន ទេសចរណ៍ ធ្វើសិប្បកម្ម សកម្មភាពសិល្បៈ និងទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងក្រៅរដ្ឋាភិបាល (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

## គ. គ្រប់គ្រងថវិកា

- ថវិកាចំណូលត្រូវមានបញ្ជីកត់ច្បាស់លាស់ ដោយមានបញ្ជាក់នូវប្រាក់ចំណូល កាលបរិច្ឆេទទទួល ចំនួនថវិកាឈ្មោះអ្នកទទួល ឈ្មោះអ្នកជឹងៗ -ល-។
- បញ្ជីចំណាយត្រូវមានបញ្ជាក់ប្រភេទចំណាយចំនួនទឹកប្រាក់ កាលបរិច្ឆេទ និងភ្ជាប់ជាមួយនូវកំណត់ហេតុដែលអង្គប្រជុំបានសម្រេចឲ្យចំណាយ។
- ថវិកាត្រូវថែរក្សា និងគ្រប់គ្រងដោយបុគ្គលស្មោះត្រង់ដែលជ្រើសរើសដោយសហគមន៍ដែលជាបុគ្គលមានស្មារតី និងស្រឡាញ់ការអប់រំ។
- ចំណូល និងចំណាយត្រូវផ្សព្វផ្សាយឲ្យគណៈកម្មការសហគមន៍ ឬសហគមន៍ជឹងៗ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

## ឃ. ថែរក្សាសម្បត្តិសាលារៀន

- សហគមន៍ត្រូវចាត់ទុកសាលារៀនជាទ្រព្យសម្បត្តិរួម។
- សហគមន៍ត្រូវគ្រប់គ្រងសត្វពាហនៈកុំឲ្យចូលក្នុងសាលារៀន។
- ជួយថែរក្សា ការពារយាមកាមទ្រព្យសម្បត្តិសាលារៀន និងជួសជុល។
- តាមដានមើល ជួយថែរក្សាសម្ភារៈសិក្សារបស់កូនចៅដែលសាលាបានខ្ចី សម្រាប់ការរៀនសូត្រដូចជាសៀវភៅសិក្សាជាដើម។
- ថែរក្សាទ្រព្យសម្បត្តិដែលសាលារៀនបានឲ្យខ្ចីក្នុងពេលមានរវល់ដូចជា តុ កៅអី ពេលបុណ្យទាន
- អគារសិក្សាថ្នាក់រៀន បន្ទប់ពិសោធន៍ រោងជាង សំណង់អនាម័យទឹកស្អាត ការិយាល័យ និងឧបករណ៍ប្រើប្រាស់ ព្រមទាំងអគ្គីសនីនិងឧបករណ៍ ជាដើម។
- សហគមន៍អាចផ្តល់ព័ត៌មានដល់នាយកសាលាគ្រប់ពេលនៅពេលណាឃើញថា អគារណាមួយត្រូវការជួសជុលតូច (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

ង. ចូលរួមសាងសង់ ជួសជុលសាលារៀន

- សហគមន៍ជាកម្លាំងមិនចេះរីងស្ងួត
- សហគមន៍ចូលរួមជួយឧបត្ថម្ភ មជ្ឈមណ្ឌលធនធាន កម្រងសាលា និងប្រើប្រាស់តាមសេចក្តីត្រូវការដើម្បីពង្រីកចំណេះដឹងរបស់គេ និងជួយដល់ការរៀនសូត្ររបស់កូនចៅពួកគេ
- សហគមន៍ចូលរួមតាមកម្លាំងចិត្ត និងកម្លាំងកាយ ( បំផុសគំនិតបងប្អូនកូនចៅដែលមានជំនាញខាងសំណង់ឲ្យចូលរួមធ្វើជាង បំផុសបងប្អូនដែលគ្មានជំនាញឲ្យចូលរួមជាពលកម្ម ក្នុងការដឹកជញ្ជូនថ្ម ខ្សាច់ ដែក និងសម្ភារៈសំណង់ផ្សេងៗ
- សហគមន៍ចូលរួមតាមរយៈសម្ភារៈរួមមានការចូលរួមជួយឧបត្ថម្ភផ្តល់ថវិកា ដែលបានមកពីសកម្មភាពផ្សេងៗ ចូលរួមជាសម្ភារៈផ្សេងៗ ដូចជាខ្សាច់ដែលជាសម្ភារៈមាននៅមូលដ្ឋាន
- ជួយថែរក្សាសម្ភារៈសំណង់ទាំងអស់ដែលត្រូវដឹកនាំមកដល់ទីកន្លែងសាងសង់
- ជួយកែលម្អបរិស្ថានសាលារៀន
- គណៈគ្រប់គ្រងសាលារៀនសម្រេចចិត្តប្រើប្រាស់ថវិកាសាលារៀនដើម្បី ជួសជុល និងត្រូវអនុវត្តន៍តាមការណែនាំសម្រាប់ការជួសជុល និងការសាងសង់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)

ច. បំផុសកូនចៅឲ្យទៅសាលារៀន

- ជួយរំឭកជាប្រចាំនូវគ្រួសារណាដែលមានកូនដល់អាយុសិក្សាឲ្យទៅសាលារៀន។
- ជួយផ្តល់ព័ត៌មានអំពីកុមារដែលត្រូវចូលរៀន និងចំនួនកុមារដែលនៅសាលារៀន ដោយដោះស្រាយតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាពដើម្បីឲ្យបានទៅសាលារៀន។

សហគមន៍ត្រូវជួយផ្សព្វផ្សាយដល់ប្រជាជនដើម្បី ឲ្យកូនចៅទៅសាលារៀនតាមរយៈមធ្យោបាយផ្សេងៗដូចជា ការប្រជុំ ការជួបគ្នានៅវត្តរៀងរាល់ថ្ងៃសីល ថ្ងៃបុណ្យ ការសំដែងសិល្បៈ ការទស្សនា ការបិទប្រកាស វិទ្យុទូរទស្សន៍ សារព័ត៌មានប្រកាស និងចូលរួមបើកបវេសនកាលរបស់សហគមន៍មាតាបិតាសិស្ស (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

## ធ. តាមដានការសិក្សារៀនសូត្ររបស់សិស្ស

ការអប់រំមិនមែនជាបន្ទុកសាលារៀនតែម្នាក់ឯងទេ ប៉ុន្តែជាការចូលរួមចំណែករបស់សហគមន៍ផងដែរ។ ដូច្នេះមាតាបិតាត្រូវៈ

- ជួយអប់រំកូនបន្ថែម និងជុំវិញឲ្យខិតខំរៀនសូត្រ និងបង្កលក្ខណៈ ទាំងសម្ភារ និងពេលវេលាពិសេសកូនស្រី
- ទំនាក់ទំនងជាមួយលោកគ្រូ/អ្នកគ្រូឲ្យបានញឹកញាប់ដោយផ្ទាល់មាត់ ឬតាមលិខិត និងលោកនាយកសាលារៀន ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងករណីសិស្សបោះបង់ការសិក្សា
- ចូលរួមប្រជុំដើម្បីទទួលព័ត៌មានពីការសិក្សារបស់កូនចៅ
- ជួយផ្តល់មតិយោបល់ ដែលមានប្រយោជន៍ដល់សាលារៀន ជាពិសេសជាមួយគណៈគ្រប់គ្រងសាលារៀន
- ជួយផ្តល់បទពិសោធដល់ការបង្រៀនសិស្ស
- ជួយឧបត្ថម្ភដល់កុមារលំបាក
- ជួយអប់រំផ្លូវចិត្ត អាកប្បកិរិយា និងការអប់រំវិជ្ជាជីវៈដល់កូន
- ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់កូន
- ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់កូន
- ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់កូន
- តាមដានត្រួតពិនិត្យការសិក្សារបស់កូននៅសាលារៀន និងជួយបង្រៀនកូននៅផ្ទះ និង
- ជួយឧបត្ថម្ភ និងផ្តល់នូវមូលដ្ឋានសម្ភារដែលមាននៅក្នុងមូលដ្ឋានដើម្បីបម្រើដល់សកម្មភាពរៀន និងបង្រៀនដល់កុមារ ដូចជា សម្ភារៈសម្រាប់ផលិតសម្ភារៈឧបទេស-ល- (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

## ជ. ចូលរួមកសាង អនុវត្តផែនការ តាមដានត្រួតពិនិត្យការអនុវត្តរបស់សាលារៀន

ដើម្បីឲ្យសាលារៀនទទួលបាននូវការអភិវឌ្ឍទៅមុខជាលំដាប់ រាល់ផែនការការងាររបស់សាលារៀន ត្រូវតែមានការចូលរួមពីសហគមន៍ដែលជាកម្លាំងមិនចេះរីងស្ងួត ដូចជាការចូលរួមកំណត់បញ្ហា កំណត់គោលបំណងសកម្មភាព និងកម្មវិធីផ្សេងៗរួមបញ្ចូលទាំងពេលវេលា។ ការចូលរួមរបស់សហគមន៍ គឺបង្កើតការទុកចិត្តរវាងសហគមន៍ គ្រូបង្រៀន និងសាលារៀន។ ការទុកចិត្តនេះអាចធ្វើឱ្យមានការចូលរួម និងការបរិចាករបស់សហគមន៍ជួយដល់សាលារៀន ហើយសាលារៀន និងគ្រូបង្រៀនត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ និងមាតាបិតាតាមគោលការណ៍គណនេយ្យភាព។

- ចូលរួមចំណែកអនុវត្តផែនការរបស់សាលារៀន និងតាមដានត្រួតពិនិត្យ និងវាយតម្លៃលើសមត្ថភាពសាលារៀន។
- ស្រង់ស្ថិតិ កុមារពីអាយុ០.១៥ ឆ្នាំ ពិសេសកុមារដល់អាយុសិក្សា និងអនក្ខរជន (ព្រោះស្ថិតិ ជាកត្តាមូលដ្ឋានក្នុងការធ្វើ ផែនការអប់រំសហគមន៍)។
- ស្ថិតិកុមារទីទ័ល និងកុមារពិការ។

ការចូលរួមរបស់សហគមន៍ក្នុងសកម្មភាពសាលារៀនមានដូចជា ជួយសិស្សមករៀនទៀងទាត់ គ្រប់គ្រងការសាងសង់សាលារៀន ជាសមាជិកគណៈកម្មការថ្នាក់រៀន ចូលរួមក្នុងការរៀបចំព្រឹត្តិការណ៍ ឬពិធីផ្សេងៗនៅសាលារៀន ជាអ្នកជំនាញបង្ហាញប្រធានបទអ្វីមួយដល់សិស្ស ជួយរកមូលនិធិសាលារៀន សង្កេតសកម្មភាពបង្រៀនក្នុងថ្នាក់ និងតាមដានសិស្សដែលជាកូនរបស់ខ្លួនធ្វើកិច្ចការផ្ទះជាលំហាត់ ឬជាគម្រោងដែលគ្រូដាក់ឱ្យជួយសិស្ស ឱ្យអាន និងសិក្សានៅផ្ទះបានទៀងទាត់ និងថែរក្សាហេដ្ឋារចនា-សម្ព័ន្ធសាលារៀនជាដើម។

ក្នុងគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា (២០១៨) បានលើកឡើងអំពីតម្លាភាពនៃការចូលរួមរបស់សហគមន៍រួមមាន៖

- តម្លាភាពក្នុងការបង្កើតគណៈគ្រប់គ្រងសាលារៀន
- តម្លាភាពក្នុងការធ្វើផែនការសាលារៀននិងការគ្រោងថវិកា និងការរកមូលនិធិ

- តម្លាភាពក្នុងការចំណាយ និងផ្សព្វផ្សាយទិន្នន័យហិរញ្ញវត្ថុ
- តម្លាភាពពីការអនុវត្ត និងប្រតិបត្តិការសាលារៀន
- តម្លាភាពពីលទ្ធផលសិក្សារបស់សិស្ស
- តម្លាភាពក្នុងការបង្កើតគណៈកម្មការសាងសង់ និងជួសជុលសាលារៀន
- តម្លាភាពពីថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិពីការផ្ដល់ធាតុចូលដល់សាលារៀន និងការកសាងសមត្ថភាពសាលារៀន

សហគមន៍ជា កម្លាំងចលករនិងជាប្រភពមិនចេះរីងស្ងួត ក្នុងការលើកកម្ពស់ការអភិវឌ្ឍសាលារៀន គុណភាពបង្រៀនរៀន ការរៀន និងលទ្ធផលសិក្សារបស់សិស្ស តាមរយៈការចូលរួមរៀបចំផែនការ ស្វែងរកធនធាន និងការពិនិត្យតាមដានវឌ្ឍនភាព ក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំឱ្យមានជីវិតស្រស់បំព្រងប្រកបដោយសុខដុមនីយកម្ម ។ សហគមន៍សំដៅទៅលើ មាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងសហគមន៍ ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។ ការចូលរួមក្នុងការគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី និងការពិនិត្យតាមដាន ដែលសហគមន៍អាចពិនិត្យតាមដានម៉ោងបង្រៀន ដូចជាអវត្តមានគ្រូបង្រៀន សិស្សអវត្តមាន ថ្នាក់រៀនបើកយឺត ឬបិតមុនម៉ោង និងសាលារៀនបើក បិតមិនខុសប្រតិទិនសិក្សា។ ជារួមសហគមន៍អាចចូលរួមអភិវឌ្ឍសាលារៀន តាមរយៈចូលរួមជាវិភាគទានដើម្បីទ្រទ្រង់សាលារៀន គំនិតយោបល់ ស្វែងរកដៃគូសម្រាប់ឧបត្ថម្ភចំណូលថវិកា គ្រប់គ្រងថវិកា ថែរក្សាទ្រព្យសម្បត្តិសាលារៀន ចូលរួមសាងសង់ ជួសជុលសាលារៀន បំផុសកូនចៅឲ្យទៅសាលារៀន តាមដានការសិក្សារៀនសូត្ររបស់សិស្ស ចូលរួមតាមដានត្រួតពិនិត្យការអនុវត្តរបស់សាលារៀន ពង្រឹងពង្រីកសមត្ថភាពយល់ដឹងអំពីការអភិវឌ្ឍសាលារៀន។

**២.២.៣ កត្តាសាលារៀន**

ការសិក្សាជាសាកលបង្ហាញថា គុណភាពអប់រំគឺជាកត្តាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ច ក្នុងន័យនេះដើម្បី រួមចំណែកធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន ចាំបាច់ត្រូវលើកកម្ពស់គុណភាពនៃការរៀន និង

បង្រៀន មានន័យថាការចូលរៀននាំឱ្យសិស្សអាចបង្កើនចំណេះដឹង ពោលគឺបើសិស្សរៀនកាន់តែច្រើន នោះសេដ្ឋកិច្ចនឹងរីកចម្រើនកាន់តែឆាប់រហ័ស (Hanushek and Woessman, 2008)។

ពង្រឹងប្រព័ន្ធទំនាក់ទំនង និងសហប្រតិបត្តិការជាមួយសហគមន៍ និងដៃគូអភិវឌ្ឍន៍៖ (១)បញ្ចូលសមាសភាពសហគមន៍នៅក្នុងគណៈកម្មការ និងអនុគណកម្មការនានា និងគ្រប់សកម្មភាពពាក់ព័ន្ធ (២) រៀបចំក្រុមបណ្ដាញដើម្បីផ្សារភ្ជាប់ទំនាក់ទងរវាងសាលារៀន និងគ្រួសារសិស្ស ក្នុងការទទួលខុសត្រូវលើការប្រមូលសិស្សចូលរៀន ការតាមដាន និងជំរុញការសិក្សារបស់សិស្សតាមភូមិ ឬក្រុម (៣)ផ្ដល់ឱកាសឱ្យសហគមន៍ចូលរួមគ្រប់សកម្មភាពរបស់សាលារៀន (បើកបវេសនកាល ការកសាងផែនការ ការអប់រំទូទៅ ការអប់រំបំណិនជីវិត ការផ្លាស់ប្ដូរបទពិសោធន៍ ពិធីបុណ្យឬការតាំងពិព័រណ៍ ក្នុងសាលារៀនឬក្នុងកម្រង) (៤)ផ្ដល់ឱកាសឱ្យសហគមន៍ប្រើប្រាស់ទីតាំងសាលារៀន ដើម្បីធ្វើសកម្មភាព ឬយុទ្ធនាការដែលបម្រើផលប្រយោជន៍របស់សាលារៀន និងសហគមន៍ផ្ទាល់ (៥)ផ្ដល់ឱកាសឱ្យសហគមន៍ចូលរួមកៀងគរសប្បុរសជន ដើម្បីប្រមូលធនធាននានា ជាសម្ភារៈ ថវិកា កសាង ជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងកែលម្អបរិស្ថានសាលារៀន (៦) ផ្ដល់ឱកាសឱ្យសហគមន៍បង្កើតឥណទាននានា ដើម្បីឧបត្ថម្ភគាំទ្ររាល់កង្វះខាត និងការលំបាករបស់សាលារៀន គ្រូបង្រៀន និងសិស្សក្រីក្រ (៧)លើកទឹកចិត្តឱ្យដៃគូអភិវឌ្ឍន៍ដែលធ្វើសកម្មភាពបម្រើឱ្យវិស័យអប់រំ ក្នុងទីតាំងគោលដៅរបស់កម្រង និងពង្រីកសកម្មភាពរបស់ខ្លួននៅទីតាំងផ្សេងទៀត (ក្រសួងអប់រំ យុវជន និងកីឡា, ២០១០)។ ដើម្បីកសាង និងអភិវឌ្ឍធនធាន មនុស្សប្រកបដោយគុណភាព និងគុណធម៌ ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១)។

ក្នុងការអភិវឌ្ឍសាលារៀនមួយប្រកបដោយនិរន្តរភាពបាន ទាមទារឱ្យអ្នកដឹកនាំ គ្រប់គ្រងមានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន ដែលបង្កើនឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដូចជាសិស្សានុសិស្ស គ្រូបង្រៀន ឪពុកម្ដាយ គណៈកម្មការទ្រទ្រង់សាលារៀន អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធជាច្រើនទៀតនៅមូលដ្ឋាន ក្នុងការអនុវត្តសកម្មភាពដោយត្រូវធ្វើ ស្វ័យវាយតម្លៃសាលារៀន ដើម្បីឱ្យដឹងពី

ចំណុចល្អ និងអ្វីត្រូវកែលម្អ រួចធ្វើផែនការអភិវឌ្ឍសាលារៀនដោយផ្អែកលើចំណុចត្រូវកែលម្អ និងធ្វើការពិនិត្យតាមដាន វាយតម្លៃសាលារៀនក្នុងឆ្នាំសិក្សានីមួយៗ ហើយបន្ថែមទៀតនោះដើម្បីរៀបចំផែនការជោគជ័យត្រូវមាន ៖ (១) ការអភិវឌ្ឍសាលារៀន (២)ដំណើរការរៀបចំផែនការអភិវឌ្ឍសាលារៀន (៣) ទម្រង់ផែនការអភិវឌ្ឍសាលារៀន (៤) ការតាមដាន និងវាយតម្លៃផែនការ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។

### ក. ការអភិវឌ្ឍសាលារៀន

ដើម្បីមានការអភិវឌ្ឍសាលារៀនត្រូវមានការសហការ និងការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ តាមសៀវភៅការរៀបចំផែនការអភិវឌ្ឍសាលារៀន បានលើកឡើងថា (២០១៧) ដើម្បីសម្រេចកិច្ចការនេះ ឃុំសង្កាត់ធ្វើការជាមួយស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងឃុំសង្កាត់ រួមទាំងសាលារៀន ដើម្បីកំណត់កិច្ចការសំខាន់ៗ សម្រាប់អនុវត្តរួមគ្នា និងធ្វើការអភិវឌ្ឍសាលារៀន ឬផ្នែកផ្សេងៗទៀតក្នុងឃុំសង្កាត់ និងការអភិវឌ្ឍឃុំសង្កាត់ទាំងមូល។ ជាមួយគ្នានោះដែរមានកិច្ចការមួយចំនួនដែលសាលារៀន និងស្ថាប័នផ្សេងៗត្រូវម្ចាស់ការដោយខ្លួនឯង គឺការងារបច្ចេកទេស ឬជំនាញសម្រាប់ស្ថាប័ន។ ក្នុងនោះផងដែរសាលារៀនត្រូវមាន វិធីសាស្ត្របង្រៀន ការវិភាគកម្មវិធីសិក្សាសម្រាប់រៀបចំសកម្មភាពបង្រៀន ការសរសេរតេស្តវាយតម្លៃជាដំណាក់ និងវាយតម្លៃបញ្ចប់ជាដើម។

ការអភិវឌ្ឍសាលារៀន គឺជាយន្តការសម្រាប់អភិវឌ្ឍផែនការអភិវឌ្ឍសាលារៀន ដោយមានការដឹកនាំដោយនាយកសាលារៀន គណៈកម្មការអភិវឌ្ឍសាលារៀន និងគណៈកម្មការប្រតិបត្តិសាលារៀន។ ហើយអ្នកចូលរួមមាន គណៈគ្រប់គ្រងសាលា អាជ្ញាធរដែនដី ប្រធានក្រុម មេភូមិ ក្រុមប្រឹក្សាឃុំ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្រុមប្រឹក្សាយុវជននិងកុមារ សិស្ស និងមាតាបិតាសិស្ស (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។

### ខ. ដំណើរការរៀបចំផែនការអភិវឌ្ឍសាលារៀន

ការកសាងផែនការអភិវឌ្ឍសាលារៀន នឹងត្រូវប្រព្រឹត្តទៅក្នុងរយៈពេលមួយឆ្នាំម្តង គឺចាប់ផ្តើមអនុវត្តនៅដើមឆ្នាំសិក្សានីមួយៗ ដែលមានសមាសភាពចូលរួមពីគណៈគ្រប់គ្រងសាលារៀន គណៈទ្រទ្រង់

សាលារៀន ក្រុមប្រឹក្សាយុវជនកុមារ គ្រូបង្រៀន តំណាងសិស្ស ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ យោងការណែនាំស្តីពី ការរៀបចំផែនការអភិវឌ្ឍសាលារៀន (២០១៧) បានលើកឡើងថា ការអនុវត្តការងារដឹកនាំ គ្រប់គ្រងសាលារៀន ផ្តោតលើលទ្ធផល ដើម្បីធ្វើឱ្យសាលារៀនបង្កើនស្វ័យភាពរបស់ខ្លួន និងមានភាពជាម្ចាស់ រួមទាំងមានជំនាញ និងចំណេះដឹងទូលំទូលាយ ក្នុងការធ្វើឱ្យសាលារៀនទទួលបាននូវការគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ។ម្យ៉ាងទៀតតាមរយៈការបំពេញការងាររបស់ខ្លួន សាលារៀនអាចធ្វើការឆ្លុះបញ្ចាំងទៅលើគោលនយោបាយ សេចក្តីណែនាំ ឬលិខិតបទដ្ឋាននានាដើម្បីប្រាកដថា ការដឹកនាំគ្រប់គ្រងសាលារៀន ស្ថិតនៅកម្រិតណា ហើយអាចឆ្លើយតបទៅនឹងផែនការយុទ្ធសាស្រ្តវិស័យអប់រំរបស់ក្រសួងបានកម្រិតណាដែរ។ លើសពីនេះទៅទៀត ការរៀបចំរចនាសម្ព័ន្ធនេះ គឺរៀបចំឡើងដើម្បីពង្រឹងប្រព័ន្ធធ្វើការងាររួមគ្នា ក្នុងសាលារៀន និងសហគមន៍ដែលអាចអនុវត្តន៍ឱ្យបានទាំងគុណភាព និងប្រសិទ្ធភាព ស្របទៅតាមគោលដៅការអភិវឌ្ឍប្រកបដោយចីរភាព។

**គ. ទម្រង់ផែនការអភិវឌ្ឍសាលារៀន**

ដើម្បីជាជំនួយស្មារតីក្នុងការរៀបចំផែនការអភិវឌ្ឍសាលារៀន និងកំណត់បាននូវសកម្មភាពសំខាន់ៗក្នុងការងាររៀបចំផែនការ និងរៀបចំទៅតាមលំដាប់លំដោយតាមខ្លឹមសារនីមួយៗ ដូចជាការកំណត់បញ្ហាចម្បងៗទាក់ទងទៅនឹងការចូលរៀន គុណភាពសិក្សា ការដឹកនាំគ្រប់គ្រងជាដើម។ មួយវិញទៀត ការរៀបចំឱ្យមានធាតុសំខាន់ដែលសាលារៀនគិតគូរដល់ចក្ខុវិស័យ បេសកកម្ម និងគោលបំណង។ ក្នុងការចូលរៀន គឺជាការចូលរួមគាំទ្រដល់ការប្រមូលសិស្សចូលរៀនរបស់សហគមន៍ អាជ្ញាធរ ដៃគូឪពុកម្តាយ អាណាព្យាបាល ដែលមិនទាន់បានគ្រប់តម្រូវការរបស់សាលារៀន ដូចជា សម្ភារៈគាំទ្រដល់ការធ្វើយុទ្ធនាការ សម្ភារៈសិក្សាជាដើម។

ធានាសង្គតិភាបជាមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍដោយចីរភាព (SDG) ២០៣០ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។

### ឃ. ការតាមដាន និងវាយតម្លៃផែនការ

ការអនុវត្តការវាយតម្លៃផែនការអភិវឌ្ឍសាលារៀន ការវាយតម្លៃត្រូវចលនាធនធានក្នុងសហគមន៍ និងរៀបចំយន្តការតាមដានដោយរៀបចំឱ្យមានការប្រជុំ កំណត់ត្រាកិច្ចប្រជុំ និងប្រព័ន្ធរបាយការណ៍។ ការអនុវត្តការតាមដាន និងវាយតម្លៃលទ្ធផលនៃការអភិវឌ្ឍសាលារៀន គឺដើម្បីពិនិត្យមើលថាការអនុវត្តផែនការមានការរីកចម្រើនកម្រិតណា និងជាការឆ្លុះបញ្ចាំងនូវការសម្រេចវត្ថុបំណងដែលត្រូវបានចែងក្នុងផែនការអភិវឌ្ឍសាលារៀន ព្រមទាំងតាមដាន និងវាយតម្លៃសាលារៀននៅដើមឆ្នាំសិក្សា ចុងឆ្នាំសិក្សា និងនៅក្នុងអំឡុងសាលារៀនក្នុងកម្មវិធីសាលា និងឧបករណ៍ដែលផលជះដល់សាលា។ នៅក្នុងការតាមដាន និងវាយតម្លៃផែនការ ត្រូវមានសកម្មភាពដូចជា ៖

- បង្កើតក្រុមតាមដាន និងវាយតម្លៃការអភិវឌ្ឍសាលារៀន
- ពិនិត្យមើលការសម្រេចបាននូវទិសដៅរបស់សាលារៀន
- កំណត់បាននូវមេរៀនពិសោធន៍ ដែលទទួលបានពីការអនុវត្ត
- កំណត់បានមេរៀនពិសោធន៍ដែលទទួលបានពីការអនុវត្ត
- កំណត់បាននូវបញ្ហាដែលនឹងត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការកសាងផែនការសម្រាប់ឆ្នាំបន្ទាប់
- វាយតម្លៃនូវគ្រប់សកម្មភាពទាំងអស់
- កំណត់ជាមុននូវកាលបរិច្ឆេទនៃការវាយតម្លៃ
- ផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃដល់គ្រប់អ្នកពាក់ព័ន្ធ
- ផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធរួមចំណែកជា មតិយោបល់ អំពីការអនុវត្តផែនការនិងចូលរួមធ្វើកំណែលម្អផែនការទៅអនាគត (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។

### ២.២.៤ កត្តាសិស្ស

សិស្សមានវិន័យ ចង់រៀនសូត្រ ពួកគេនឹងមើលឃើញពីតម្លៃអប់រំទៅអនាគតរបស់ខ្លួន និងការមានអត្តចរិកស្លូតបូត សុភាពរាបសារ ចេះគោរពព្រះពុទ្ធសាសនា ចេះគោរពចាស់ទុំ ដឹងខុសដឹងត្រូវ ដែលខិតខំក្រេបជញ្ជក់យកចំណេះដឹងពីគ្រូ មានបំណិនក្នុងការគិតពិចារណា និងបញ្ចេញទស្សនៈសិក្សាដោយ

សេរី ចេះធ្វើខ្លួនឱ្យមានតម្លៃក្នុងសង្គម ចេះធ្វើការប្រៀបធៀប ដើម្បីអភិវឌ្ឍន៍រាល់កត្តាអសកម្មទាំងឡាយ នឹងឈានទៅដល់គោលដៅមួយ ដែលពួកគេចង់បានប្រកបទៅដោយជោគជ័យយ៉ាងធំធេង (ក្រសួង អប់រំ យុវជន និងកីឡា,២០០៧)។ កាលណាសិស្សានុសិស្ស ពួកគេចេះទប់ស្កាត់នូវភាពពាលាអាវ៉ាសែ ជួយអប់រំមិត្តភក្តិ បង្ហាញផ្លូវ ដើម្បីកែលម្អឱ្យមនុស្សមានតម្លៃ និងចេះប្រើប្រាស់ពេលវេលាដោយយល់ច្បាស់ថា (ពេលវេលាជាមាសប្រាក់) នៃសិស្សរាល់គ្នាដោយមិនបណ្តែតបណ្តោយឱ្យពេលវេលាមានតម្លៃកន្លងហួសទៅ ដោយឥតប្រយោជន៍នោះឡើយ។ ក្នុងកិច្ចអភិវឌ្ឍសហគមន៍ យុវជន គឺជាកត្តាសំខាន់បំផុតដែលត្រូវមានតួនាទីដូចខាងក្រោម ៖

- បង្កឱកាសចូលរួមអភិវឌ្ឍសហគមន៍
- គិតគូរដល់កិច្ចអភិវឌ្ឍសហគមន៍
- រៀបចំខ្លួនត្រៀមដឹកនាំសហគមន៍
- ចូលរួមលុបបំបាត់បាតុភាពអវិជ្ជមានក្នុងសហគមន៍
- រៀបចំខ្លួនធ្វើសមាជិកស្របច្បាប់ និងដ៏ល្អរបស់សហគមន៍
- បង្កើនភាពក្លាហាន និងឆន្ទៈមុះមុត
- បង្កើនសមត្ថភាពផលិតភាព
- ខិតខំរៀនសូត្រស្វែងរកចំណេះដឹង បំណិនប្រសប់ ចំណេះធ្វើ ចេះរួមរស់នៅជាមួយគ្នា និងមានស្មារតីទំនួលខុសត្រូវ ។

**២.២.៥ កត្តាគ្រូ**

គ្រូបង្រៀន ជាគោលដៅចម្បងក្នុងការអប់រំមនុស្ស និងការអភិវឌ្ឍប្រកបដោយយកចិត្តទុកដាក់ និងផ្ទេរចំណេះដឹងទៅដល់សិស្សានុសិស្ស៖

- ការផ្តល់ពុទ្ធិ ចំណេះដឹង ដែលគ្រូបានប្រឹងអស់ពីសមត្ថភាព ចេះពង្រីកបន្ថែម ដោយប្រើបញ្ញាត្រិះរិះពិចារណា និងឱ្យសិស្សមានចំណេះដឹងទូទៅខាងវិទ្យាសាស្ត្របច្ចេកទេស ដើម្បីឱ្យគេប្រកបមុខរបរចិញ្ចឹមជីវិត និងអាចរួមចំណែកបានក្នុងការការពារ និងកសាងប្រទេសជាតិ។

- អប់រំឱ្យស្គាល់តម្លៃ និងសេចក្តីស្រឡាញ់របស់មនុស្ស គឺលើកតម្កើនតម្លៃមនុស្ស សេចក្តីថ្លៃថ្នូរបស់មនុស្ស សេចក្តីស្រឡាញ់របស់មនុស្ស គឺក្នុងបំណងឱ្យគេស្រឡាញ់ចំណេះដឹងវប្បធម៌របស់ខ្លួន។

- អាចប្តូរអាកប្បកិរិយា គឺបង្រៀនឱ្យមនុស្សមានសមត្ថភាពគ្រប់បែបយ៉ាង ដើម្បីប្តូរឥរិយាបថស្របទៅតាមសង្គមកាល និងត្រៀមខ្លួនធ្វើសហប្រតិបត្តិការជាមួយអ្នកដទៃដោយយកចិត្តទុកដាក់។

- មានសមត្ថភាព និងការប៉ិនប្រសប់ គឺបង្រៀនមនុស្សឱ្យមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយជម្លោះនានាដោយអហឹង្សា។ ម្យ៉ាងទៀត គឺចង់ឱ្យមនុស្សចេះវិភាគរកហេតុផល ចំពោះព្រឹត្តិការណ៍ទាំងឡាយដែលកើតមានឡើងចំពោះមុខ ហើយចេះទទួលខុសត្រូវ និងចេះគ្រប់គ្រងស្ថានភាពដ៏លំបាកស្មុគស្មាញ និងចេះតស៊ូអំណត់អត់ធន់គ្រប់បែបយ៉ាង នោះទើបទទួលបានជោគជ័យ (ថៅ ២០០៥)។

- ការជំរុញ និងលើកទឹកចិត្តសិស្ស ដែលពួកគេសម្រេចអ្វីមួយបានលទ្ធផលល្អ។ ណែនាំតម្រង់ទិសឱ្យចេះស្រឡាញ់អនាគតខ្លួនគេ ធ្វើការបំផុសសកម្មភាពដល់សិស្សក្នុងការចូលរួមយ៉ាងសកម្មជាមួយគ្រូ និងចង់រៀនជាមួយគ្រូ ហើយបង្រៀនពួកគេឱ្យមានបំណិនក្នុងការគិត ការស្រាវជ្រាវ ចេះដោះស្រាយបញ្ហាបានដោយខ្លួនគេ។

- ចេះប្រើចិត្តសាស្ត្រគ្រប់បែបយ៉ាង មានសីលធម៌ថ្លៃថ្នូរគួរឱ្យគោរព ដើម្បីការអប់រំមានប្រសិទ្ធភាពដោយប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ (អនុក្រឹត្យលេខ១២៦ អនក្រ.បក ២០០៨ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន មាត្រា៨)។

ដូច្នេះគ្រូអាចធ្វើឱ្យសិស្សជក់ចិត្តជិតអារម្មណ៍ ចង់រៀនសូត្រ ព្រមទាំងមានវិន័យម៉ឺងម៉ាត់ ច្បាស់លាស់ បែបនោះទើបការអប់រំ និងការអភិវឌ្ឍមានប្រសិទ្ធភាព។

យោងតាម ឧបករណ៍វាយតម្លៃគ្រូបង្រៀនល្អ ជាឧបសម្ព័ន្ធទី២ នៃប្រកាសលេខ៧៦១ អ.យ.ក.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ បានចែងអំពីសូចនាករគ្រូបង្រៀនល្អដូចខាងក្រោម៖

**១.គុណវុឌ្ឍិ** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬសញ្ញាបត្រសមមូល សញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រសមមូល សញ្ញាបត្រឬវិញ្ញាបនបត្របណ្តុះបណ្តាលបង្រៀន សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**២.ចំណេះដឹងមូលដ្ឋានផ្នែកព័ត៌មានវិទ្យានិងទូគមនាគមន៍** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ចំណេះដឹងប្រើប្រាស់កុំព្យូទ័រ ការអនុវត្តការបង្រៀនតាមអនឡាញដោយផ្សាយផ្ទាល់ ឬថាក់ផ្សាយក្នុងបណ្ដាញសង្គមនានា ការផ្ដល់វីដេអូការបង្រៀន សន្លឹកកិច្ចការផ្ទះ និងសម្ភារៀនផ្សេងទៀតឬបណ្ដាញទំនាក់ទំនងសង្គមផ្សេងទៀត សមត្ថភាពចូលរួមការប្រជុំ សិក្ខាសាលាឬការបណ្ដុះតាមប្រព័ន្ធអនឡាញឬមានសមត្ថភាពបង្កើតសម្រាប់ការប្រជុំផ្សេងៗ ការរៀបចំបទបង្ហាញនិងបង្រៀនក្នុងថ្នាក់រៀនដោយប្រើឧបករណ៍បច្ចេកវិទ្យា។

**៣.សមត្ថភាពជំនាញ** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ការយល់ដឹងពីគោលនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការដឹកនាំគ្រប់គ្រងសម្របសម្រួលថ្នាក់រៀន និងការលើកទឹកចិត្តសិស្ស សមត្ថភាពជំនាញក្នុងការបង្រៀន ភាសាបរទេស ប្រវត្តិនិងបទពិសោធនៃការបង្រៀនចាប់ពី៥ឆ្នាំឡើងទៅ ជំនាញវិភាគនិងការបកស្រាយព័ត៌មាន ការរៀបចំថ្នាក់បង្ហាញនិងការបង្រៀនថ្នាក់និទស្សន៍។

**៤.ភាពជាអ្នកដឹកនាំនិងគ្រប់គ្រង** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ វិនិច្ឆ័យបានត្រឹមត្រូវ តម្លាភាពនិងយុត្តិធម៌ ការដឹកនាំសិស្សជួយការងារសង្គមនិងសហគមន៍ ការរៀបចំសៀវភៅរដ្ឋបាលថ្នាក់រៀន ការតាមដាននិងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការគ្រប់គ្រងសកម្មភាពរៀននិងបង្រៀន ការផ្ដល់ការទទួលខុសត្រូវ កែលម្អនិងផ្ដល់ឱកាសដល់សិស្ស ការសម្របសម្រួលនិងជំរុញសកម្មភាពសិក្សារបស់សិស្ស ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា SOP ។

**៥.ការស្រាវជ្រាវនិងគំនិតច្នៃប្រឌិត** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើការស្រាវជ្រាវបន្ថែមលើវិធីសាស្ត្រនិងបច្ចេកទេសបង្រៀនថ្មីៗ ការចូលរួមប្រជុំបច្ចេកទេសនិងការផលិតសម្ភារឧបទេស ការរៀបចំកិច្ចតែងការបង្រៀន ការរៀបចំផែនទីគំនិតថ្មីៗក្នុងដំណើរការបង្រៀន ការរិះរកវិធីសាស្ត្រជួយបង្រៀនបន្ថែមដល់សិស្សរៀនយឺត ការដឹកនាំសិស្សធ្វើការសិក្សាស្រាវជ្រាវ ការចងក្រងបទពិសោធន៍នៃវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាពនិងចែករំលែកឬផ្សព្វផ្សាយដល់គ្រូដទៃទៀត ទេពកោសល្យនិងគំនិតច្នៃប្រឌិតធ្វើឱ្យថ្នាក់រៀនមានសកម្មភាពរស់រវើក។

**៦.បំណិនប្រាស្រ័យទាក់ទង** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ទំនាក់ទំនងល្អជាមួយសិស្សព្រមទាំងគ្រូបង្រៀន គណៈគ្រប់គ្រងសាលា មាតាបិតា អ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរដែនដី ការផ្តល់ព័ត៌មានដល់មាតាបិតាឬអ្នកអាណាព្យាបាលសិស្សជាប្រចាំ ការចូលរួមនិងចែករំលែកបទពិសោធន៍ការបង្រៀននិងរៀន ការស្វែងយល់ពីអារម្មណ៍និងតម្រូវការសិស្ស។

**៧.លទ្ធផលសិក្សារបស់សិស្ស** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ សិស្សមានចំណេះដឹងសមស្របតាមកម្រិតថ្នាក់ អត្រាសិស្សបោះបង់ការសិក្សាទាបជាង ឬស្មើថ្នាក់ជាតិ អត្រាសិស្សឡើងថ្នាក់ស្មើឬខ្ពស់ជាងថ្នាក់ជាតិ ការជួយសិស្សរៀនយឺតនិងតម្រង់ទិសសិស្សមានបញ្ញាខ្ពស់ សិស្សមានគំនិតច្នៃប្រឌិត សិស្សពូកែថ្នាក់រាជធានីខេត្តឬថ្នាក់ជាតិ ការផ្គត់ផ្គង់គ្រប់គ្រងនិងថែរក្សាសៀវសិក្សាគោល និយ័តភាពសិក្សា។

**៨.ការសង្កេតការបង្រៀននិងរៀន** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ការអនុវត្តតាមកិច្ចតែងការបង្រៀន ការប្រើប្រាស់សម្ភារៈឧបទេស ការប្រើប្រាស់វិធីសាស្ត្របង្រៀន ការរៀបចំសកម្មភាពសិក្សា និងអន្តរកម្មរវាងសិស្សនិងគ្រូបង្រៀន លទ្ធផលសិក្សារបស់សិស្សសម្រេចបានតាមវត្ថុបំណងមេរៀន ការពេញចិត្តចូលរួមសកម្មភាពរបស់សិស្សជាមួយគ្រូបង្រៀន ការបណ្តុះគំនិតច្នៃប្រឌិត ទម្លាប់ល្អនិងសមត្ថភាពដល់សិស្ស ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងជីវភាពប្រចាំថ្ងៃនិងមុខវិជ្ជាដទៃទៀត ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព បំណិននិងឥរិយាបថរបស់គ្រូបង្រៀន។

**៩.ក្រមសីលធម៌វិជ្ជាជីវៈ** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ការគោរពវិន័យការងារ ការទទួលខុសត្រូវនិងការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ មានសីលធម៌រស់នៅល្អ សាមគ្គីភាពល្អ គុណធម៌និងយុត្តិធម៌ ភក្តីភាពចំពោះអង្គភាព រក្សាការសម្ងាត់វិជ្ជាជីវៈនិងផ្តល់តម្លៃអ្នកសិក្សា ការមិនរើសអើងនិងមិនប្រើអំពើហិង្សា ការថែរក្សានិងទុកដាក់សម្ភារៈ បរិក្ខារ មានសណ្តាប់ធ្នាប់ល្អ។

**១០.ការអភិវឌ្ឍយុវជន** លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃទៅលើ ប្រឹក្សាយោបល់ក្នុងដំណើរការរៀបចំក្រុមប្រឹក្សាកុមារ/យុវជន ការចូលរួមក្នុងក្លឹបសិក្សា កងកាយរឹទ្ធិ ការជំរុញការដឹកនាំសកម្មភាពសង្គម ការចូលរួមសកម្មភាពបណ្តុះបណ្តាលកុមារ/យុវជន។

ការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន និងគណគ្រប់គ្រងសាលារៀន គឺជាកត្តាគន្លឹះមួយដែលនាំទៅរកភាពជោគជ័យក្នុងការផ្តល់សេវាអប់រំដែលប្រកបដោយគុណតម្លៃការទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធិភាពនៅគ្រប់កាលៈទេសៈ។ គ្រូបង្រៀនត្រូវតែមានចំណេះដឹងថ្មីៗ និងគរុកោសល្យថ្មីៗមកបង្ហាត់បង្រៀនដល់សិស្ស និស្សិតឱ្យមានចំណេះដឹងទូលំទូលាយ និងអភិវឌ្ឍខ្លួនទៅជាពលរដ្ឋសកល ជាអ្នកបន្តវេនសម្រាប់សង្គមជាតិនាថ្ងៃអនាគត់ ។ វិស័យអប់រំពិតជាត្រូវការចាំបាច់នូវភាពជាអ្នកដឹកនាំ ដែលមានភាពវៃឆ្លាត រស់រវើក បុរេសកម្ម និងទន់ភ្លន់ ក្នុងការដោះស្រាយបញ្ហា ព្រមទាំងឆ្លើយតបភ្លាមៗចំពោះស្ថានការណ៍នៃវិបត្តិដែលបង្កឱ្យមានភាពរអាក់រអួលក្នុងការបង្រៀន និងការរៀននៅទូទាំងប្រទេស ដូច្នោះការបង្កើននិងពង្រឹងសមត្ថភាពរបស់គ្រូបង្រៀន វាពិតជាសំខាន់ និងតម្រូវឱ្យគ្រូបង្រៀនទាំងអស់ត្រូវតែខិតខំអភិវឌ្ឍសមត្ថភាពខ្លួនឯងឱ្យសមស្របនឹងសម័យបច្ចេកវិទ្យាបច្ចេកទេស និងអនាគត់ផងដែរ ។ ដើម្បីធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត ត្រូវជម្រុញលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ពិសេសលោកគ្រូអ្នកគ្រូ និងមាតាបិតាឬអាណាព្យាបាល ចូលរួមបន្តការចូលរួមទទួលខុសត្រូវ និងធានាថា កុមារទាំងអស់ដែលជាទំពាងស្នងឬស្សីត្រូវបានចូលរៀន ដើម្បីការរីកលូតលាត់នៃរាងកាយប្រកបដោយប្រាជ្ញាស្មារតីល្អរឹងមាំ ដើម្បីក្លាយជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អនៅសតវត្សទី២១នេះ។

## ២.៣ ការអភិវឌ្ឍសាលារៀនដោយសហគមន៍

ដើម្បីឲ្យសាលារៀនទទួលបាននូវការអភិវឌ្ឍទៅមុខជាលំដាប់ និងរាល់ផែនការការងាររបស់សាលារៀន ត្រូវតែមានការចូលរួមពីសហគមន៍ដែលជាកម្លាំងមិនចេះរីងស្ងួត ដូចជា ការចូលរួមកំណត់បញ្ហា កំណត់គោលបំណងសកម្មភាព និងកម្មវិធីផ្សេងៗរួមបញ្ចូលទាំងពេលវេលា។ សហគមន៍ត្រូវជួយផ្សព្វផ្សាយដល់ប្រជាជន ឲ្យកូនចៅទៅសាលារៀនតាមរយៈមធ្យោបាយផ្សេងៗដូចជា ការប្រជុំ ការជួបគ្នានៅវត្តរៀងរាល់ថ្ងៃសីល ថ្ងៃបុណ្យ ការសំដែងសិល្បៈ ការទស្សនា ការបិទប្រកាស វិទ្យុ ទូរទស្សន៍ សារ-ព័ត៌មានប្រកាស និងចូលរួមបើកបវេសនកាលរបស់សហគមន៍មាតាបិតាសិស្ស។ សាលារៀនដំណើរការ

បានល្អ គឺអាស្រ័យដោយមានថវិកាទ្រទ្រង់។ សហគមន៍ត្រូវចូលរួមយ៉ាងសកម្មក្នុងការស្វែងរកថវិកាសម្រាប់ឧបត្ថម្ភសាលារៀន។

### ២.៣.១ សកម្មភាពនៃការដឹកនាំសហគមន៍ចូលរួមអភិវឌ្ឍសាលារៀន

ដំហានសំខាន់ៗសម្រាប់ដំណើរការរៀបចំ ដឹកនាំសហគមន៍ប្រកបដោយភាពជោគជ័យ និងត្រឹមត្រូវទៅតាមនីតិវិធី ត្រូវរៀបចំតាមលំដាប់ដូចជា (១) កាសិក្សាស្រាវជ្រាវដំហានដំបូង (២)រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ (៣) ការកំណត់ព្រំប្រទល់សហគមន៍ (៤) ការរៀបចំច្បាប់ និងបទបញ្ជាផ្ទៃក្នុង(៥)ការរៀបចំធ្វើកិច្ចព្រមព្រៀងជាមួយសហគមន៍(៦)ការរៀបចំផែនការសម្រាប់គ្រប់គ្រសហគមន៍ (Mikiko, 2017)។ អ្នកដឹកនាំសហគមន៍មួយល្អត្រូវ យកប្រយោជន៍រួមជាធំជាងប្រយោជន៍ខ្លួន មានគំនិតទូលំទូលាយប្រកបដោយគំនិតគតិបណ្ឌិត ចេះផ្លាស់ប្តូរតាមកាលៈទេសៈនិងយល់អំពីសភាពការណ៍ មានគោលការណ៍ច្បាស់លាស់ ក្លាហាន និងចេះស្តាប់អ្នកដទៃ អ្នកដែលចេះប្រមូលផ្តុំសមាជិករបស់ខ្លួនទាំងអស់ដើម្បីធ្វើការរួមគ្នា (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១)។ អ្នកដឹកនាំជាបុគ្គលិកដែលធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមានលើអ្នកដទៃ ក្នុងការកំណត់គោលដៅ និងសមិទ្ធិផលរបស់វា ហើយគេប្រើប្រាស់នូវឥទ្ធិពលលើអ្នកដទៃតាមរយៈការប្រើប្រាស់អំណាច ជំនឿ និងការយល់គ្នាទៅវិញទៅមកតាមការប្រាស្រ័យទាក់ទងគ្នា ហើយលក្ខណៈនៃអ្នកដឹកនាំល្អ មានសមត្ថភាព មានគំនិតទូលំទូលាយ មានចំណេះដឹងនិងទេពកោសល្យក្នុងការលើកទឹកចិត្ត ស្វែងយល់ពីចំនុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន យល់ដឹងពីសកម្មភាពក្រុមការងារនិងខ្លួនឯងក៏ដូចជាបុគ្គលិក មានភាពប៉ិនប្រសព្វ និងត្រូវមានឆន្ទៈក្នុងការផ្ទេរចំណេះដឹង ( ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ ក្នុងការដឹកនាំសហគមន៍ត្រូវយកចិត្តទុកដាក់លើបញ្ហាដូចជា ៖

- ត្រូវអភិវឌ្ឍនិងឆ្លើយតមទៅនឹងសេចក្តីត្រូវការរបស់សហគមន៍មូលដ្ឋាន
- ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមស្តាប់ ផ្តល់អនុសាសន៍ដល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- ផ្តល់ការគាំទ្រជួយកែលម្អស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឃុំ សង្កាត់

- ការធ្វើផែនការឃុំ សង្កាត់ផ្អែកលើតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋមូលដ្ឋាននិងធនធានថវិកា កម្លាំងពលកម្មឆ្លើយតបចំណុចអាទិភាពរបស់សហគមន៍ដែលត្រូវអភិវឌ្ឍន៍ ។

យោងតាមក្រសួងអប់រំ យុវជន និងកីឡា (២០២១) ដើម្បីធ្វើឲ្យសង្គមមានការអភិវឌ្ឍអ្នកដឹកនាំសហគមន៍ត្រូវ ធ្វើដូចតទៅៈ

- សហការជិតស្និទ្ធលជាមួយមហាជន
- ចេះរៀបចំចាត់ចែង បែងចែកការងារឲ្យល្អ
- មានគំនិតផ្តួចផ្តើមរៀបចំគោលដៅ
- បើកឱកាសឲ្យមហាជន សាកសួរ ផ្តល់មតិ
- ចេះជម្រុញឲ្យមានមនុស្សក្នុងសហគមន៍ចង់ចេះ
- ចង់ដឹងនិងបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួន
- ចេះផ្តល់បទពិសោធន៍ឲ្យគ្នាទៅវិញទៅមក
- ចេះគ្រប់គ្រងនូវសមាជិកក្នុងសហគមន៍ ។

យោងតាម ការរៀបចំផែនការអភិវឌ្ឍសាលារៀន របស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) បានលើកឡើងថា សហគមន៍អភិវឌ្ឍន៍ត្រូវធ្វើដូចតទៅៈ

- សហគមន៍ត្រូវជិតស្និទ្ធជាមួយប្រជាជន
- បើកឱកាសឲ្យមហាជន សាកសួរ ផ្តល់មតិ
- ចេះចាត់ចែងរៀបចំ បែងចែការងារ
- មានទស្សនៈទូលំទូលាយទៅអនាគត
- ជំរុញការងារអភិវឌ្ឍន៍ផ្ទាល់ខ្លួនក្នុងសហគមន៍ ។

**២.៣.២ ការគាំទ្រ និងផ្សព្វផ្សាយរបស់សហគមន៍**

សហគមន៍បានដើរតួនាទីយ៉ាងសំខាន់ និងមានសក្តានុពលសម្រាប់អនុវត្តកម្មវិធី កំណែទម្រង់វិស័យអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា,២០២១)។ សក្តានុពលទាំងនោះមានដូចជា សហគមន៍ជា

មន្ត្រីដែលមិនទាមទារប្រាក់ខែ សហគមន៍ជាមន្ត្រីដែលសម្បូរដោយទ្រព្យសម្បត្តិ មានចំណេះដឹង និងមានការប្តេជ្ញាចិត្តដើម្បីសហគមន៍ ហើយអ្វីដែលសហគមន៍ត្រូវការនោះ គឺក្រុមប្រតិបត្តិដែលឯកភាពគ្នាក្នុងសហគមន៍ ដើម្បីពួកគេប្រើប្រាស់សក្តានុពលរបស់ពួកគេបានក្នុងការជួយសហគមន៍សាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១)។ ធនធានមនុស្សក្នុងសហគមន៍ គឺជាធនធានប្រកបដោយសក្តានុពលសម្រាប់ដំណើរការអភិវឌ្ឍសហគមន៍ ការផ្សព្វផ្សាយ និងសហគមន៍មានសមត្ថភាពក្នុងការច្នៃប្រឌិត វិភាគប្រាស្រ័យទាក់ទង កសាងទំនុកចិត្ត និងធ្វើសកម្មភាពរួមគ្នាដើម្បីប្រយោជន៍រួម (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១)។ ការចូលរួម និងគាំទ្ររបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ គឺជាបេះដូងនៃការចងក្រងសហគមន៍ ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តគម្រងកម្មវិធី (ក្រសួងអប់រំ យុវជន និងកីឡា, ២០១០)។ ក្នុងន័យនោះ គឺការចងក្រងសហគមន៍ត្រូវមានប្រព័ន្ធសកម្មភាពច្បាស់លាស់ មានន័យថាត្រូវចាប់ផ្តើមពីត្រង់ណា បញ្ចប់នៅត្រង់ណា ហើយសកម្មភាពអ្វីខ្លះដែលត្រូវបំពេញ។

### ២.៣.៣ សហគមន៍ចូលរួមកៀងគរដៃគូអភិវឌ្ឍន៍សាលារៀន

ការចូលរួម និងការប្តេជ្ញាចិត្តរបស់មន្ត្រីអប់រំនៅគ្រប់កម្រិត របស់សិស្សានុសិស្ស របស់សហគមន៍ និងមាតាបិតា/អ្នកអាណាព្យាបាល ជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន(ក្រសួងអប់រំ យុវជន និងកីឡា ,២០១៨)។

ការរៀបចំឱ្យមានសមាសភាពមកពីក្រុមប្រឹក្សាឃុំ គណៈកម្មការភូមិ នគរបាលប៉ុស្តិ៍ និងមន្ត្រីមណ្ឌលសុខភាព ជាមួយនាយកសាលា គ្រូបង្រៀន និងក្រុមប្រឹក្សាយុវជននិងកុមារ នៅក្នុងក្រុមការងារសម្រាប់អភិវឌ្ឍន៍សាលារៀន ដែលជាផ្នែកនៃគណៈកម្មការទ្រទ្រង់សាលារៀន។ ការរៀបចំឱ្យមានដំណើរការធ្វើការរួមគ្នា អាចផ្តោតទៅលើ (១)ការគ្រប់គ្រងស្ថិតិអប់រំ សុខភាព សង្គម និងសេដ្ឋកិច្ច ក្នុងភូមិសាស្ត្រឃុំដើម្បីធានាបានពីការធ្វើបច្ចុប្បន្នភាពផែនទីខ្នងផ្ទះ និងធ្វើរួមគ្នាក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន (៣)ការរៀបចំឱ្យមានការតាមដាន និងវាយតម្លៃគ្នាលើការងារអប់រំ និងការងារគណនេយ្យភាពសង្គម ទៅលើសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។

សារៈប្រយោជន៍នៃការចូលរួមរបស់សហគមន៍ គឺបង្កើតការទុកចិត្តគ្នារវាងសហគមន៍ គ្រូបង្រៀន និងសាលារៀន ព្រមទាំងការចូលរួមរបស់មាតាបិតា និងសិស្សក្នុងការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀនដែលមានសារៈសំខាន់ដើម្បី បំពេញចន្លោះខ្វះខាតនៃការពិនិត្យតាមដានកិច្ចការរបស់នាយកសាលា និងគ្រូបង្រៀន។ ការទុកចិត្តនេះអាចធ្វើឱ្យមានការចូលរួម និងការបរិចាករបស់សហគមន៍ជួយដល់សាលារៀន ហើយសាលារៀន និងគ្រូបង្រៀនត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ និងមាតាបិតាតាមគោលការណ៍គណនេយ្យភាព (ក្រសួងអប់រំ យុវជន និងកីឡា,២០១៨)។

❖ ប្រភេទនៃការចូលរួមរបស់សហគមន៍សម្រាប់ការធ្វើផែនការ និងការអភិវឌ្ឍន៍ការអប់រំ

☞ ការពង្រឹងអំណាច (Empowerment) ប្រជាជនក្នុងតំបន់មានការគ្រប់គ្រងលើការអភិវឌ្ឍន៍ទាំងអស់ដោយគ្មានឥទ្ធិពលណាមួយឡើយ(Choguill, 1996; Dewar, 1999)។

☞ ភាពជាដៃគូ( Partnership) មានកម្រិតខ្លះនៃឥទ្ធិពលក្នុងស្រុកនៅក្នុងដំណើរការអភិវឌ្ឍន៍ (Arnstein, 1969)។

☞ អន្តរកម្ម (Interaction) មនុស្សមានការចូលរួមកាន់តែច្រើននៅក្នុងកម្រិតនេះ។ សិទ្ធិរបស់ប្រជា-ពលរដ្ឋមូលដ្ឋានទទួលស្គាល់ និងទទួលយកក្នុងការអនុវត្តនៅថ្នាក់មូលដ្ឋាន (Pretty, 1995)។

☞ ការពិគ្រោះយោបល់ (Consultation) មនុស្សត្រូវបានពិគ្រោះយោបល់តាមវិធីជាច្រើន ឧ. ចូលរួមក្នុងសហគមន៍ការប្រជុំ ឬសូម្បីតែសវនាការសាធារណៈ។ អ្នកអភិវឌ្ឍន៍អាចទទួលយកការរួមចំណែកមួយចំនួនពីអ្នកស្រុកដែលផ្តល់អត្ថប្រយោជន៍ដល់គម្រោងរបស់ពួកគេ (Arnstein, 1969) ។

☞ ការជូនដំណឹង (Informing)៖ ប្រជាជនត្រូវបានប្រាប់អំពីកម្មវិធីអភិវឌ្ឍន៍ដែលត្រូវបានសម្រេចចិត្តរួចហើយនៅក្នុងសហគមន៍ ។ អ្នកអភិវឌ្ឍន៍ដំណើរការគម្រោងដោយគ្មានស្តាប់យោបល់របស់ប្រជាជនក្នុងតំបន់ (Arnstein, 1969) ។

☞ ឧបាយកល (Manipulation)៖ ការអភិវឌ្ឍន៍ជាទូទៅត្រូវបានបង្កើតឡើងដោយបុគ្គលដែលមានអំណាចមួយចំនួន ឬរដ្ឋាភិបាលដោយគ្មានការពិភាក្សាជាមួយប្រជាជន (Arnstein, 1969) ។

ការកៀរគរសហគមន៍ គឺជាការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងសហគមន៍លើសកម្មភាពអភិវឌ្ឍន៍នានាដោយការចាត់អាទិភាព ធនធាន តម្រូវការ និងដំណោះស្រាយនានាដើម្បីភាពប្រសើរឡើង នៃការចូលរួមឱ្យមានការអភិវឌ្ឍ អភិបាលកិច្ចល្អ គណនេយ្យភាព និងសន្តិភាព។ ការរំពឹងថាសហគមន៍នឹងអាចកំណត់បានអំពីបញ្ហាដែលពួកគេជួបប្រទះ តម្រូវការ ដំណោះស្រាយ ការកៀរគរធនធាន ការអនុវត្ត និងគ្រប់គ្រងគម្រោង និងធ្វើឱ្យសហគមន៍មានការផ្លាស់ប្តូរជាវិជ្ជមានប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចគោលដៅទាំងនេះថ្នាក់ដឹកនាំសាលា ត្រូវផ្តល់វគ្គបណ្តុះបណ្តាលជាប្រចាំដល់ថ្នាក់ដឹកនាំសហគមន៍ដើម្បីកសាងជំនាញ និងបទពិសោធន៍ បង្កើនឱកាស និងបង្កើនការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តផងដែរ។ ដើម្បីជំរុញឱ្យសហគមន៍មានសិទ្ធអំណាច និងមានស្វ័យភាពក្នុងការដឹកនាំ និងគ្រប់គ្រងក្នុងសហគមន៍ដើម្បីឱ្យការអភិវឌ្ឍមាននិរន្តរភាព។

## ២.៤ គោលការណ៍នៃការគ្រប់គ្រងសាលារៀន

តាមសៀវភៅណែនាំប្រតិបត្តិស្តីពី ការគ្រប់គ្រងតាមសាលារៀន (២០១៨) បានលើកឡើងនៅអភិក្រមក្នុងការគ្រប់គ្រងតាមសាលារៀនត្រូវធ្វើឡើង ដោយគោរពតាមសមាសភាពទាំង ៥គឺ (១) ស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងថវិកាសាលារៀន (២) ស្វ័យភាពក្នុងការគ្រប់គ្រងបុគ្គលិក (៣) តួនាទីគណៈកម្មការគ្រប់គ្រងសាលារៀន/ SMC និងអភិបាលកិច្ចសាលារៀន (៤) ការវាយតម្លៃសាលារៀន និងសិស្ស (៥) គណនេយ្យភាពសាលារៀន។

(១)ស្វ័យភាពក្នុងការធ្វើផែនការនិងការគ្រប់គ្រងថវិកាសាលារៀនអនុម័តសូចនាករផលសម្រេច និងក្រុមគោលដៅ អនុម័តផែនការកែលម្អសាលារៀននិងថវិការឆ្នាំ ផ្តល់ការព្រមព្រៀងលើការវាយតម្លៃការអនុវត្តន៍របស់សាលារៀនធៀបជាមួយនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព គាំទ្រនិងជួយដល់ការរកមូលនិធិសាលារៀន។ ក្នុងន័យនេះដើម្បី សម្របសម្រួលការពិភាក្សា និងសម្របសម្រួលមនុស្សឱ្យធ្វើការជាមួយគ្នា ក្នុងការរៀបចំសូចនាការផលសម្រេច និងក្រុមគោលដៅ និងផែនការកែលម្អសាលារៀននិងថវិកាឆ្នាំ ដាក់ជូនលទ្ធផលវាយតម្លៃការអនុវត្តរបស់សាលារៀនមានសប្រសិទ្ធភាពដល់គណៈកម្មការ

គ្រប់គ្រងសាលារៀន គ្រប់គ្រងសម្របសម្រួលការពិភាក្សា និងសម្របសម្រួលមនុស្សឱ្យធ្វើការជាមួយគ្នាលើសកម្មភាពរកមូលនិធិសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨) ។

(២) ស្វ័យភាពក្នុងការគ្រប់គ្រងបុគ្គលិក អនុម័តរង្វាន់ដល់មន្ត្រីដែលបានបំពេញការងារបានល្អប្រសើរ ស្នើវិធានការរដ្ឋបាលសម្រាប់មន្ត្រីមិនអនុវត្តន៍ភារកិច្ចដល់ថ្នាក់ក្រោមជាតិ អនុម័តរង្វាន់សម្រាប់នាយក ឬនាយិកាដែលបានបំពេញការងារល្អប្រសើរ។ ជារួមអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រីនិងដាក់ស្នើ ផ្តល់រង្វាន់ដល់មន្ត្រីដែលបានបំពេញការងារល្អប្រសើរ និងស្នើដល់គណៈកម្មការគ្រប់គ្រងសាលារៀននូវវិធានការរដ្ឋបាលសម្រាប់មន្ត្រីមិនអនុវត្តន៍ភារកិច្ច(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨) ។

(៣) តួនាទីគណៈកម្មការគ្រប់គ្រងសាលារៀន (SMC) និងអភិបាលកិច្ចសាលារៀន គាំទ្រក្នុងការដោះស្រាយបញ្ហាដែលលើកឡើង ដោយមាតាបិតានិងសិស្សពីការពិនិត្យតាមដានសាលារៀននិងថ្នាក់រៀន ធនាតម្លាភាពក្នុងការចូលរួមរបស់សហគមន៍។ ជាការសម្របសម្រួលធានាដំណើរការដោយរលូននូវការអនុវត្តសកម្មភាព ជាតួនាទីរបស់សហគមន៍និងអភិបាលកិច្ចសាលារៀន ពិនិត្យឡើងវិញនិងដាក់ស្នើការកែសម្រួលដើម្បីធានានូវតម្លាភាពក្នុងការចូលរួមរបស់សហគមន៍(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨) ។

(៤) ការវាយតម្លៃសាលារៀន និងសិស្ស អនុម័តលទ្ធផលវាយតម្លៃការអនុវត្តរបស់សាលារៀន ទទួលស្គាល់របាយការណ៍រីកចម្រើនប្រចាំត្រីមាសពីការអនុវត្តផែនការកែលម្អសាលារៀន ទទួលស្គាល់របាយការណ៍រីកចម្រើនប្រចាំឆ្នាំពីការសម្រេចសូចនាករនិងក្រុមគោលដៅផលសម្រេច។ សម្របសម្រួលការពិភាក្សា និងសម្របសម្រួលមនុស្សឱ្យធ្វើការវាយតម្លៃការអនុវត្តរបស់សាលារៀនធៀបនឹងស្តង់ដារសាលារៀនមានសប្រសិទ្ធភាព ធ្វើការចងក្រងទិន្នន័យនិងព័ត៌មានសម្រាប់ផលិតរបាយការណ៍ រីកចម្រើនប្រចាំត្រីមាស ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀនដល់គណៈកម្មការគ្រប់គ្រងសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨) ។

(៥) គណនេយ្យភាពសាលារៀន ទទួលស្គាល់របាយការណ៍ទាំងឡាយដែលត្រូវផ្សព្វផ្សាយជាសាធារណៈ រៀបចំនិងដាក់ស្នើរបាយការណ៍ទាំងឡាយ ដែលត្រូវផ្សព្វផ្សាយជាសាធារណៈដល់គណៈកម្មការគ្រប់គ្រងសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ ការអនុវត្តរចនាសម្ព័ន្ធគណនេយ្យភាព តាមសាលារៀនត្រូវមានការគាំទ្រពីថ្នាក់ដឹកនាំ ហើយថ្នាក់ដឹកនាំទៀតសោតត្រូវ យល់ដឹងឱ្យបានច្បាស់ពីគោលបំណងក្នុងការផ្តល់មូលដ្ឋានសុទ្ធសាធ នឹងនាំមកនូវហានិភ័យដល់សាលារៀន បែបនេះហើយទើបចាំបាច់ត្រូវរៀបចំឱ្យមានប្រព័ន្ធមួយដ៏ប្រសើរ ដែលនាំមកនូវកិច្ចសហប្រតិបត្តិការវាងថ្នាក់ជាតិក្រោមជាតិ និងថ្នាក់សាលារៀនក្នុងការធ្វើការសម្រេចចិត្ត។ ដើម្បីឱ្យសាលារៀនមានប្រសិទ្ធភាព ការធ្វើវិមជ្ឈការត្រូវបានផ្តោតសំខាន់លើការផ្លាស់ប្តូរសិទ្ធិអំណាច នៃរចនាសម្ព័ន្ធមានស្រាប់នៅក្នុងសហគមន៍ គណៈកម្មការគ្រប់គ្រងសាលារៀន ដែលជាការបង្កើនការលានុវត្តភាពក្នុងការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ ក្នុងការដំណើរការសាលារៀន (Bardhan, 2002)។ គណនេយ្យភាព សំដៅទៅលើលក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងរបាយការណ៍ ចំណែកឯតម្លាភាពពាក់ព័ន្ធនិងរបាយការណ៍ ដំណើរការនិងការប្រតិបត្តិទាន់ពេលវេលា អាចជឿជាក់បាន ច្បាស់លាស់ និងឆ្លើយតបជាសាធារណៈ។

ក្នុងអភិក្រមការគ្រប់គ្រងតាមសាលារៀន គឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាព ដោយសារស្ថាប័នមានភាពរឹងមាំ ហើយសាលារៀនមានភាពស្វ័យភាព និងគណនេយ្យភាព (Eurydice, 2007)។ ការគ្រប់គ្រងសាលារៀន នឹងមានប្រសិទ្ធភាពក្នុងករណីណាដែលបុគ្គលិក អប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានសមត្ថភាព ធ្វើឱ្យការដឹកនាំគ្រប់គ្រងសាលារៀនមានការឆ្លើយតបនឹងតម្រូវការរបស់សិស្ស និងគ្រូបង្រៀនទាន់ពេលវេលា។ ក្នុងតម្រូវការជាអាទិភាពរបស់សិស្សនិងគ្រូបង្រៀនត្រូវបានកំណត់តាមរយៈទិន្នន័យនិងព័ត៌មានដែលប្រមូលបានមកពីការវាយតម្លៃសិស្ស គ្រូបង្រៀន និងសាលារៀន ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដែលជាការប្រើប្រាស់ និងផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានពិតជាប្រចាំ ព្រមទាំងដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព នឹងធ្វើឱ្យសហគមន៍ បុគ្គលិកអប់រំ មានទំនុកចិត្តលើសាលារៀន ធ្វើឱ្យបុគ្គលិកអប់រំជឿទុកចិត្តគ្នាទៅវិញទៅមក ជាពិសេសធ្វើឱ្យមាតាបិតា អ្នកអាណាព្យាបាលសិស្ស អាជ្ញាធរ មានទំនុកចិត្តលើគ្រូបង្រៀន និងសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

### ២.៤.១ វិមជ្ឈការនិងការអប់រំ

វិមជ្ឈការអប់រំអាចជួយឱ្យមាតាបិតា និងសិស្សខិតទៅជិតអ្នកផ្តល់សេវាអប់រំ ជានានូវការទទួលយកបាននូវគរុកោសល្យបង្រៀន និងការគ្រប់គ្រងប្រសើរច្រើនស្របតាមអ្វីដែលគេត្រូវការ(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ តែបើការខិតចូលនេះវាតិចពេក វានាំឱ្យប្រព័ន្ធអប់រំមានការបែកបាក់ ដល់ទីបញ្ចប់ស្តង់ដាអប់រំមិនត្រូវបានបំពេញ ហើយតម្លៃសហគមន៍នឹងត្រូវក្លាយជាមិនមានន័យក្នុងការជួយសង្គម (Ritzen, Domelen and Vijider, 1997)។ សម្រាប់វិស័យអប់រំ ដំណើរការវិមជ្ឈការត្រូវការប្តេជ្ញាចិត្ត និងការដឹកនាំរឹងមាំកម្រិតគោលនយោបាយ ដើម្បីអាចសម្រេចជោគជ័យបាន (McLean and King, 1999)។ ប្រទេសជាច្រើនមានពិសោធន៍ថា ការធ្វើវិមជ្ឈការត្រឹមតែថ្នាក់ក្រោមជាតិគឺ មិនគ្រប់គ្រាន់ទេ ហើយដើម្បីឱ្យមានភាពប្រសើរនៅសាលារៀន និងការរៀនសូត្រនោះត្រូវបង្កើតស្វ័យភាពដល់សហគមន៍ និងមន្ត្រីនៅសាលារៀនជាការចាំបាច់ (McLean and King, 1999)។ វិធីដើម្បីធ្វើវិមជ្ឈការអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តពីថ្នាក់កណ្តាលទៅសាលារៀន គឺត្រូវបានទទួលស្គាល់ថា ជាការគ្រប់គ្រងតាមសាលារៀន (SBM) (Caldwell, 2005; Fasih and Patrinos, 2009)។ ដើម្បីឱ្យមានប្រសិទ្ធភាពការធ្វើវិមជ្ឈការត្រូវតែប៉ងឱ្យបានដើម្បីផ្លាស់ប្តូររចនាសម្ព័ន្ធ នៃអំណាចរបស់សហគមន៍ ដែលកំពុងមានបច្ចុប្បន្ន ធ្វើឱ្យមានឱកាសសម្រាប់ការចូលរួមច្រើន និងបង្ហាញនូវគំនិតយោបល់របស់សហគមន៍ និងឱ្យបានគ្រប់ប្រជាពលរដ្ឋទាំងអ្នកក្រ និងអ្នកជួបការលំបាកឱ្យចូលរួម (Bardhan, 2002)។ វាហាក់ដូចជាមានការឯកភាពគ្នាតាំងពីឆ្នាំ ១៩៨០ ទាំងការធ្វើវិមជ្ឈការហួសហេតុពេក ឬការផ្តល់សិទ្ធិអំណាចទាំងស្រុងទៅមូលដ្ឋានអាចនាំមកនូវមហន្តរាយ។ ដូចនេះហើយត្រូវតែរៀបចំឱ្យមាននូវប្រព័ន្ធសហប្រតិបត្តិការប្រសើររវាង ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ស្តីពីសិទ្ធិក្នុងការធ្វើការសម្រេចចិត្ត។

### ២.៤.២ គោលបំណងនៃការគ្រប់គ្រងសាលារៀន

តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំ(២០១៤-២០១៨) បានកំណត់គោលនយោបាយចំនួន៣គឺ (១) ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ (២)លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ (៣)អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍន៍សមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ។ ការ

គ្រប់គ្រងតាមសាលារៀនធ្វើឱ្យមានការប្រែប្រួលខ្លាំងជាវិជ្ជមាន លើលទ្ធផលសិក្សារបស់សិស្ស (Patrinos, 2011)។ ការគ្រប់គ្រងតាមសាលារៀន គឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាព ដោយសារស្ថាប័នមានភាពរឹងមាំ ហើយសាលារៀនមានស្វ័យភាព និងគណនេយ្យភាព (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ ក្នុងន័យនេះចង់បង្ហាញថា ការគ្រប់គ្រងសាលារៀន នឹងមានប្រសិទ្ធភាពប្រសិនបើ បុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានសមត្ថភាព ធ្វើឱ្យការដឹកនាំគ្រប់គ្រងសាលាសរៀន ឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់សិស្ស និងគ្រូបង្រៀនទាន់ពេលវេលា។

## ២.៥ សកម្មភាពពាក់ព័ន្ធនិងការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន

ភាពជាដៃគូរវាងសាលារៀន និងសហគមន៍ត្រូវបានគេមើលឃើញថាជាមធ្យោបាយដ៏ជោគជ័យ ដើម្បីជួយដល់សិស្សានុសិស្ស គ្រួសារ ដែលជួបការលំបាក នៅក្នុងវឌ្ឍនភាពសម័យកាល សាលាក្នុងស្រុកត្រូវបានគេមើលជាទូទៅថា ជាស្ថាប័នកណ្ដាលរបស់សហគមន៍ សាលារៀនជាកន្លែងបម្រើ ដែលសមាជិកសហគមន៍អាចស្ដាប់ការបង្រៀន ជជែកវែកញែកអំពីបញ្ហាពលរដ្ឋ និងប្រើប្រាស់កន្លែងសម្រាប់កម្សាន្តនៅពេលយប់ ចុងសប្ដាហ៍ និងពេលសម្រាកពីសាលា អ្នកកែទម្រង់សង្គមមកពីសាលាក្រៅប្រព័ន្ធ រួមទាំងអ្នកបោកប្រាស់ សកម្មជន គ្រូពេទ្យសុខភាពសាធារណៈ (Dewey, 1902)។

សហគមន៍អាចដើរតួនាទីផ្សេងៗគ្នានៅក្នុងការផ្ដល់ និងគ្រប់គ្រងការអប់រំ និងដំណើរការសិក្សា។ ការចូលរួមរបស់សហគមន៍អាចធ្វើបាន នូវការរួមចំណែកលើកកម្ពស់ការអប់រំ (UNICEF, 1992)។ ការចូលរួមរបស់សហគមន៍គឺជាគោលគំនិតមួយព្យាយាមនាំភាគីពាក់ព័ន្ធផ្សេងៗគ្នាមកជាមួយគ្នា សម្រាប់ការដោះស្រាយបញ្ហា និងការសម្រេចចិត្ត (Talbot & Verrinder, 2005) ។ ការចូលរួមរបស់សហគមន៍គឺចាត់ទុកថាចាំបាច់ដើម្បីទទួលបានការគាំទ្រពីសហគមន៍សម្រាប់ការរៀបចំផែនការ និងការអភិវឌ្ឍន៍អប់រំ (Cole, 2007)។

ការចូលរួមរបស់សហគមន៍ សំដៅដល់ប្រជាជន ការចូលរួមសកម្មភាពក្នុងវិស័យប្រព័ន្ធអប់រំ ហើយវាដើរតួយ៉ាងសំខាន់ និងយូរអង្វែង ដែលតួនាទីក្នុងការលើកកម្ពស់គុណភាពជីវិត (Putnam, 2000)។ ការចូលរួមរបស់សហគមន៍ក្នុងការអប់រំដំណើរការអភិវឌ្ឍន៍ អាចជាគាំទ្រ និងគាំទ្រវប្បធម៌

ប្រពៃណី ចំណេះដឹង និងជំនាញក្នុងស្រុក និងបង្កើតមោទនភាពក្នុងបេតិកភណ្ឌសហគមន៍ (Lacy et al., 2002)។

ការចូលរួមរបស់សហគមន៍ គឺជាផ្នែកមួយនៃយន្តការផ្តល់សិទ្ធិអំណាចឲ្យមនុស្សចូលរួមការអភិវឌ្ឍការអប់រំ ហើយវាត្រូវបានបើកដំណើរការជាគំនិតសំខាន់នៃការអភិវឌ្ឍ ព្រមទាំងកើនឡើងការចូលរួម គឺជាមធ្យោបាយដើម្បីសម្រេចបាននូវការអភិវឌ្ឍដើម្បីដោះស្រាយបញ្ហាអប់រំ (Aref et al, 2009; Lasker, Weiss, and Miller, 2001)។

តាមការសិក្សាស្រាវជ្រាវក្នុងប្រទេសអ៊ីរ៉ង់របស់ Aref, (2011) បានបរិយាយថា ការយល់ដឹងអំពីឧបសគ្គនៃការចូលរួម គឺសំខាន់នៅពេលដែលសហគមន៍កំពុងរៀបចំ សម្រាប់ការចូលរួមក្នុងការអភិវឌ្ឍវិស័យអប់រំ ការធ្វើផែនការ។ ការយល់ដឹងនេះអាចជួយសហគមន៍ និងអង្គការនានាកាន់តែមានប្រសិទ្ធភាពប៉ះពាល់ដល់ដំណើរការបង្កើតគោលនយោបាយអប់រំ។ លើសពីនេះទៅទៀត វាមានសារៈសំខាន់សម្រាប់រដ្ឋាភិបាលក្នុងការយល់ដឹងប្រព័ន្ធអប់រំប្រឈម នឹងឧបសគ្គដែលអាចរារាំងវឌ្ឍនភាពរបស់ខ្លួន ក្នុងការឆ្លើយតប និងការទទួលស្គាល់អាទិភាពរបស់សហគមន៍មូលដ្ឋាននៅក្នុងប្រទេស។ ការជំនះឧបសគ្គចំពោះការអប់រំ នឹងបម្រើការសម្រួលដល់ដំណើរការបង្កើតគោលនយោបាយ។ មានអក្សរសិល្ប៍ជាច្រើនដែលទាក់ទងដោយផ្ទាល់ជាមួយឧបសគ្គនៃសហគមន៍ ជាពិសេសនៅក្នុងប្រទេសទីបី។ ជាពិសេសការអភិវឌ្ឍវិស័យអប់រំនៅអ៊ីរ៉ង់មានឧបសគ្គជាច្រើនដែលមិនអាចអភិវឌ្ឍន៍បាន។ ខាងក្រោមនេះគឺជាឧបសគ្គចម្បង៖

- អសមត្ថភាពក្នុងការវិភាគការផ្លាស់ប្តូរវិមាត្រសង្គមនៃប្រព័ន្ធការអប់រំ
- កង្វះការយល់ដឹងអំពីដំណើរការគោលនយោបាយ
- កង្វះលទ្ធភាពទទួលបានព័ត៌មាន (Steven & Jennifer, 2002) ។

ការចូលរួមសហគមន៍ក្នុងការអប់រំ ការធ្វើផែនការតម្រូវឱ្យប្រឈមមុខ និងដោះស្រាយបញ្ហាប្រឈមមួយចំនួន។ ជាទូទៅដូចជា Crewe និង Harrison (1998) វិធីសាស្ត្រចូលរួមយ៉ាងច្បាស់លាស់មើលរំលងភាពស្មុគស្មាញ និងសំណួរនៃអំណាច និងជម្លោះក្នុងសហគមន៍។ ពួកគេត្រូវបានរចនាឡើងដោយផ្អែកលើការសន្មតមិនពិតដែលថាសហគមន៍ ក្រុម ឬគ្រួសារមានភាពដូចគ្នា ឬមានផលប្រយោជន៍

ដែលត្រូវគ្នាទៅវិញទៅមក។ ភាពខុសគ្នាកើតឡើងទាក់ទងនឹងអាយុ ភេទ ទ្រព្យសម្បត្តិ ជាតិសាសន៍ ភាសា វប្បធម៌ ជាតិសាសន៍ ជាដើម។ ចាំបាច់ផ្តល់ឱកាសដើម្បីបង្ហាញពីទស្សនៈរបស់ពួកគេក្នុងកម្រិតដូចគ្នានឹងអ្នកដទៃ។

ក្នុងការព្យាយាមស្វែងយល់ពីកត្តា ដែលរារាំងសហគមន៍មិនឱ្យចូលរួមការអប់រំផ្លូវការ Shaeffer (1992) បានរកឃើញថាកម្រិតនៃការចូលរួមរបស់សហគមន៍ ជាកម្រិតទាបនៃសង្គម និងសេដ្ឋកិច្ចតំបន់។ នេះគឺដោយសារតែតំបន់បែបនេះមានទំនោរទៅមានធាតុដូចជាៈ (ក) កង្វះខាតការកោតសរសើរចំពោះគោលបំណងរួមការអប់រំ (ខ) ភាពមិនស៊ីចង្វាក់គ្នារវាងឪពុកម្តាយការរំពឹងទុកនៃការអប់រំ និងអ្វីដែលសាលាត្រូវបានគេមើលឃើញថាជាការផ្តល់ (គ) ជំនឿថាការអប់រំគឺមានសារៈសំខាន់ដែលភារកិច្ចរបស់រដ្ឋ (ឃ) រយៈពេលត្រូវការពេលវេលាដើម្បីដឹងពីអត្ថប្រយោជន៍នៃសាលាកាន់តែប្រសើរ និង (ង) ភាពល្ងង់ខ្លៅនៃរចនាសម្ព័ន្ធ មុខងារ និងឧបសគ្គរបស់សាលា (Uemura,1999)។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងណាមួយដើម្បីលើកកម្ពស់សហគមន៍ការចូលរួមក្នុងផែនការអប់រំ និងការអភិវឌ្ឍ ចាំបាច់ត្រូវវាយតម្លៃសមត្ថភាពរបស់សហគមន៍ដើម្បីអនុវត្តអ្វីដែលពួកគេបានរំពឹងថា នឹងសម្រេចបានក្នុងរយៈពេលវែង។ ការចូលរួមរបស់សហគមន៍ ខ្លួនឯងជាគោលដៅការអភិវឌ្ឍក្នុងការអប់រំ ឬកែលម្អដើម្បីដោះស្រាយភាពស្មុគស្មាញបញ្ហា ដែលរួមចំណែកដល់គុណភាពអប់រំមិនល្អនៅក្នុងទូទាំងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។ វាគឺជាដំណើរការដែលជួយសម្រួលដល់ការសម្រេចបានការលើកកម្ពស់គុណភាពអប់រំ និងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យក្នុងសង្គម។ នៅក្នុងការសិក្សាស្វែងយល់ពីគំនិតនៃសហគមន៍ការចូលរួមក្នុងដំណើរការអប់រំ ការអភិវឌ្ឍ ការសិក្សាក៏បានបង្ហាញផងដែរ ការចូលរួមរបស់សហគមន៍អាចរួមចំណែកដល់ការធ្វើផែនការ និងការអភិវឌ្ឍការអប់រំ តាមរយៈបណ្តាញផ្សេងៗ។ ខាងក្រោមនេះគឺជាវិធីដែលសហគមន៍អាចចូលរួមចំណែកដល់ការធ្វើផែនការ និងការអភិវឌ្ឍការអប់រំ។

- ☞ ការតស៊ូមតិការចុះឈ្មោះចូលរៀន និងអត្ថប្រយោជន៍នៃការអប់រំ
- ☞ ការលើកកម្ពស់សីលធម៌របស់គ្រូបង្រៀន

☞ រៀអង្គាសប្រាក់សម្រាប់សាលារៀន

☞ សាងសង់ ជួសជុល និងកែលម្អសាលារៀនគ្រឿងបរិក្ខារ

☞ ការជ្រើសរើស និងគាំទ្រគ្រូបង្រៀន

☞ ធ្វើការសម្រេចចិត្តអំពីទីតាំងសាលារៀន និងកាលវិភាគ

☞ ត្រួតពិនិត្យ និងតាមដានការចូលរួមនិងការបង្រៀនរបស់គ្រូ

☞ បង្កើតគណៈកម្មការអប់រំភូមិ ដើម្បីគ្រប់គ្រងសាលារៀន

☞ ចូលរួមយ៉ាងសកម្មក្នុងការប្រជុំសាលាដើម្បីរៀនអំពីវឌ្ឍនភាពនៃការសិក្សារបស់កុមារ

☞ ផ្តល់ការបង្រៀនជំនាញ និងព័ត៌មានវប្បធម៌ក្នុងស្រុក

☞ ជួយកុមារក្នុងការសិក្សា

☞ ប្រមូលធនធានបន្ថែម និងដោះស្រាយបញ្ហាតាមរយៈការអប់រំ

☞ ផ្តល់សន្តិសុខដល់គ្រូដោយរៀបចំលំនៅដ្ឋានសមរម្យសម្រាប់ពួកគេ

☞ កំណត់កត្តាដែលរួមចំណែកដល់បញ្ហាការអប់រំ (Uemura, 1999) ។

## ២.៦ សន្និដ្ឋាន

ការអភិវឌ្ឍសាលារៀនត្រូវបានទទួលស្គាល់ជាការចាំបាច់ ដើម្បីការអប់រំមានសមត្ថភាពខ្ពស់សម្រាប់ជាការកសាងបុគ្គលិកលក្ខណៈមនុស្សឱ្យមានការអភិវឌ្ឍ ដើម្បីឱ្យក្លាយជាពលរដ្ឋថ្លៃថ្នូរ និងមានប្រយោជន៍ដល់សង្គមជាតិ។ ជាតុសំខាន់ៗនៃការអភិវឌ្ឍសាលារៀនរួមមាន ៖ គណៈគ្រប់គ្រងសាលារៀន កត្តាគ្រូ កត្តាសហគមន៍ កត្តាសាលារៀន និងកត្តាសិស្ស។ ជាការពិតការអភិវឌ្ឍសាលារៀនពិតជាមានសារៈសំខាន់ ការអភិវឌ្ឍសាលារៀនមួយទៅបានត្រូវមានការចូលរួម និងការសហការគ្រប់សមាភាពភាគីពាក់ព័ន្ធដទៃទៀតដើម្បីការអភិវឌ្ឍដោយរលូននិងនិរន្តរ៍ភាពយូរអង្វែង។ មួយវិញទៀត សាលារៀនមួយមានការអភិវឌ្ឍត្រូវមានការដឹកនាំដោយត្រឹមត្រូវ តម្លាភាព សុច្ចរិតភាព និងគណនេយ្យភាព ជាពិសេសមានការចូលរួមសហការពីសហគមន៍ និងភាគីដៃគូដទៃទៀត ដែលជាកម្លាំងចលករក្នុងការជួយជំរុញការអភិវឌ្ឍសាលារៀនឱ្យបានកាន់តែឆាប់រហ័យ និងវែងឆ្ងាយ។ សាលារៀនមានដំណើរការទៅបានដោយ

រលូន ត្រូវពឹងផ្អែកទៅលើគណៈគ្រប់គ្រងសាលារៀន ហើយក៏ត្រូវមានការគាំទ្រពីភាគីពាក់ព័ន្ធផងដែរ។ គណៈគ្រប់គ្រងសាលារៀនត្រូវមានគម្រោង និងផែនការមួយច្បាស់លាស់ ដើម្បីសម្រេចតាមការគ្រោងទុក។ មួយទៀតសហគមន៍ជា កម្លាំងចលករនិងជាប្រភពមិនចេះរីងស្ងួត ក្នុងការលើកកម្ពស់ការអភិវឌ្ឍសាលារៀន គុណភាពបង្រៀន រៀន ការរៀន និងលទ្ធផលសិក្សារបស់សិស្ស តាមរយៈការចូលរួមរៀបចំផែនការ ស្វែងរកធនធាន និងការពិនិត្យតាមដានវឌ្ឍនភាព ក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំឱ្យមានជីវិតស្រស់បំព្រង ប្រកបដោយសុខដុមនីយកម្ម ។ សហគមន៍គឺសំដៅទៅលើមាតាបិតារបស់សិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងរបស់សហគមន៍ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។ ការចូលរួមក្នុងការគ្រប់គ្រង ការអនុវត្តការងាររបស់មន្ត្រី និងការពិនិត្យតាមដាន ដែលសហគមន៍អាចពិនិត្យតាមដានម៉ោងបង្រៀន ដូចជាអវត្តមានគ្រូបង្រៀន សិស្សអវត្តមាន ថ្នាក់រៀនបើកយឺត ឬបិតមុនម៉ោង និងសាលារៀនបើក បិតមិនខុសប្រតិទិនសិក្សា។ ជារួមសហគមន៍អាចចូលរួមអភិវឌ្ឍសាលារៀនតាមរយៈចូលរួមជាវិភាគទានដើម្បីទ្រទ្រង់សាលារៀន គំនិតយោបល់ ស្វែងរកដៃគូសម្រាប់ឧបត្ថម្ភចំណូលថវិកា គ្រប់គ្រងថវិកា ថែរក្សាទ្រព្យសម្បត្តិសាលារៀន ចូលរួមសាងសង់ ជួសជុលសាលារៀន បំផុសកូនចៅឲ្យទៅសាលារៀន តាមដានការសិក្សារៀនសូត្ររបស់សិស្ស ចូលរួមតាមដានត្រួតពិនិត្យការអនុវត្តរបស់សាលារៀន ពង្រឹងពង្រីកសមត្ថភាពយល់ដឹងអំពីការអភិវឌ្ឍសាលារៀន។

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក ៣
# វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវស្ដីពី« ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ » គឺមានគោលបំណងដើម្បីសិក្សាឈ្វេងយល់ពីការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនក្នុងខេត្តកំពង់ស្ពឺ ព្រមទាំងកំណត់អំពីបញ្ហាប្រឈម និងអត្ថប្រយោជន៍របស់សហគមន៍ក្នុងការចូលរួមជាមួយសាលារៀន ។ នៅក្នុងជំពូកនេះអ្នកសិក្សានិងធ្វើការបង្ហាញអំពីឧបករណ៍ផ្សេងៗសម្រាប់ធ្វើការស្រាវជ្រាវដូចជា វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រក្នុងការជ្រើសរើសសំណាក និងប្រភេទសំណាក ព្រមទាំងវិធីបញ្ចូល និងវិភាគទិន្នន័យផងដែរ។ ក្នុងការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ បានបង្ហាញពីវិធីសាស្ត្រដែលត្រូវប្រើ ប្រភេទទិន្នន័យនិងប្រភពទិន្នន័យ។ នៅក្នុងការជ្រើសរើសសំណាក ជាការបង្ហាញការជ្រើសរើសចំនួនសំណាក ទីកន្លែងនៃការប្រមូលសំណាក មូលហេតុនៃការប្រមូលសំណាក និងរបៀបនៃការជ្រើសរើសសំណាក។ ចំពោះប្រភពទិន្នន័យវិញ បង្ហាញអំពីប្រភពទិន្នន័យដែលអ្នកសិក្សាស្រាវជ្រាវទៅសម្ភាសន៍ (អាចសម្ភាសន៍ដោយផ្ទាល់ រៀបចំជាកម្រងសំណួរ អង្កេតជាដើម)។ រីឯការប្រមូលទិន្នន័យ រៀបរាប់អំពីដំណើរការប្រមូលទិន្នន័យ បង្ហាញអំពីគោលបំណងនៃការប្រមូលទិន្នន័យ។ ម្យ៉ាងវិញទៀតការវិភាគទិន្នននន័យ បានប្រាប់អំពីដំណើរការទិន្នន័យ (ការសម្អាត បែងចែក និងវិភាគទិន្នន័យ) ប្រាប់ពីវិធីសាស្ត្រវិភាគទិន្នន័យ និងបកស្រាយទិន្នន័យ។ ជាចុងក្រោយនៃជំពូកបានលើកឡើង ក្រមសីលធម៌នៃការស្រាវជ្រាវ ហើយជានារក្សាការសម្ងាត់អត្តសញ្ញាណនៃការស្រាវជ្រាវនេះផងដែរ។

## ៣.១ គម្រោងវិភាគ

ការសិក្សាស្រាវជ្រាវនេះបានរៀបចំឡើងជាលក្ខណៈបែបបរិមាណវិស័យ ដើម្បីធ្វើការឱ្យស៊ីចង្វាក់គ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរនៃប្រធានបទ ដែលបានលើកមកសិក្សាស្រាវជ្រាវ។ ដើម្បីបំពេញលក្ខខណ្ឌក្នុងការបញ្ចប់ថ្នាក់បណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សារបស់វិទ្យាស្ថានជាតិអប់រំ ហើយបេក្ខជនមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីសរសេរគម្រោងស្រាវជ្រាវ ហើយបញ្ចប់ទាន់ពេលវេលាដើម្បី

ឡើងការពារនិក្ខេបទរបស់ខ្លួនតាមផែនការគ្រោងទុករបស់វិទ្យាស្ថាន។ ដែលមានអ្នកចូលរួមពាក់ព័ន្ធ ៤ ប្រភេទរួមមានដូចជា៖ (១) គណៈគ្រប់គ្រងសាលារៀន នាយក/ នាយិកា (២) គ្រូបង្រៀន លោកគ្រូ/អ្នកគ្រូ (៣) សិស្សានុសិស្ស និង (៤) សហគមន៍ (អាជ្ញាធរ មាតាបិតាសិស្ស អាណាព្យាបាល ជាដើម) ដើម្បីធ្វើកម្រងសំណួរសម្ភាស សម្រាប់កំណត់នូវការចូលរួមរបស់សហគន៍ក្នុងការអភិវឌ្ឍសាលារៀន។ ក្នុងការប្រមូលទិន្នន័យនេះផងដែរ គឺធ្វើឡើងនៅក្នុងខេត្តកំពង់ស្ពឺដោយផ្តោតទៅលើសាលាមធ្យមសិក្សាទុតិយភូមិចំនួនបីដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ដែលមានដូចជា វិទ្យាល័យហ៊ុនសែនភ្នំស្រួច វិទ្យាល័យម្ភៃឧសភា អ្នកប្អូនកញ្ញា និងវិទ្យាល័យហ៊ុនសែនចំបក់ ដែលជាសាលាគោលដៅសម្រាប់សិក្សាស្រាវជ្រាវ។

## ៣.២ ការប្រមូលទិន្នន័យ

បន្ទាប់ពីបានពិភាក្សា និងពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណ្ឌិតណែនាំគោល និងណែនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានធ្វើការរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ដោយកត្តាពេលវេលាអ្នកស្រាវជ្រាវបានធ្វើការប្រមូលទិន្នន័យ និងការសម្ភាសក្នុងសាលាគោលដៅ ហើយក្នុងអំឡុងពេលនោះការប្រមូលទិន្នន័យអ្នកសិក្សាស្រាវជ្រាវមានការសហការបានយ៉ាងល្អប្រសើរជាមួយ គណៈគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី សហគមន៍ ដើម្បីធ្វើការសម្ភាសន៍ និងបែងចែកកម្រងសំណួរ ដែលបានគ្រោងទុកតាមផែនការ។

លើសពីនេះទៀតនោះ អ្នកស្រាវជ្រាវបានចុះទៅធ្វើភារកិច្ចជួបជាមួយគណៈគ្រប់គ្រងសាលាគោលដៅ និងអាជ្ញាធរដែនដីដើម្បីជូនលិខិតឧទ្ទេសនាម ឯកសារពាក់ព័ន្ធ និងសុំការអនុញ្ញាតដើម្បីធ្វើការជួប ក្រុមដែលជាគោលដៅដើម្បធ្វើការផ្តល់កម្រងសំណួរ និងការសម្ភាសន៍តាមប្រភេទកម្រងសំណួរដែលបានគ្រោងទុកជាមុន។ អ្នកចូលរួមមាន គណៈគ្រប់គ្រងនាយក/នាយិកា គ្រូបង្រៀន(លោកគ្រូ/អ្នកគ្រូ) សិស្សានុសិស្ស អាជ្ញាធរមូលដ្ឋាន សហគមន៍ និងអ្នកពាក់ព័ន្ធ ដោយមានចំនួន និងពេលវេលាមួយកំណត់យ៉ាងជាក់លាក់។

**ការប្រមូលទិន្នន័យចម្បង៖** ខ្ញុំបាទបានធ្វើកម្រងសំណួរដើម្បីសម្ភាសន៍ តាមរយៈឱ្យចំនួនសំណាកបំពេញជ្រើសរើស និងឆ្លើយសំណួរមួយចំនួន ហើយវាជាទិន្នន័យដោយផ្ទាល់បានមកពីការសាកសួរ និង

សម្ភាសន៍ ជាមួយអ្នកពាក់ព័ន្ធទាំងឡាយ។ ហើយការចុះប្រមូលទិន្នន័យ គឺបានប្រើប្រាស់រយៈពេលសរុប ២ អាទិត្យដោយគិតចាប់ផ្តើម រហូតដល់ថ្ងៃដែលទទួលបានកម្រងសំណួរពី គណៈគ្រប់គ្រងសាលារៀន លោកគ្រូ/អ្នកគ្រូ សិស្សានុសិស្ស អាជ្ញាធរមូលដ្ឋាន និងសហគមន៍។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

នៅក្នុងឧបករណ៍ស្រាវជ្រាវនេះផងដែរ គឺជាឧបករណ៍មួយសម្រាប់ធ្វើការឆ្លើយសំណួរស្រាវជ្រាវ ដែលអាចឱ្យអ្នកស្រាវជ្រាវមានលទ្ធភាពក្នុងការដំណើរការ ឬក៏បន្តដំហានរបស់ខ្លួនដើម្បីប្រមូលទិន្នន័យ ដែលចង់បាន។ ឧបករណ៍ស្រាវជ្រាវ គឺជាមធ្យោបាយមួយរបស់អ្នកស្រាវជ្រាវប្រើដើម្បីទទួលបានព័ត៌មាន សំខាន់ៗប្រកបដោយប្រសិទ្ធភាពពីការប្រមូលទិន្នន័យ។ ហេតុនេះក្នុងការប្រមូលទិន្នន័យ តាមរយៈការ សិក្សាស្រាវជ្រាវខាងលើ ដោយផ្តោតទៅលើប្រធានបទ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរ និងការ សម្ភាសន៍ជាឧបករណ៍ស្រាវជ្រាវ ដែលសំណួរមានបួនប្រភេទក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណ វិស័យ ជូនចំពោះគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស និងសហគមន៍ ដោយផ្តោតទៅ លើទ្រឹស្តីពាក់ព័ន្ធនានាដូចជា ការរៀបចំគម្រោងផែនការយុទ្ធសាស្ត្រ និងលើកទិសដៅផែនការសម្រាប់ធ្វើ ការអភិវឌ្ឍសាលារៀន បណ្តាញទំនាក់ទំនង និងការគ្រប់គ្រងរចនាសម្ព័ន្ធអប់រំ ការសហការប្រកបដោយ ចីរភាពជាមួយភាគីពាក់ព័ន្ធ ដំណើរការរៀន និងបង្រៀន ការអនុវត្តកម្មវិធីសិក្សា ការតាមដានវាយតម្លៃ លទ្ធផលនៃការអនុវត្ត ការទំនាក់ទំនងនិងការចូលរួមជាវិភាគទានពីសហគមន៍ដើម្បី អភិវឌ្ឍន៍សាលារៀន និងកិច្ចការងាយផ្សេងៗទៀត ស្របជាមួយគ្នាដែរ កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គលនិង ក្រុមជាមួយគ្រប់ក្រុមគោលដៅទាំងអស់ ព្រមទាំងរក្សានូវការសម្ងាត់ និងក្រមសីលធម៌ខ្ពស់ជូនដល់អ្នក ដែលបានចូលរួមផ្តល់ចម្លើយ។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

ក្នុងកម្រិតចង្អុលបង្ហាញនេះ គឺត្រូវបានប្រើប្រាស់ក្នុងទម្រង់ក្នុងកម្រងសំណួរស្រាវជ្រាវ ដើម្បីធ្វើការ ប្រមូលទិន្នន័យពីភាគីដែលពាក់ព័ន្ធលើការឆ្លើយតបក្នុងកម្រិតតួលេខ ឬក៏ការវាស់ស្ទង់មួយជាក់លាក់។ លើសពីនេះទៀតសោត កម្រិតចង្អុលបង្ហាញអាចបំពេញដោយគូសផ្ទាល់នៅលើកម្រងសំណួរ ក្នុងការ

សិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិតសំណួរ មានដូចជា តិចតួចណាស់ តិចតួច មធ្យម ច្រើន និងច្រើនណាស់ ដែលជាកម្រិតវាស់ស្ទង់នៃសំណួរនីមួយៗ។ ការវាយតម្លៃនៃ ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ គឺដើម្បីប្រើប្រាស់តម្លៃបកស្រាយអត្ថន័យតម្លៃមធ្យមរបស់កម្រងសំណួរ តាមបែបអត្រាវាយតម្លៃកំណត់ពិន្ទុលើតម្លៃមធ្យម គឺយកតាមលំនាំកម្រិតនៃពិន្ទុរបស់លោក Panya, Wernatawee &Workham (2017) ដោយបានបង្ហាញលទ្ធផលដូចខាងក្រោម៖

- Mean = ៤.៥១ - ៥.០០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតខ្ពស់បំផុត
- Mean = ៣.៥១ - ៤.៥១ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតខ្ពស់
- Mean = ២.៥១ - ៣.៥១ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតមធ្យម
- Mean = ១.៥១ - ២.៥០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតទាប
- Mean = ១.០០ - ១.៥០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតទាបបំផុត

ការតម្លៃបកស្រាយអត្ថន័យតម្លៃមធ្យមរបស់កម្រងសំណួរ តាមបែបអត្រាវាយតម្លៃកំណត់ពិន្ទុលើតម្លៃមធ្យមតាម Likert Scale $\frac{n-1}{n}$ ដែល $\frac{5-1}{5} = 0.80$

- Mean = ៤.២១ - ៥.០០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតខ្ពស់បំផុត
- Mean = ៣.៤១ - ៤.២០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតខ្ពស់

- Mean = ២.៦១ - ៣.៤០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតមធ្យម
- Mean = ១.៨១ - ២.៦០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតទាប
- Mean = ១.០០ - ១.៨០ ក្នុងន័យចង់បង្ហាញថា កម្រិតនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ នៅកម្រិតទាបបំផុត

ក្នុងកម្រិតនៃការវាយតម្លៃ បានកំណត់តាមការវាយតម្លៃដោយគិតជាភាគរយ (%) ផ្អែកតាមការគណនាក្នុងការដាក់កម្រិតនិទ្ទេសពិន្ទុសិស្សក្នុងសៀវភៅសិក្ខាគារិកគឺ៖

តម្លៃចាប់ពី ០% រហូតដល់ ២៥% កំណត់ថាកម្រិតខ្សោយណាស់

តម្លៃចាប់ពី ២៦% រហូតដល់ ៤៩% កំណត់ថាកម្រិតខ្សោយ

តម្លៃចាប់ពី ៥០% រហូតដល់ ៦៦% កំណត់ថាកម្រិតមធ្យម

តម្លៃចាប់ពី ៦៧% រហូតដល់ ៨៤% កំណត់ថាកម្រិតល្អបង្គួរ

តម្លៃចាប់ពី ៨៥% រហូតដល់ ១០០% កំណត់ថាកម្រិតល្អ និងល្អប្រសើរណាស់។

បើធ្វើការប្រៀបធៀបភាគរយនៃកម្រិតពិន្ទុតាមតម្លៃមធ្យមរបស់ បូនធាំ ស្រីសា អាត បានឱ្យឃើញថាមានកម្រិតលម្អៀងភាគរយគ្នាបន្តិចចាប់ពីតម្លៃកម្រិតមធ្យម ទៅតម្លៃកម្រិតខ្ពស់បំផុតដែលខុសគ្នា៤%។

- តម្លៃមធ្យមចាប់ពី ១.០០ រហូតដល់ ១.៥០ បានកំណត់ថាកម្រិតទាបបំផុត ស្មើនឹងតម្លៃពី ០% ដល់៣០%
- តម្លៃមធ្យមចាប់ពី ១.៥០ រហូតដល់ ២.៥០ បានកំណត់ថាកម្រិតទាប ស្មើនឹងតម្លៃពី៣០.១% ដល់៥០%
- តម្លៃមធ្យមចាប់ពី ២.៥១ រហូតដល់៣.៥០ បានកំណត់ថាកម្រិតមធ្យម ស្មើនឹងតម្លៃពី៥០.១% ដល់៧០%

- តម្លៃមធ្យមចាប់ពី៣.៥១% រហូតដល់៤.៥០ បានកំណត់ថាកម្រិតខ្ពស់ ស្មើនឹងតម្លៃពី៧០.១% ដល់៩០%
- តម្លៃមធ្យមចាប់ពី៤.៥១រហូតដល់៥.០បានកំណត់ថាកម្រិតខ្ពស់បំផុតស្មើនឹងតម្លៃពី៩០.១% ដល់១០០%

**៣.៣.២ កម្រងសំណួរ**

ក្នុងគោលបំណងនៃកម្រងសំណួរស្រាវជ្រាវនេះ គឺជាការប្រមូលទិន្នន័យនេះ ដើម្បីសិក្សាឈ្វេងយល់ពីការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនក្នុងខេត្តកំពង់ស្ពឺ នឹងការកំណត់អំពីបញ្ហាប្រឈមរបស់សហគមន៍ និងអត្ថប្រយោជន៍របស់សហគមន៍ក្នុងការចូលរួមជាមួយសាលារៀន។ ហើយទិន្នន័យដែលប្រមូលបានមក គឺប្រើប្រាស់សម្រាប់តែការសិក្សានេះតែប៉ុណ្ណោះ។

**៣.៣.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន**

ក្នុងប្រភេទកម្រងសំណួរនេះ គឺអ្នកសិក្សាស្រាវជ្រាវបានធ្វើការរៀបចំជា ៤ផ្នែកធំៗ ហើយផ្នែកទី១ គឺនិយាយអំពី ព័ត៌មានទូទៅ ដែលក្នុងផ្នែកនេះផងដែរចែកចេញជា១០ចំណុចតូចៗ ដែលទាក់ទងនឹង ១. ភេទ ២.ស្រុក ៣. ខេត្ត ៤.តំបន់ ៥.អាយុ ៦.តួនាទី ៧.បទពិសោធន៍ក្នុងតួនាទីការងារបច្ចុប្បន្ន ៨. សញ្ញាបត្រទទួលបានចុងក្រោយ ៩.បទពិសោធន៍ក្នុងវិស័យអប់រំ ១០.ការទទួលបានវគ្គបណ្តុះបណ្តាល ឬ វិក្រឹត្យការលើផ្នែករៀបចំផែនការ និងការទំនាក់ទំនងជាមួយសហគមន៍។ ផ្នែកទី២ ការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ ដែលមានចែកចេញជាបីផ្នែកមានដូចជា៖ ក. ភាពជាអ្នកដឹកនាំការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀនជាមួយសហគមន៍ ខ. ការប្រាស្រ័យទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដើម្បីទទួលបានលទ្ធផលល្អប្រសើរ គ. បង្កើតកម្មវិធីជួបជុំ និងពិគ្រោះយោបល់រវាងមាតាបិតាសិស្ស និងគណៈគ្រប់គ្រងសាលា។ នៅផ្នែកទី៣ ការបង្កើតជាបណ្តាញទំនាក់ទំនង និងគ្រប់គ្រងដឹកនាំសម្របសម្រួលជាមួយសហគមន៍ ចែកចេញជាប្រាំគឺ ក. ការសហការ និងទំនាក់ទនងជាមួយសហគមន៍ ខ. ការបង្កើតបណ្តាញសកម្មភាព និងការចរចាសម្រុះសម្រួលជាមួយសហគមន៍ គ. ផ្នែកដោះស្រាយវិវាទ និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ឃ.ការកសាងការបង្កើតគំនិតរួមគ្នាដើម្បី

អភិវឌ្ឍន៍សាលា ង.ផែនការអភិវឌ្ឍសាលារៀននិងការអនុវត្តជានិរន្តរ៍ភាពដើម្បីការអប់រំទាំងអស់គ្នា។ ផ្នែកទី៤ ការបង្កើតដៃគូសហការប្រកបដោយការអភិវឌ្ឍជាមួយអ្នកពាក់ព័ន្ធ ចែកចេញជាពីរគឺ ក.បរិយាកាសគាំពារសម្រាប់កម្មវិធីពីសហគមន៍ ខ. ការបោះផ្សាយនិងការប្រកាសលទ្ធផលទិន្នន័យដល់ភាគីពាក់ព័ន្ធ។ ហើយនៅផ្នែកចុងក្រោយនៃកម្រងសំណួរការសម្ភាសន៍ បានបញ្ចូលដូចជា ផ្នែកទី១ ការចូលរួមនិងការសហការដើម្បីទទួលបានការអភិវឌ្ឍសាលារៀនសម្រាប់សហគមន៍ ដែលមាន៣ សំណួរ។ ផ្នែកទី២ ការបង្កើតជាបណ្តាញទំនាក់ទំនង និងគ្រប់គ្រងដឹកនាំសម្របសម្រួលជាមួយសហគមន៍ដែលមាន២ សំណួរ។ ផ្នែកទី៣ ការបង្កើតដៃគូសហការប្រកបដោយការអភិវឌ្ឍជាមួយអ្នកពាក់ព័ន្ធ ដែលមានពីរសំណួរ និងមានសំណូមពរ ឬមតិយោបល់បន្ថែមទៀត ដើម្បីទទួលបានព័ត៌មានបន្ថែមក្នុងការយកមកវិភាគបានកាន់តែស៊ីជម្រៅ។

### ៣.៣.២.២ កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ (គ្រូបង្រៀន)

ស្ថិតនៅក្នុងផ្នែកនៃកម្រងសំណួរនេះផងដែល អ្នកសិក្សាស្រាវជ្រាវបានធ្វើការរៀបចំកម្រងសំណួរចែកចេញជា៤ផ្នែកធំៗ។ ដែលផ្នែកទី ១ ព័ត៌មានទូទៅរបស់លោកគ្រូអ្នកគ្រូ ដែលក្នុងផ្នែកនេះផងដែរចែកចេញជា១០ចំណុចតូចៗ ដែលទាក់ទងនឹង ១. ភេទ ២.ស្រុក ៣. ខេត្ត ៤.តំបន់ ៥.អាយុ ៦.តួនាទី ៧.បទពិសោធន៍ក្នុងតួនាទីការងារបច្ចុប្បន្ន ៨.សញ្ញាបត្រទទួលបានចុងក្រោយ ៩.បទពិសោធន៍ក្នុងវិស័យអប់រំ ១០.ការទទួលបានវគ្គបណ្តុះបណ្តាល ឬវិក្រឹត្យការលើផ្នែករៀបចំផែនការ និងការទំនាក់ទំនងជាមួយសហគមន៍។ ផ្នែកទី២ ក្នុងដំណើរការនៃការរៀននិងបង្រៀន ដែលបានចែកចេញជា ២.១ ការប្រតិបត្តិនៃកម្មវិធីសិក្សា ២.២ ការដំណើរការសម្រាប់ការរៀននិងបង្រៀនតាមកម្រិតថ្នាក់ ២.៣ វិធីសាស្រ្តនិងសកម្មភាបង្រៀននិងរៀន បានចែកចេញជា ក.វិធីសាស្រ្តបង្រៀន ខ.ការអនុវត្តជាក់ស្តែងក្នុងដំណើរការនិងសកម្មភាពបង្រៀន ២.៤ វង្វាយតម្លៃនិងលទ្ធផល។ ផ្នែកទី៣ ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ។ ផ្នែកទី៤ បញ្ហាប្រឈមនិងសំណូមពរ ដែលមានចែកចេញជាបីសំណួរ បញ្ហាប្រឈមដែលជាឧបសគ្គក្នុងការជំរុញការចូលរួមរបស់សហគមន៍ជាមួយសាលារៀន សហគមន៍ចូលរួមជាមួយសាលារៀន

និងសំណួរចុងក្រោយ សំណូមពរឬក៏មតិយោបល់បន្ថែមដើម្បីជំរុញការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀនឱ្យកាន់តែមានប្រសិទ្ធភាព។

### ៣.៣.២.៣ កម្រងសំណួរសម្រាប់សហគមន៍ និងអ្នកពាក់ព័ន្ធ

ស្ថិតនៅក្នុងផ្នែកនៃកម្រងសំណួរនេះផងដែរ អ្នកសិក្សាស្រាវជ្រាវបានធ្វើការរៀបចំកម្រងសំណួរចែកចេញជា៣ ផ្នែកធំៗ។ ផ្នែកទី១ ព័ត៌មានទូទៅ ដែលមានចែងចេញជា៣ចំណុចគឺ ១.ភេទ ២.មកពីភូមិ ឃុំ ស្រុក និង ៣.អាយុ។ ផ្នែកទី២ ព័ត៌មានទូទៅនៃការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលមាន២០ សំណួរសំខាន់ៗ។ ផ្នែកទី៣ បញ្ហាប្រឈម និងសំណូមពរ ឬមតិយោបល់បន្ថែម ដែលមានចំណុចដូចជា ៣.១ បញ្ហាប្រឈមផ្សេងៗ ៣.២ សំណូមពរ ឬមតិយោបល់ និងដំណោះស្រាយដើម្បីអាចដោះស្រាយបញ្ហាខាងលើ។

### ៣.៣.២.៤ កម្រងសំណួរសម្រាប់សិស្ស

ស្ថិតនៅក្នុងផ្នែកនៃកម្រងសំណួរនេះផងដែល អ្នកសិក្សាស្រាវជ្រាវបានធ្វើការរៀបចំកម្រងសំណួរចែកចេញជា៤ ផ្នែកធំៗ។ ផ្នែកទី១ ព័ត៌មានទូទៅ ដែលចែកចេញជា៣ ចំណុចសំខាន់ៗគឺ ១.ភេទ ២. កម្រិតថ្នាក់ និង៣.អាយុ។ ផ្នែកទី២ ព័ត៌មានទូទៅអំពីការសិក្សារបស់សិស្ស ដែលមាន២ចំណុច គឺ ២.១ ការប្រតិបត្តិនៃការបង្រៀននិងរៀន មាន២៩សំណួរ និង ២.២ វង្វាយតម្លៃលទ្ធផលនៃការសិក្សា មាន៧ ចំណុច។ ផ្នែកទី៣ ការង្កើតទំនាក់ទំនងនិងការសហការគ្នា មាន៨ សំណួរសំខាន់ៗ។ ផ្នែកទី៤ បញ្ហាប្រឈមនិងសំណូមពរ ចែកជា២ចំណុចគឺ ៤.១ បញ្ហាប្រឈមផ្សេងៗ និង ៤.២ សំណូមពរ ឬមតិយោបល់បន្ថែមរបស់សិស្ស។

## ៣.៤ ការជ្រើសរើសភាគសំណាក

ដើម្បីឱ្យការប្រមូលសំណាកស្របជាមួយប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវវិធីសាស្ត្រក្នុងការជ្រើសរើសភាគសំណាក ទៅតាមគោលបំណងក្នុងការប្រមូលទិន្នន័យ ដោយដៅយកតែភាគសំណាកនីមួយៗ ដែលអ្នកសិក្សាស្រាវជ្រាវបានមានគំនិតយល់ឃើញថា សំណាកទាំងនោះអាចជួយផ្តល់នូវទិន្នន័យបានយ៉ាងជាក់លាក់ ហើយវាបានឆ្លើយតបជាមួយប្រធានបទស្រាវជ្រាវ និងសិក្សាបានស៊ីជម្រៅ។

អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រជ្រើសរើសសំណាកងាយៗ (Convenience Sampling) គឺជាវិធីសាស្ត្រដែលមិនមានប្រូបាប៊ីលីតេ ដោយគ្មានការកំណត់លក្ខខណ្ឌ ងាយស្រួលក្នុងការទទួលបានព័ត៌មាន ព្រោះវាងាយស្រួលបំផុតសម្រាប់អ្នកស្រាវជ្រាវក្នុងការសម្ភាសន៍។

ដោយយោងតាមករណីសិក្សាស្រាវជ្រាវនេះ បានកំណត់យកការជ្រើសរើសសំណាក ត្រូវបានធ្វើការគណនាតាមរូបមន្ត យ៉ាមេន Yamane (1976) នៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ ដែលមានចំនួនវិទ្យាល័យដែលស្ថិតនៅគម្រោង GEIP សរុប 7 វិទ្យាល័យនៅទូទាំងខេត្តកំពង់ស្ពឺ។ តាមរូបមន្ត $n = \frac{N}{1+Ne2}$

n = ចំនួនវិទ្យាល័យដែលត្រូវជ្រើសរើសយកមកសម្ភាសន៍

N = ចំនួនវិទ្យាល័យសរុបនៅក្នុងការសម្ភាសន៍នៃខេត្តកំពង់ស្ពឺ

e = ជាតម្លៃប្រែប្រួល %

ការគណនាលើចំនួនវិទ្យាល័យ ដែលត្រូវជ្រើសរើសមកសម្ភាសន៍ក្នុងចំណោមវិទ្យាល័យស្ថិតនៅក្នុងគម្រោងទាំង៧ វិទ្យាល័យ។

យើងបាន $n = \frac{7}{1+(7*0.05^2)}$ = 6 វិទ្យាល័យ

ដោយផ្អែកលើចំនួនសំណាកខាងលើមាន ៦ វិទ្យាល័យ ប៉ុន្តែរយៈពេលនៃការសិក្សាស្រាវជ្រាវមានកាលកំណត់ អ្នកស្រាវជ្រាវបានយកជាមធ្យមនៃវិទ្យាល័យនោះនៅត្រឹមតែ ៣ វិទ្យាល័យដែលជាវិទ្យាល័យគោលដៅសម្រាប់មកសិក្សាស្រាវជ្រាវ ដែលជាតំណាងវិទ្យាល័យស្ថិតនៅក្នុងគម្រោង GEIP ក្នុងទូទាំងខេត្តកំពង់ស្ពឺទាំងមូល។

ដោយឡែកជាក់ស្តែងតាមលទ្ធភាព និងពេលវេលា ខ្ញុំបាទបានធ្វើការចុះសម្ភាសន៍ដោយប្រើប្រាស់កម្រងសំណួរបានត្រឹមតែ ២៧៩ នាក់ប៉ុណ្ណោះ ដែលនូវក្នុងនោះមានទិន្នន័យដំបូងដែល ខ្ញុំបាទបានមកពីការចុះទៅស្រាវជ្រាវដោយផ្ទាល់ចុះទៅស្រាវជ្រាវក្នុងខេត្តកំពង់ស្ពឺដូចខាងក្រោម៖

- ការស្ទង់មតិពីគណៈគ្រប់គ្រងសាលារៀនចំនួន ០៩នាក់
- ទទួលបានពីលោកគ្រូ អ្នកគ្រូបង្រៀន ៦០ នាក់ទាំងបីវិទ្យាល័យគោលដៅ

– ទទួលបានពីសហគមន៍ដែលជាមាតាបិតាសិស្ស រួមទាំងអ្នកពាក់ព័ន្ធ គណៈគ្រប់គ្រងសាលារៀន សរុប ៦០ នាក់

– ទទួលបានពីសិស្សានុសិស្សថ្នាក់ទី១០ ដល់ទី១២ មានចំនួន ១៥០ នាក់

មួយវិញទៀត ភាគសំណាកដែលអ្នកស្រាវជ្រាវឃើញចន្លោះដែលអាច ទទួលយកបាននិងជឿទុកចិត្តបាននោះ គឺគណៈគ្រប់គ្រងសាលារៀនចំនួន ០៩នាក់ គ្រូបង្រៀន ៦០នាក់ សិស្សានុសិស្សថ្នាក់ទី១០ ដល់ទី១២ មានចំនួន ១៥០ នាក់ និងសហគមន៍ដែលជាមាតាបិតាសិស្ស រួមទាំងអ្នកពាក់ព័ន្ធ គណៈការគ្រប់គ្រងសាលារៀនសរុប ៦០ នាក់។

**តារាង ១.១ ទិន្នន័យចំនួនសំណាក**

| + អ្នកចូលរួមក្នុងការសម្ភាសន៍ | + ចំនួនសំណាក | + វិទ្យាល័យគោលដៅចំនួន៣៖ |
|---|---|---|
| - គណៈគ្រប់គ្រងសាលារៀន | ៩ នាក់ | - វិទ្យាល័យហ៊ុនសែនភ្នំស្រួច |
| - គ្រូបង្រៀន | ៦០ នាក់ | - វិទ្យាល័យ ម្តេបួន កញ្ញា និង |
| - សហគមន៍ | ៦០ នាក់ | - វិទ្យាល័យហ៊ុនសែនចំបក់ |
| - សិស្ស | ១៥០ នាក់ | |

**កិច្ចសម្ភាសន៍ជាមួយក្រុមគោលដៅនិងអាទិ៍ភាពទី១** ក្នុងកិច្ចការសម្ភាសន៍ ដោយផ្ទាល់ជាមួយគណៈគ្រប់គ្រងសាលារៀន និងការប្រគល់ជូននូវកម្រងសំណួរដល់ លោកនាយក/នាយិកា លោកនាយករង/នាយិការង ដើម្បីបំពេញនូវកម្រងសំណួរទទួលបាននូវព័ត៌មានបន្ថែមទៀត។ ក្នុងបុព្វហេតុដែលអ្នកសិក្សាស្រាវជ្រាវជ្រើសរើសលោកនាយក/នាយិកា លោកនាយករង/នាយិការង ក្នុងការប្រមូលទិន្នន័យនិងផ្តល់ព័ត៌មានទៅលើការស្រាវជ្រាវនេះ ដោយសារតែលោក/លោកស្រីជាអ្នកដែលអាចផ្តល់នូវព័ត៌មានទូទៅ និងជាក់លាក់ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ ការប្រាស្រ័យទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ ការបង្កើតបណ្តាញទំនាក់ទំនង និងការគ្រប់គ្រងដឹកនាំសម្របសម្រួលជាមួយសហគមន៍ដោយផ្ទាល់ និងការបង្កើតសហការដៃគូ ជាមួយអ្នកពាក់ព័ន្ធផ្សេងៗទៀត។ ពិសេសជាងនេះទៀតនោះគឺ លោក/លោកស្រីគាត់ជាអ្នកទទួលខុសត្រូវអនុវត្តន៍ផែនការដោយផ្ទាល់ ការ

តាមដាន ការត្រួតពិនិត្យ ក្នុងការអភិវឌ្ឍសាលារៀនជាប្រចាំថ្ងៃ និងព័ត៌មានពាក់ព័ន្ធជាមួយនឹងសហគមន៍ និងសិស្ស ព្រមទាំងព័ត៌មានផ្សេងទៀត។

**កិច្ចសម្ភាសន៍ជាមួយក្រុមគោលដៅនិងអាទិ៍ភាពទី២** នៅក្នុងការសម្ភាសន៍លោកគ្រូ អ្នកគ្រូ ដែលមានតួនាទីជាប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស សមាជិក និងគ្រូទទួលបន្ទុកថ្នាក់ ដោយអ្នកសិក្សាស្រាវជ្រាវបានប្រគល់ជូននូវកម្រងសំណួរដែលបានរៀបចំរួចរាល់ ឱ្យលោកគ្រូ អ្នកគ្រូគាត់បំពេញកម្រងសំណួរដោយផ្ទាល់ ដោយអ្នកស្រាវជ្រាវមើលឃើញថាពួកគាត់ជាអ្នកអនុវត្តន៍ប្រតិបត្តិដោយផ្ទាល់នូវកម្មវិធីសិក្សា ដំណើរការបង្រៀននៅក្នុងថ្នាក់រៀន និងរៀនសម្រាប់ថ្នាក់នីមួយៗ ដំណើរការសម្រាប់ការរៀននិងបង្រៀនតាមកម្រិតថ្នាក់ វិធីសាស្ត្រនិងសកម្មភាពបង្រៀន ការវង្វាយតម្លៃការសិក្សារបស់សិស្ស ការបង្កើតទំនាក់ទំនងជាមួយសហគមន៍និងអ្នកពាក់ព័ន្ធ ដែលជាការឆ្លើយតបប្រធានបទ និងគោលបំណងខាងលើ។

**កិច្ចសម្ភាសន៍ជាមួយក្រុមគោលដៅនិងអាទិ៍ភាពទី៣** អ្នកស្រាវជ្រាវបានធ្វើការជ្រើសរើសអ្នកពាក់ព័ន្ធដើម្បីយកមកសម្ភាសន៍មានដូចជា (មាតាបិតាសិស្ស អាណាព្យាបាលសិស្ស អាជ្ញាធរមូលដ្ឋាន និងគណៈកម្មាធិការគ្រប់គ្រងសាលារៀន សរុប ៥០ នាក់ដើម្បីយកមកធ្វើជាសំណាកដោយចាប់ដោយចៃដន្យដោយហេតុថាពួកគាត់ជាអ្នកដែលបានចូលរួមដើម្បីអភិវឌ្ឍន៍សាលារៀនជាប្រចាំ ស្របជាមួយគ្នានោះដែរប្រាកដជាពួកគាត់អាចមានលទ្ធភាពក្នុងការផ្តល់ព័ត៌មានបន្ថែម និងផ្សេងៗទៀតដែលទាក់ទងនិងប្រធានបទបានគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យអ្នកសិក្សាយកមកវិភាគបានស៊ីជម្រៅ និងបានគ្រប់ជ្រុងជ្រោយ។

**កិច្ចសម្ភាសន៍ជាមួយក្រុមគោលដៅនិងអាទិ៍ភាពទី៤** អ្នកស្រាវជ្រាវបានជ្រើសរើស និងប្រគល់សន្លឹកកិច្ចសម្ភាសន៍ដល់សិស្សចំនួន ១៥០ នាក់ ក្នុងការធ្វើជាសំណាក់ ដែលសិស្សបានបំពេញកម្រងសំណួរ ដោយហេតុដែលបានជ្រើសរើសពួកគាត់ដោយសារតែ ពួកគាត់ជាអ្នករៀនជួបផ្ទាល់ជាមួយលោកគ្រូ អ្នកគ្រូ ហើយពួកគាត់បានចូលរួមចំណែកយ៉ាងខ្លាំងដើម្បីជួយផ្សព្វផ្សាយ និងជាកត្តាជាលិករក្នុងការជំរុញឱ្យមានការចូលរួមពីសហគមន៍ដើម្បីអភិវឌ្ឍសាលារៀនជាប់ជាប្រចាំ។

## ៣.៥ ការវិភាគទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទសំណួរស្រាវជ្រាវ ដែលបានកំណត់ខាងលើ អ្នកសិក្សាស្រាវជ្រាវបានកំណត់ដោយការស្រាវជ្រាវនេះ និងប្រើសប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ (Quantitative Approach) ដើម្បីប្រមូលទិន្នន័យពីក្រុមគោលដៅនីមួយៗ (ក្រុមគោលដៅទាំងបួនខាងលើ)។ ទិន្នន័យត្រូវបានវិភាគដោយធ្វើចំណាត់ក្រុមទៅតាមប្រធានបទរួមធំ និងប្រធានបទរងបន្តបន្ទាប់។ បន្ទាប់មកប្រធានបទធំ និងរងទាំងនោះត្រូវបានប្រើប្រាស់សម្រាប់ការសរសេរពន្យល់ បកស្រាយពីលទ្ធផល និងទាញសេចក្តីសន្និដ្ឋាន ព្រមទាំងទាញចេញនូវរូបភាពរួមដើម្បីឈានទៅកំណត់ឱ្យបានច្បាស់លាស់កត្តាដែលឱ្យសហគមន៍ចូលរួម បញ្ហាប្រឈមរបស់សហគមន៍ក្នុងការចូលរួមជាមួយសាលារៀន។ បន្ថែមទៀតនោះ ទិន្នន័យបែបបរិមាណវិស័យដែលធ្វើការប្រមូលបានពីកម្រងសំណួរដែលបានមកពីការបំពេញ ដោយភាគសំណាកទាំងអស់ ដំបូងបង្អស់អ្នកស្រាវជ្រាវបានរៀបចំដាច់ដោយឡែក ទៅតាមប្រភេទភាគសំណាកនីមួយៗរួមមាន គណៈគ្រប់គ្រងសាសា(នាយក/នាយិកា) គ្រូបង្រៀន(លោកគ្រូ/អ្នកគ្រូ) សិស្សានុសិស្ស និងសហគមន៍ (អាណាព្យាបាល មាតាបិតា អាជ្ញាធរពាក់ព័ន្ធ)។

អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្មវិធី Microsoft Excel ដើម្បីសង់តារាងក្រាហ្វិកក្នុងការវិភាគទិន្នន័យតាមបែបបរិមាណវិស័យ ក្នុងការបង្ហាញកម្រិតចម្លើយនៃសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការចូលរួមរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស សហគមន៍ (អាណាព្យាបាល មាតាបិតា អាជ្ញាធរពាក់ព័ន្ធ)ដោយធ្វើការគិតជាមធ្យមភាគ និងភាគរយ ដើម្បីវិភាគទិន្នន័យឱ្យបានគ្រប់ជ្រុងជ្រោយ។

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

# ជំពូក ៤
# លទ្ធផល និងការពិភាក្សា

យោងទៅតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ តាមរយៈព័ត៌មានដែលអ្នកស្រាវជ្រាវបានប្រមូលបានពាក់ព័ន្ធនិងការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ និងយោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់អ្នកស្រាវជ្រាវមុនៗកន្លងមក អ្នកស្រាវជ្រាវបានឃើញនូវកត្តាដែលចូលរួមមួយចំនួនរបស់សហគមន៍។ ករណីសិក្សានេះមានហេតុផលមួយចំនួនដែលបានបង្ហាញ ចេញមកភ្លាមៗតាមរយៈព័ត៌មានប្រមូលបាន ហើយខ្លះទៀតតម្រូវឱ្យមានការវិភាគមានលក្ខណៈស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។ មួយវិញទៀតអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបកស្រាយ និងពិភាក្សានូវអ្វីៗដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួរដែលជាពហុជ្រើសរើស និងកម្រងសំណួរបើកដែលជាការសម្ភាសន៍ក្រុមគោលដៅ ដែលរួមមានគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនសហគមន៍ សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធដទៃទៀត។

## ៤.១ ការវិភាគលើកម្រងសំណួរគណៈគ្រប់គ្រងសាលា

### ៤.១.១ ផ្នែកទី១៖ ព័ត៌មានទូទៅ

ក្នុងទិន្នន័យដែលទទួលបានពីកម្រងសំណួរនៅក្នុងផ្នែកទី១នេះ ផ្តោតទៅលើព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន ដែលបានចូលរួមក្នុងការបំពេញកម្រងសំណួរ ដោយធ្វើការបែងចែកជាចំណាត់ ថ្នាក់ទៅតាមប្រភេទស្ថិតិបែបពណ៌នា ដែលមានដូចជា ភេទ ស្រុក ខេត្ត តំបន់ អាយុ តួនាទី បទពិសោធន៍ក្នុងតួនាទី សញ្ញាបត្រ បទពិសោធន៍ក្នុងវិស័យអប់រំ ការបណ្តុះបណ្តាល SEIP OR GEIP និងទំនាក់ទំនងជាមួយសហគមន៍។

## ក្រាបទី១ ៖ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន




ក្រាបទី១ ខាងលើនេះបង្ហាអំពីការចូលរួមបំពេញកម្រងសំណួររបស់គណៈគ្រប់គ្រងដែលរួមមានភេទប្រុស ៧៧.៧៨% ភេទស្រី ២២.២២% មានចំនួនស្រុកបីគឺ ភ្នំស្រួច៣៣.៣៣% សំរោងទង ៣៣.៣៣% និងបសេដ្ឋ៣៣.៣៣% ដែលស្ថិតនៅខេត្តកំពង់ស្ពឺ ១០០% ស្ថិតនៅតំបន់ជនបទ១០០%។ អ្នកដែលចូលរួមសម្ភាសន៍មានអាយុចន្លោះពី៤០ទៅ៥០ឆ្នាំមាន ៤៤.៤៤% និងអាយុលើសពី៥០ឆ្នាំមាន ៥៥.៥៦%។ ដែលក្នុងនោះមានតួនាទីជានាយក/នាយិកា ៣៣.៣៣% និងជានាយករង/នាយិការង ៦៦.៦៧%។ ចំណែកឯបទពិសោធន៍ក្នុងតួនាទីការងារបច្ចុប្បន្នចន្លោះពី៥ទៅ១០ឆ្នាំ ២២.២២%និងលើសពី១០ឆ្នាំ៦៦.៦៧%។ មួយវិញទៀតចំពោះកម្រិតសញ្ញាបត្របរិញ្ញាបត្រ ៣៣.៣៣% និងបរិញ្ញាបត្រជាន់ខ្ពស់ ៦៦.៦៧% និងគណៈគ្រប់គ្រងសាលាដែលចូលរួមបំពេញកម្រងសំណួរមានបទពិសោធន៍ក្នុងវិស័យអប់រំលើសពី១០ឆ្នាំ ១០០%។ រីឯគណៈគ្រប់គ្រងសាលារៀនបានទទួលវគ្គបណ្តុះបណ្តាល SEIP or GEIP និងទំនាក់ទំនងជាមួយសហគមន៍មាន ៨៨.៨៩% និងអ្នកដែលមិនធ្លាប់បានចូលរួមមាន ១១.១១%។ តាមការបង្ហាញក្នុងក្រាបខាងលើនេះ បានឆ្លុះបញ្ចាំងថា ការប្រមូលប្រភេទសំណាកមិនទាន់មានភាពយេនឌ័រគ្នានៅឡើយ ហើយមានការផ្តោតទៅលើតែអ្នកដែលមានបទពិសោធន៍ក្នុងវិស័យអប់រំច្រើន។ មួយវិញទៀត ក៏បង្ហាញថាគណៈគ្រប់គ្រងមានការចូលរួមក្នុងការទទួលបានចំណេះដឹងថ្មី និងការអភិវឌ្ឍសមត្ថភាពជាប្រចាំដែលនាំឱ្យមានលទ្ធភាពក្នុងការដឹកនាំ និងមានគំនិតអភិវឌ្ឍន៍ក្នុងសាលារៀន។

### ៩.១.២ ផ្នែកទី២៖ ការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ

**ក្រាបទី២ ៖ ភាពជាអ្នកដឹកនាំការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀនជាមួយសហគមន៍**




សម្គាល់៖ A: ភាពជាអ្នកដឹកនាំការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀនជាមួយសហគមន៍

A1: យល់ដឹងយុទ្ធសាស្ត្រសហគមន៍សាលារៀន

A2: បែងចែកតួនាទី និងចំណុចទទួលខុសត្រូវរបស់សហគមន៍ ក្នុងការធានាគុណភាពអប់រំ

A3: បណ្តុះបណ្តាលនិងណែនាំអំពីកម្មវិធីសិក្សា និងគម្រោងនានារបស់សាលារៀនដល់សហគមន៍

A4: ផ្តួចផ្តើមគំនិតធ្វើកិច្ចការជាមួយអ្នកពាក់ព័ន្ធដើម្បីគៀងគរមូលនិធិគាំពារសាលារៀន

A5: បង្ហាញសកម្មភាពល្អៗប្រចាំថ្ងៃ

A6: បង្កើតភាពជឿទុកចិត្តដល់សហគមន៍

A7: បង្ហាញពីតម្លាភាព និងគណនេយ្យភាព

A8: ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសាលារៀន

A9: មានមោទនភាពលើវិជ្ជាជីវៈរបស់ខ្លួន

A10: បំពេញការងារឱ្យអស់ពីលទ្ធភាព និងសមត្ថភាព

A11: ហ៊ានធ្វើសេចក្តីសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈម

A12: អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (ស្វ័យសិក្សា ស្រាវជ្រាវ)

A13: ការបង្កើតវប្បធម៌ទំនាក់ទំនងរវាងគ្រូបង្រៀន និងថ្នាក់ដឹកនាំ

A14: ការធ្វើប្រតិភូកម្មឱ្យមានប្រសិទ្ធភាពដើម្បីសម្រេចគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ

A15: បង្កើនការគ្រប់គ្រង ការដឹកនាំនិងសមិទ្ធកម្មប្រកបដោយគណនេយ្យភាព

A17: ការដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍

A16: ការរៀបចំរចនាសម្ព័ន្ធបែងចែកតួនាទី និងភារកិច្ចដល់បុគ្គលិក តាមជំនាញប្រកបដោយប្រសិទ្ធភាព

តាមក្រាបទី២ ខាងលើបានបង្ហាញថា ភាពជាអ្នកដឹកនាំការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀនជាមួយសហគមន៍មានកម្រិតមធ្យមភាគ ៣.១០ ដែលស្ថិតនៅកម្រិតខ្ពស់ និងកម្រិតមធ្យមភាគ ៤.៨៩ ស្ថិតនៅកម្រិតខ្ពស់បំផុត ជាមធ្យមភាគក្នុងចំណោមចំណុចរងទាំងដប់ប្រាំពីរគឺ ៤.១៨។ ក្នុងនោះក្រាបបានបង្ហាញថា ភាពជាអ្នកដឹកនាំការគ្រប់គ្រង និងការអភិវឌ្ឍសាលារៀនជាមួយសហគមន៍ គឺមានការបែងចែកតួនាទី និងចំណុចទទួលខុសត្រូវរបស់សហគមន៍ ក្នុងការធានាគុណភាពអប់រំ ព្រមទាំងការដឹកនាំសិស្សជួយការងារសង្គម និងសហគមន៍បានយ៉ាងល្អ។

**ក្រាបទី៣ ៖ ការប្រាស្រ័យទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដើម្បីទទួលបានលទ្ធផលល្អប្រសើរ**




កំណត់សម្គាល់៖ B: ការប្រាស្រ័យទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដើម្បីទទួលបានលទ្ធផលល្អប្រសើរ

B1: អនុញ្ញាតដល់សហគមន៍ចូលរួមនិងចែករំលែកចំណេះដឹង និងជំនាញរបស់ពួកគាត់បាន

B2: បានជួបពិភាក្សាជាមួយភាគីពាក់ព័ន្ធដើម្បីធ្វើផែនការ ការអនុវត្តកម្មវិធី និងការបង្កើតគម្រោងផ្សេងៗបាន

B3: បានពន្យល់ដល់ភាគីពាក់ព័ន្ធមានប្រសិទ្ធភាពកម្រិតណា ដើម្បីឱ្យពួកគាត់ចូលរួមវិភាគទានក្នុងការអភិវឌ្ឍសាលារៀន

B4: បានគាំទ្រមតិយោបល់ គំនិតផ្តួចផ្តើមរបស់ភាគីពាក់ព័ន្ធប្រកបដោយសុភវិនិច្ឆ័

B5: ដោះស្រាយវិវាទប្រកបដោយប្រសិទ្ធិភាព និងការទទួលយកបាន

តាមក្រាបទី៣ ខាងលើបានបង្ហាញថា ការប្រាស្រ័យទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដើម្បីទទួលបានលទ្ធផលល្អប្រសើរមានកម្រិត ៤.២២ ដែលស្ថិតនៅកម្រិតទាប និងមានកម្រិត ៤.៤៤ ស្ថិតនៅកម្រិតខ្ពស់ ដែលមានមធ្យមភាគក្នុងចំណោមចំណុចរងទាំងប្រាំគឺ ៤.៣៨។ ដែលអាចបញ្ជាក់បានថា ការប្រាស្រ័យទំនាក់ទំនងរបស់គណៈគ្រប់គ្រងសាលារៀន ជាមួយសហគមន៍បានល្អប្រសើរជាទីគាប់ចិត្ត។ ព្រមទាំងមានគំនិតក្នុងការ ផ្តួចផ្តើមធ្វើអ្វីមួយ និងមានលទ្ធភាពអាចដោះស្រាយបញ្ហាដែលបានចោទមានឡើងក្នុងសាលារៀនមានលក្ខណៈល្អ។

**ក្រាបទី៤ ៖ បង្កើតកម្មវិធីជួបជុំ និងពិគ្រោះយោបល់រវាងមាតាបិតាសិស្ស និងគណៈគ្រប់គ្រងសាលា**



កំណត់សម្គាល់៖ C:បង្កើតកម្មវិធីជួបជុំនិងពិគ្រោះយោបល់រវាងមាតាបិតាសិស្សនិងគណៈគ្រប់គ្រងសាលា

C1: បង្កើតការជួបជុំជាមួយមាតាបិតាសិស្ស អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ

C2: ទទួលបានមតិយោបល់ពីការពិភាក្សាជាមួយអ្នកពាក់ព័ន្ធយកមកអភិវឌ្ឍសាលាបាន

C3: ការរៀបចំប្រជុំបុគ្គលិកនិងសហគមន៍ក្នុងការពិនិត្យកែលម្អ អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សាបា ន

C4: សង្កេតឃើញថា ការជួបជុំនេះបានបង្កើតភាពស្និទ្ធស្នាល

C5: ការពិគ្រោះយោបល់ជាមួយសហគមន៍ និងដៃគូពាក់ព័ន្ធមានសារៈសំខាន់ក្នុងការអភិវឌ្ឍ

តាមក្រាបទី៤ បានបង្ហាញថា គណៈគ្រប់គ្រងសាលារៀន បង្កើតកម្មវិធីជួបជុំ និងពិគ្រោះយោបល់រវាងមាតាបិតាសិស្ស មានកម្រិតមធ្យមភាគ ៣.១៥ ដែលស្ថិតនៅកម្រិតទាប និង ៤.២២ ដែលស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោមចំណុចរងទាំងប្រាំគឺ ៣.៥២ ដែលអាចបញ្ជាក់ថា គណៈគ្រប់គ្រងនិងសហគមន៍មានការពិគ្រោះយោបល់គ្នាបានទូលំទូលាយ ក្នុងការរៀបចំផែនការក្នុងការចូលរួមអភិវឌ្ឍន៍សាលារៀន និងបង្កើតផែនការដើម្បីអភិវឌ្ឍន៍សាលារៀន។

### ៤.១.៣ ផ្នែកទី៣៖ ការបង្កើតបណ្តាញទំនាក់ទំនង និងគ្រប់គ្រងដឹកនាំសម្របសម្រួលជាមួយសហគមន៍

**ក្រាបទី៥ ៖ ការសហការ និងទំនាក់ទំនងជាមួយសហគមន៍**



កំណត់សម្គាល់៖ D: ការសហការ និងទំនាក់ទំនងជាមួយសហគមន៍

D1: ការរក្សាបាននូវវប្បធម៌សាមគ្គីភាព សន្តិភាពនិងការគោរពគ្នាទៅវិញទៅមកតាមឋានានុក្រម

D2: មានកាយវិការនិងពាក្យសម្តីបានសមរម្យជាមួយអ្នកពាក់ព័ន្ធពេលទំនាក់ទំនង

D3: បានទទួលយកព័ត៌មានត្រឡប់ពីសហគមន៍ និងអ្នកពាក់ព័ន្ធបាន

D4: ការផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃជាផ្លូវការដល់ភាគីពាក់ព័ន្ធ

D5: បានផ្តើមកម្មវិធីបន្ថែមថ្មីៗដែលគាំពារដោយសហគន៍បានញឹកញាប់

D6: បញ្ជ្រាបការយល់ដឹងដល់សហគមន៍អំពីការចូលរួមការអភិវឌ្ឍសាលារៀន

D7: មានឆន្ទះរក្សាទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ និងសហគមន៍

តាមក្រាបទី៥ បានបង្ហាញថា ការសហការ និងទំនាក់ទំនងជាមួយសហគមន៍របស់គណៈគ្រប់គ្រងសាលារៀន មានមធ្យមភាគជារួមគឺ ៤.១០ ដែលក្នុងនោះមាន ៣.២៣ ស្ថិតនៅកម្រិតទាប និង ៤.៦៩ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគ។ សបញ្ជាក់ថា គណៈគ្រប់គ្រងសាលារៀនមានសមត្ថភាពក្នុងការសហការ និងទំនាក់ទំនាក់ជាសហគមន៍ដោយរក្សាបាននូវសមគ្គីភាពនិងគោរពគ្នាទៅវិញទៅមក ជាពិសេសកាយវិការនិងពាក្យសម្តីបានសមរម្យជាមួយអ្នកពាក់ព័ន្ធពេលទំនាក់ទំនងបានយ៉ាងល្អ។ មួយវិញទៀត ការទទួលព័ត៌មានពីសហគមន៍ទាំងការរិះគន់ និងគំនិតដើម្បីកែលម្អសាលារៀន និងមានឆន្ទះរក្សាទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ និងសហគមន៍យូរអង្វែង និងនិរន្តរភាព។

**ក្រាបទី៦៖ ការបង្កើតបណ្តាញសកម្មភាព និងការចរចារសម្រុះសម្រួលជាមួយសហគមន៍**




កំណត់សម្គាល់៖ E: ការបង្កើតបណ្តាញសកម្មភាព និងការចរចាសម្រុះសម្រួលជាមួយសហគមន៍

E1: ការបង្កើនទំនាក់ទំនងជិតស្និទ្ធ និងយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធនានាដើម្បីអភិវឌ្ឍសាលារៀន

E2: ការដឹកនាំនិងសម្របសម្រួល ការកៀរគរធនធានពីប្រភពផ្សេងៗ ដើម្បីអភិវឌ្ឍសាលារៀន

E3: ការកសាងទំនុកចិត្ត ដោយខិតខំបង្កើនសមិទ្ធផល លទ្ធផលសិក្សាល្អគោរពឆន្ទៈរួម មានការលះបង់ មានចក្ខុវិស័យ បេសកម្ម រចនាសម្ព័ន្ធច្បាស់លាស់

E4: ជំរុញឱ្យទំនាក់ទំនងរវាងសហគន៍ និងគណៈគ្រប់គ្រងសាលា មានភាពស៊ីចង្វាក់គ្នាបាន

E5: សម្រេចនូវគោលដៅ និងគោលបំណងដែលកើតចេញពីការព្រមព្រៀងគ្នាជាមួយសហគន៍

E6: ការពន្យល់ពីតម្លៃនៃការអប់រំដល់មាតាបិតាសិស្ស

E7: ការផ្សព្វផ្សាយរាល់សមិទ្ធផលការងាររបស់សាលា ដែលសហគមន៍បានចូលរួមអភិវឌ្ឍន៍

E8: ការបង្កលក្ខណៈងាយស្រួលដល់អ្នកពាក់ព័ន្ធចូលរួម ដោយផ្តល់ការគាំទ្រការផ្តល់កិត្តិយស និងការផ្តល់ឱកាសចូលរួមក្នុងសកម្មភាពនានា

E9: ការស្តាប់ និងទទួលយកនូវគំនិត ឬយោបល់រិះគន់ ស្ថាបនាពីសហគមន៍និងភាគីពាក់ព័ន្ធ

ក្រាបទី៦៖ បានបង្ហាញថា គណៈគ្រប់គ្រងសាលារៀនបានធ្វើការបង្កើតបណ្តាញសកម្មភាព និងការចរចាសម្រុះសម្រួលជាមួយសហគមន៍ មានមធ្យមភាគ ២.២៥ ស្ថិតនៅកម្រិតទាប និង ៣.៩១ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគរួមគឺ ៣.២៣។ ជាលទ្ធផលខាងលើនេះបានបង្ហាញថា ការបង្កើនទំនាក់ទំនងជិតស្និទ្ធ និងយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និង អ្នកពាក់ព័ន្ធនានាដើម្បីអភិវឌ្ឍសាលារៀន ជាពិសេសរួមគ្នាសម្រេចគោលដៅ និងគោលបំណង ដែលកើតចេញពីការព្រមព្រៀងគ្នាជាសហគមន៍។

**ក្រាបទី៧៖ ផ្នែកដោះស្រាយវិវាទ និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ**




កំណត់សម្គាល់៖ F: ផ្នែកដោះស្រាយវិវាទ និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ

F1: ការបង្កើតឱកាស ការយកចិត្តទុកដាក់ដើម្បីទទួលបានលទ្ធផលល្អនៃការសិក្សារបស់សិស្ស

F2: បានដោះស្រាយបញ្ហាប្រឈមជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធបាន

F3: សម្របសម្រួលក្នុងការកៀងគរស្វែងរកធនធានដើម្បីធ្វើការអភិវឌ្ឍសាលារៀន

F4: រៀបចំរចនាសម្ព័ន្ធដើម្បីចាំជួយដោះស្រាយបញ្ហា និងការផ្តល់ជាមតិយោបល់ដល់អ្នកពាក់ព័ន្ធ

F5: ទទួលយកការសំណូមពររបស់សហគមន៍និងអ្នកពាក់ព័ន្ធយកទៅដោះស្រាយ

តាមក្រាបទី៧ បានបង្ហាញថា ការដោះស្រាយវិវាទ និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធមានមធ្យមភាគ ៣.២២ ស្ថិតនៅកម្រិតទាប និង ៣.៥៦ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោម

រងទាំងប្រាំគឺ ៣.៣៩ ដែលអាចបញ្ជាក់បានថា គណៈគ្រប់គ្រងសាលារៀនបានធ្វើការខិតខំប្រឹងប្រែងដោះស្រាយបញ្ហាដែលបានកើតមានឡើង ជាមួយភាគីពាក់ព័ន្ធបានកម្រិតខ្ពស់។ ព្រមទាំងបានបង្កើតការសម្របសម្រួលក្នុងការស្វែងរកមូលនិធិដើម្បី កសាងសាលារៀន និងមានការអភិវឌ្ឍ។

**ក្រាបទី៨៖ ការកសាងការបង្កើតគំនិតរួមគ្នាដើម្បីអភិវឌ្ឍន៍សាលា**




កំណត់សម្គាល់៖ G: ការកសាងការបង្កើតគំនិតរួមគ្នាដើម្បីអភិវឌ្ឍសាលា

G1: បង្ហាញអំពីគំនិតផ្តួចផ្តើម និងទស្សនៈវិស័យផ្សេងៗដល់ភាគីពាក់ព័ន្ធ

G2: ណែនាំអំពីសារៈសំខាន់នៃការអភិវឌ្ឍសាលារៀនដល់សហគមន៍បាន

G3: ពិគ្រោះយោបល់ និងការសន្ទនាគ្នាដើម្បីស្វែងរកការបង្រួបបង្រួម ក្នុងការសហការជាដៃគូរ

G4: ណែនាំអំពីការរួបរួមគ្នា និងការមិនរើសអើងជាតិសាសន៍ដើម្បីបានចូលរួមអភិវឌ្ឍន៍សាលា

G5: ជម្រុញអំពីផែនការអភិវឌ្ឍន៍សាលា និងការចូលរួមរបស់សហគមន៍

ក្រាបទី៨ បានបង្ហាញថា ការកសាងការបង្កើតគំនិតរួមគ្នាដើម្បីអភិវឌ្ឍសាលា ជាមួយសហគមន៍ដែលមានមាតាបិតា អាណាព្យាបាល សិស្ស និងភាគីពាក់ព័ន្ធដទៃទៀត ដែលមានកម្រិតមធ្យមភាគ ៣.៤០ ដែលស្ថិតនៅកម្រិតទាប និង ៤.៦៩ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោមរងទាំងប្រាំគឺ ៣.៩១។ ក្នុងន័យនេះបានបញ្ជាក់ថា បានផ្តួចផ្តើមក្នុងការកសាងបង្កើតគំនិតរួមគ្នាដើម្បីអភិវឌ្ឍន៍សាលារៀនបានយ៉ាងសកម្ម។

**ក្រាបទី៩៖ ផែនការអភិវឌ្ឍសាលារៀន និងការអនុវត្តជានិរន្តរ៍ភាពដើម្បីការអប់រំទាំងអស់គ្នា**




កំណត់សម្គាល់៖ H: ផែនការអភិវឌ្ឍសាលារៀន និងការអនុវត្តជានិរន្តរ៍ភាពដើម្បីការអប់រំទាំងអស់គ្នា

H1: បង្កើតផែនការអភិវឌ្ឍន៍សាលារៀន ឱ្យស្របជាមួយផែនការអប់រំ

H2: អនុវត្តន៍ផែនការអភិវឌ្ឍសាលារៀនមានការចូលរួមពីអ្នកពាក់ព័ន្ធ

H3: មានស្វ័យភាពក្នុងការធ្វើផែនការ និងការគ្រប់គ្រងអភិវឌ្ឍន៍សាលា

H4: ការចូលរួមរបស់សហគមន៍ និងដៃគូអភិវឌ្ឍន៍មានសារៈសំខាន់

H5: វាយតម្លៃនៃការអភិវឌ្ឍសាលារៀន វាយតម្លៃការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការវាយតម្លៃការសិក្សារបស់សិស្ស

ក្រាបទី៩៖ ខាងលើនេះបានបង្ហាញថា ផែនការអភិវឌ្ឍសាលារៀន និងការអនុវត្តជានិរន្តរ៍ភាពដើម្បីការអប់រំទាំងអស់គ្នាមានកម្រិតមធ្យមភាគ ៣.១៥ ស្ថិតនៅកម្រិតទាប និង ៣.៣៣ ស្ថិតនៅកម្រិតខ្ពស់ជាងគេ ក្នុងចំណោមចំណុចរងទាំងប្រាំដែលមានមធ្យមភាគ ៣.២៥។ ក្នុងចំណុចទាំងប្រាំត្រង់ (H4) ដែលមានកម្រិតខ្ពស់បំផុត ដែលគណៈគ្រប់គ្រងសាលារៀនដែលជាសាលាគោលដៅមានការយល់ឃើញប្រហាក់ប្រហែលគ្នា អំពីការចូលរួមរបស់សហគមន៍ និងដៃគូអភិវឌ្ឍន៍ដទៃទៀតមានសារៈសំខាន់ ហើយការចូលរួមទាំងអស់នោះជាសមាជាតុដ៏សំខាន់មិនអាចខ្វះបានសម្រាប់អភិវឌ្ឍសាលារៀន។ មួយវិញទៀត

សាលាមានផែនការអភិវឌ្ឍសាលារៀន ជាមួយសហគមន៍ ដែលស្របជាមួយទិសដៅនៃផែនការរបស់ក្រសួងអប់រំ យុវជន និងកីឡាដោយជំរុញឱ្យមាន ការចូលរួមពីសហគមន៍ដើម្បីអភិវឌ្ឍន៍សាលា។

**៤.១.៤ ផ្នែកទី៤៖ ការបង្កើតដៃគូសហការប្រកបដោយការអភិវឌ្ឍជាមួយអ្នកពាក់ព័ន្ធ**

**ក្រាបទី១០៖ បរិយាកាសគាំពារសម្រាប់កម្មវិធីពីសហគមន៍**




កំណត់សម្គាល់៖ I: បរិយាកាសគាំពារសម្រាប់កម្មវិធីពីសហគមន៍

I1: ទំនាក់ទំនង និងបរិយាកាសរាក់ទាក់ជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ

I2: អនុវត្តន៍ និងការគាំទ្រនូវកម្មវិធីសិក្សាពេញមួយជីវិតដល់សហគមន៍

I3: ផ្តល់នូវស្តង់ដារសេហគមន៍សាលារៀន និងវង្វាយតម្លៃដល់សហគមន៍

I4: មូលដ្ឋានសហគមន៍ដើម្បីការអប់រំជាមួយដៃគូពាក់ព័ន្ធក្នុងការចូលរួមជាមួយសាលារៀន

I5: គណៈកម្មាធិការដើម្បីត្រួតពិនិត្យ តាមដាន វាយតម្លៃកម្មវិធីផ្សេងៗ

ក្រាបទី១០ បានបង្ហាញថា ការគាំពារសម្រាប់កម្មវិធីពីសហគមន៍ (I2) ផ្តល់នូវស្តង់ដារសហគមន៍សាលារៀន និងវង្វាយតម្លៃដល់សហគមន៍ 3.00 ជាចំណុចមានបញ្ហាប្រឈមខ្លាំងជាងគេ ស្ថិតនៅទាប និង 3.70 ស្ថិតនៅកម្រិតខ្ពស់ជាងគេ ក្នុងចំណោមវងទាំងប្រាំមធ្យមភាគរួមគឺ 3.23។ ដោយឃើញថាសហគមន៍មានការគាំទ្រខ្លាំងទៅ កម្មវិធីទាំងអស់នោះ ដើម្បីឱ្យមានការគាំទ្រកាន់តែប្រសើរជាងនេះទៀត គណៈគ្រប់គ្រងសាលារៀនត្រូវផ្តល់នូវស្តង់ដារនិងការវាយតម្លៃដល់សហគមន៍ឱ្យបានទូលំទូលាយ។

**ក្រាបទី១១៖ ការបោះផ្សាយ និងការប្រកាសលទ្ធផលទិន្នន័យដល់ភាគីពាក់ព័ន្ធ**




កំណត់សម្គាល់៖ J: ការបោះផ្សាយ និងការប្រកាសលទ្ធផលទិន្នន័យដល់ភាគីពាក់ព័ន្ធ

J1: បង្ហាញនូវរបាយការណ៍លទ្ធផលនៃការសិក្សារបស់សិស្សដល់អ្នកពាក់ព័ន្ធ

J2: ផ្សព្វផ្សាយនូវទំនាក់ទំនងផ្សេងៗជាមួយសហគមន៍តាមរយៈឱជីថល និងបណ្តាញទំនាក់ទំនងផ្សេងៗទៀត

J3: ផ្សាភ្ជាប់តួនាទីរបស់សហគមន៍ក្នុងការវាយតម្លៃដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍសាលា

J4: របាយការណ៍ដល់សហគមន៍ និងអ្នកពាក់ព័ន្ធដើម្បីការអប់រំជាមួយពហុភាគី

J5: រៀបចំបង្កើតនូវគណៈកម្មាធិការដើម្បីត្រួតពិនិត្យ តាមដាន វាយតម្លៃកម្មវិធីផ្សេងៗសម្រាប់បង្ហាញដល់សិស្ស មាតាបិតា អាណាព្យាបាល និងសហគមន៍

តាមលទ្ធផលក្នុងក្រាបទី១១ បានបង្ហាញថា ការបោះផ្សាយ និងការប្រកាសលទ្ធផលទិន្នន័យដល់ភាគីពាក់ព័ន្ធមានមធ្យមភាគ 3.៤0 ស្ថិតនៅកម្រិតទាបជាងគេ និង 3.78 ស្ថិតនៅកម្រិតខ្ពស់ជាងគេ ក្នុងចំណោមវងទាំងប្រាំមធ្យមភាគគឺ ៤.15។ សបញ្ជាក់ថា ការបង្ហាញនូលលទ្ធនៃការសិក្សារបស់សិស្ស បាន

យ៉ាងទៀតទាត់ ហើយបន្ថែមលើនេះទៀតនោះ ក៏បានបង្ហាញនិងបើកទូលាយក្នុងការបង្ហាញលទ្ធផលទៅដល់ភាគីពាក់ព័ន្ធដទៃផ្សេងទៀតបានគ្រប់ជ្រុងជ្រោយ។

## ៤.២ ការវិភាគលើកម្រងសំណួររបស់គ្រូបង្រៀន

### ៤.២.១ ផ្នែកទី១៖ ព័ត៌មានទូទៅ

ក្នុងការទទួលបានទិន្នន័យពីកម្រងសំណួរក្នុងផ្នែកទី១ អំពីព័ត៌មានទូទៅរបស់គ្រូបង្រៀនដែលបានចូលរួមក្នុងការបំពេញកម្រងសំណួរដោយធ្វើចំណាត់ថ្នាក់ទៅតាមប្រភេទនៃស្ថិតិបែបពណ៌នាមានដូចជា ភេទ តំបន់ អាយុ តួនាទី បទពិសោធន៍ក្នុងតួនាទី សញ្ញាបត្រ បទពិសោធន៍ក្នុងវិស័យអប់រំ ការបណ្តុះបណ្តាល SEIP OR GEIP និងទំនាក់ទំនងជាមួយសហគមន៍។

**ក្រាបទី១២៖ សំណាកគ្រូបង្រៀន**




ក្រាបទី១២ ខាងលើបានបង្ហាញពីអ្នកចូលរួមបំពេញកម្រងសំណួរគ្រូបង្រៀន ដែលរួមមានភេទប្រុស ៦៦.៦៧% ភេទស្រី ៣៣.៣៣% ដែលស្ថិតនៅតំបន់ជនបទ ១០០%។ ហើយអ្នកមានអាយុតិចជាង ៣០ ឆ្នាំ ៦.៦៧% អាយុចន្លោះពី ៣០ ទៅ៤០ឆ្នាំមាន ២៥% អាយុចន្លោះពី៤០ ទៅ៥០ឆ្នាំមាន ៥៥% និងអាយុលើសពី៥០ ឆ្នាំមាន១៣.៣៣%។ ក្នុងនោះមានតួនាទីជាប្រធានក្រុមបច្ចេកទេសមាន

១០% អនុប្រធានក្រុមបច្ចេកទេស ១៦.៦៧% និងសមាជិកមាន ៧៣.៣៣%។ មួយវិញទៀត អ្នកមានបទពិសោធន៍ក្នុងតួនាទីបច្ចុប្បន្នតិចជាង៥ ឆ្នាំ ៦.៦៧% បទពិសោធន៍ចន្លោះពី៥ ទៅ១០ឆ្នាំ ២៥% បទពិសោធន៍លើសពី ១០ឆ្នាំ ៦៨.៣៣%។ រីឯអ្នកដែលមានកម្រិតសញ្ញាបត្របរិញ្ញាបត្រមាន៦៦.៦៧% បរិញ្ញាបត្រជាន់ខ្ពស់មាន ៣១.៦៧% និងបណ្ឌិត ១.៦៧%។ ម្យ៉ាងវិញទៀត លោកគ្រូអ្នកគ្រូបង្រៀនដែលបានចូលរួមបំពេញកម្រងសំណួរមានបទពិសោធន៍ក្នុងវិស័យអប់រំតិចជាង៥ឆ្នាំមាន ៨.៣៣% ចន្លោះពី៥ ទៅ១០ឆ្នាំ ២៥% និងលើសពី១០ឆ្នាំមាន ៦៦.៦៧%។ ចំណែកឯអ្នកធ្លាប់ទទួលបានការបណ្តុះបណ្តាល SEIP or GEIP និងមានទំនាក់ទំនងជាមួយសហគមន៍មាន ៨៦.៦៧% និងអ្នកដែលមិនធ្លាប់ទទួលបានការបណ្តុះបណ្តាល ១៣.៣៣%។ ជាលទ្ធផលក្នុងក្រាបបានបង្ហាញថា សំណាកដែលប្រមូលពីគ្រូបង្រៀនមិនទាន់មានភាពយេនឌ័រនៅឡើយ ដែលមានចំនួនបុរសច្រើនជាងស្ត្រី។ មួយទៀតបានសម្គាសន៍ទៅលើអ្នកដែលមានបទពិសោធន៍ច្រើនក្នុងវិស័យអប់រំ ហើយអ្នកទទួលបានការបណ្តុះបណ្តាល និងយល់ដឹងការចូលរួមសហគមន៍ជាមួយសាលារៀនមានចំនួនច្រើន។ ទោះបីជាយ៉ាងណា សំណាកខាងនេះមិនទាន់បានគ្រប់គ្រាន់នៅឡើយ សម្រាប់ជាតំណាងឱ្យសហគមន៍ទាំងមូល។

### ៤.២.២ ផ្នែកទី២៖ ក្នុងដំណើរការនៃការរៀន និងបង្រៀន

**ក្រាបទី១៣៖ ការប្រតិបត្តិនៃកម្មវិធីសិក្សា**



កំណត់សម្គាល់៖ A: ការប្រតិបត្តិនៃកម្មវិធីសិក្សា

A1: អនុវត្តតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ

A2: រៀបចំបែងចែកនូវបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជាបានច្បាស់លាស់តាមចំនួនពេលវេលាដែលកំណត់ដោយក្រសួងអប់រំ

A3: អនុវត្តន៍ការបង្រៀនតាមចំនួនម៉ោងកំណត់ក្នុងបំណែងចែកកម្មវិធីសិក្សា

A4: ចូលរួមវគ្គបណ្តុះបណ្តាល និងរៀនបំប៉នស្រាវជ្រាវបន្ថែមលើការបង្រៀនមុខវិជ្ជារបស់ខ្លួន

A5: រៀបចំកិច្ចតែងការសម្រាប់បង្រៀនជាប្រចាំតាមម៉ោងកំណត់

A6: កិច្ចតែងការបង្រៀនតែងតែបានត្រួតពិនិត្យពីគណៈគ្រប់គ្រងសាលាជាប្រចាំ

A7: ចូលរួមប្រជុំជាមួយក្រុមបច្ចេកទេសក្នុងការពិនិត្យ តាមដាន និងកែលម្អអំពីការបង្រៀន និងរៀនបានទៀងទាត់

A8: ធ្លាប់បានចូលបណ្ណាល័យដើម្បីស្វែងរកសៀវភៅបន្ថែមក្នុងការពង្រឹងការបង្រៀនមុខវិជ្ជារបស់ខ្លួន

A9: ស្រាវជ្រាវចំណេះដឹងបន្ថែមតាម រយៈឌីជីថលផ្តេតហ្វម

A10: ប្រើប្រាស់សៀវភៅសិក្សាគោលតាមកម្រិតថ្នាក់សិក្សាបានត្រឹមត្រូវ

A11: សាលាបានបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យ ដើម្បីលើកកម្ពស់គុណភាពប្រសិទ្ធភាពការបង្រៀន និងរៀន

A12: ចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកអំពីការរៀន និងបង្រៀន

A13: ចំនួនម៉ោងគ្រប់គ្រាន់សម្រាប់ការបង្រៀនឱ្យស្របតាមកម្មវិធីសិក្សា

A14: ផ្តល់ព័ត៌មានស្តីពីលទ្ធផលការសិក្សារបស់សិស្ស

A15: យកចិត្តទុកដាក់លើសិស្សរៀនយឺត សិស្សពិការ សិស្សមានបញ្ហា

ក្រាបទី១៣ បានបង្ហាញថា ការប្រតិបត្តិនៃកម្មវិធីសិក្សាមានកម្រិតមធ្យមភាគ (A9) ៣.១២ ដែលស្ថិតនៅកម្រិតទាបជាងគេ និងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកអំពីការរៀន និងបង្រៀនមានកម្រិតមធ្យមភាគ ៤.៦២% ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោមចំណុចរង្វួមទាំងដប់ប្រាំគឺ

៣.៤៥។ ទាំងអស់នេះសបញ្ជាក់ឱ្យដឹងថា ការប្រតិបត្តិនៃកម្មវិធីសិក្សាឱ្យស្របតាមក្រសួងអប់រំស្ថិតនៅក្នុងកម្រិតខ្ពស់ ដែលជាកត្តាមួយជំរុញឱ្យការបណ្តុះបណ្តាលទាន់កម្មវិធីសិក្សា និងការរៀនសូត្របានប្រព្រឹត្តិទៅបានយ៉ាងរលូន។

**ក្រាបទី១៤៖ ការដំណើរការសម្រាប់ការរៀន និងបង្រៀនតាមកម្រិតថ្នាក់**




កំណត់សម្គាល់៖ B: ការដំណើរការសម្រាប់ការរៀន និងបង្រៀនតាមកម្រិតថ្នាក់

B1: ថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានការរៀនសូត្របានទៀងទាត់

B2: ថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា

B3: មុខវិជ្ជាបង្រៀនមានប្លង់មេរៀនគ្រប់មេរៀន

B4: មានការបញ្ជ្រាបខ្លឹមសារមេរៀនដល់សិស្សបានយល់ដឹង

B5: សិស្សបានធ្វើកិច្ចការតាមគម្រោងដែលបានគ្រោង

B6: សិស្សបានប្រកួតប្រជែងការអាន និងការធ្វើលំហាត់

B7: សិស្សទទួលបានការយល់អំពីចំណេះសម្បទា បំណិនសម្បទា និងឥរិយាបថសម្បទា

B8: ថ្នាក់រៀនបានដំណើរការតាមផែនការដែលបានគ្រោងទុក

B9: សិស្សមានឱកាសបញ្ចេញនូវទស្សនៈ និងគំនិតរបស់ខ្លួន

B10: បានជួបនូវបញ្ហាពេលបង្រៀន

B11: សិស្សអវត្តមានលើសពីបួនដងក្នុងមួយខែ

B12: សិស្សមានការសហការគ្នាពេលធ្វើកិច្ចការរួមគ្នា

តាមទិន្នន័យដែលទទួលបានពីកម្រងសំណួរក្នុងក្រាបទី១៤ បានបង្ហាញឱ្យដឹងថា ការដំណើរការសម្រាប់ការរៀន និងបង្រៀនតាមកម្រិតថ្នាក់ មានកម្រិតមធ្យមភាគ ២.២០ ស្ថិតនៅកម្រិតទាប និង ៤.៦២ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោមចំណុចរងទាំងដប់ពីរគឺ ៣.៩២។ ក្នុងក្រាបក៏បានបង្ហាញដែរថា លោកគ្រូអ្នកអ្នកគ្រូបានជួបបញ្ហានូវពេលបង្រៀន អាចមកពីកត្តាគ្រូបង្រៀនដោយផ្ទាល់ និងកត្តាសិស្ស បញ្ហាទាំងអស់នេះត្រូវការដោយលោកគ្រូអ្នកគ្រូពង្រឹងទៅលើវិន័យ ការរៀបចំសណ្ដាប់ធ្នាប់នៃការបង្រៀននិងរៀន។

**ក្រាបទី១៥៖ វិធីសាស្ត្របង្រៀន**




កំណត់សម្គាល់៖ C: វិធីសាស្ត្របង្រៀន

C1: ប្រើវិធីសាស្ត្រថ្មីៗសម្រាប់ការបង្រៀន C2: បង្ហាញវត្ថុបំណងមេរៀនបានច្បាស់លាស់

C3: ផ្លាស់ប្តូរវិធីសាស្ត្របង្រៀនដោយប្រើល្បែងកម្សាន្ត

C4: ផ្លាស់ប្តូរតាក់ទិចក្នុងការបង្រៀនញឹកញាប់

C5: ស្តាប់ការអានរបស់សិស្សព្រមទាំងជួយអានពាក្យពិបាក

C6: ដាក់កិច្ចការឱ្យសិស្សធ្វើ (ជាក្រុម ឬក៏ជាបុគ្គល)

C7: បានរំលឹងមេរៀនឡើងវិញ

C8: ជួយដល់សិស្សរៀនខ្សោយ

C9: បានជំរុញការលើកទឹកចិត្តដល់សិស្សបានទៀងទាត់

C10: វិធីសាស្ត្របង្រៀនរបស់លោក លោកស្រីសិស្សអាចទទួលយក

តាមក្រាបទី១៥ បានបង្ហាញថា វិធីសាស្ត្របង្រៀនរបស់លោកគ្រូអ្នកគ្រូបានបង្រៀននៅកម្រិតវិទ្យាល័យ មានកម្រិតមធ្យមភាគ ៣.១៤ ដែលស្ថិតនៅកម្រិតទាប និងការជំរុញការលើកទឹកចិត្តដល់សិស្សមានកម្រិតមធ្យមភាគ ៣.៩៨ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគរួមក្នុងចំណុចរងទាំងដប់គឺ ៣.៥៤។ ទាំងនេះសបញ្ជាក់ឱ្យឃើញថា ការផ្លាស់ប្តូរតាក់តិចក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូមានកម្រិតខ្ពស់ និងការលើកទឹកចិត្តសិស្សឱ្យខិតខំប្រឹងប្រែងរៀនសូត្រមានកម្រិតខ្ពស់បំផុត ដែលកត្តាទាំងអស់នេះហើយជំរុញឱ្យមានដំណើរការល្អក្នុងការបង្រៀន និងការរៀនសូត្ររបស់សិស្សានុសិស្សមានប្រសិទ្ធភាពខ្ពស់។

**ក្រាបទី១៦៖ ការអនុវត្តជាក់ស្តែងក្នុងដំណើរការរៀន និងសកម្មភាពបង្រៀន**




កំណត់សម្គាល់៖ D: ការអនុវត្តជាក់ស្តែងក្នុងដំណើរការរៀន និងសកម្មភាពបង្រៀន

D1: ប្រើប្រាស់ប្លង់មេរៀនដើម្បីបង្រៀនជាប្រចាំ

D2: ប្រើប្រាស់កិច្ចតែងការបង្រៀន

D3: ផ្តល់ឱកាសឱ្យសិស្សពិភាក្សាជាក្រុម និងកិច្ចសហការគ្នា

D4: អនុញ្ញាតឱ្យសិស្សដែលខ្លាំង និងសិស្សខ្សោយបានអាន ចោទឆ្លើយសំណួរ និងធ្វើកិច្ចការស្មើៗគ្នា

D5: ដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើក្នុង សប្តាហ៍នីមួយៗ

D6: ណែនាំដល់សិស្សឱ្យអាន នូវខ្លឹមសារមេរៀននៅផ្ទះដើម្បីត្រៀមមុន មកសាលារៀន

D7: ជំរុញ និងបំផុសគំនិត ឱ្យសិស្សមានសកម្មភាពចូលអានសៀវភៅក្នុងបណ្ណាល័យ និងស្រាវជ្រាវបន្ថែម

D8: ការយកចិត្តទុកដាក់ និងបម្រុងប្រយ័ត្នក្នុងពេលសិក្សារៀនសូត្រ

D9: លើកទឹកចិត្តសិស្សឱ្យមានការខិតខំ និងប្រឹងប្រែងរៀនសូត្រ

D9: លើកទឹកចិត្តសិស្សឱ្យមានការខិតខំ និងប្រឹងប្រែងរៀនសូត្រ

D10: រៀបចំកម្មវិធីបង្រៀនបំប៉ន ដល់សិស្សដែលរៀនខ្សោយ

D11: ប្រើប្រាស់នូវឯកសារផ្សេងៗបន្ថែមទាក់ទង និងមេរៀន

D12: ប្រើប្រាស់សៀវភៅគោល

D13: ណែនាំសិស្ស ឱ្យចូលអានសៀវភៅក្នុងបណ្ណាល័យ ជាប្រចាំ

D14: ប្រើប្រាស់សៀវភៅគ្រូ

D15: ប្រើប្រាស់ប័ណ្ណរូបភាពក្នុងការបង្រៀន

D16: ប្រើប្រាស់ប័ណ្ណសំណួរ

D17: ប្រើប្រាស់ឧបករណ៍ជំនួយ និងសម្ភារៈឧបទេស

ក្រាបទី១៦ បានបង្ហាញថា ការអនុវត្តជាក់ស្តែងក្នុងដំណើរការរៀន និងសកម្មភាពបង្រៀនមានកម្រិតមធ្យមភាគ ២.៤៥ ស្ថិតនៅកម្រិតទាប និងលើកទឹកចិត្តសិស្សឱ្យមានការខិតខំ និងប្រឹងប្រែងរៀនសូត្រ មានមធ្យមភាគ ៤.១០ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោមចំណុចរងទាំងដប់ប្រាំពីរគឺ ៣.២១។ បញ្ហាប្រឈមស្ថិតត្រង់ (D2) (D11) និង (D14) ដែលជាការរៀបចំកម្មវិធីបង្រៀនបំប៉ន ដល់សិស្សដែលរៀនខ្សោយ និងការប្រើប្រាស់ប័ណ្ណរូបភាពក្នុងការបង្រៀន ដែលបញ្ហាទាំងអស់នេះទាមទារឱ្យលោកគ្រូអ្នកគ្រូបង្កើតស្មារតីក្នុងការចូលរួមអប់រំ ដោយការផ្សារភ្ជាប់ជាមួយស្មារតី រៀននិងបង្រៀន។

**ក្រាបទី ១៧៖ វង្វាយតម្លៃ និងលទ្ធផល**




កំណត់សម្គាល់៖ E: វង្វាយតម្លៃ និងលទ្ធផល

E1: ធ្វើការចោទសួរសំណួរបំផុសមុនចូលមេរៀន និងខ្លឹមសារមេរៀន

E2: ចោទសួរសំណួរផ្ទាល់មាត់ក្នុងពេលបង្រៀនជាប្រចាំ

E3: សួរនូវសំណួរខ្លីៗក្នុងម៉ោងបង្រៀន

E4: កែកិច្ចការផ្ទះរបស់សិស្សបានទៀងទាត់

E5: មានតេស្តសាកល្បងជាប្រចាំ

E6: បានធ្វើតេស្តប្រចាំខែ

E7: វាយតម្លៃការសិក្សារបស់សិស្សតាមរយៈតេស្តប្រចាំឆមាស

ក្រាបទី១៧ បានបង្ហាញថា វង្វាយតម្លៃ និងលទ្ធផលមានកម្រិតមធ្យមភាគ ៣.៥៥ ដែលស្ថិតនៅកម្រិតទាប និង (E7) វាយតម្លៃការសិក្សារបស់សិស្សតាមរយៈតេស្តប្រចាំឆមាសមានកម្រិតមធ្យមភាគ ៤.៤៥ ស្ថិតនៅកមិតមធ្យមភាគខ្ពស់ជាងក្នុងចំណោមចំណុចវងមធ្យមភាគទាំងប្រាំពីរគឺ ៤.០៦។ នេះសបញ្ជាក់ឱ្យឃើញថា វង្វាយតម្លៃ និងលទ្ធផលស្ថិតនៅកម្រិតខ្ពស់ ដែលជាកត្តាជំរុញមួយឱ្យមានការសិក្សារបស់សិស្សបានប្រព្រឹត្តិទៅបានយ៉ាងរលូន ហើយបញ្ជាក់បានថា ការផ្ទេរចំណេះដឹងរបស់គ្រូទៅសិស្សមានប្រសិទ្ធភាព។

### ៤.២.៣ ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ

**ក្រាបទី១៨៖ ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ**




កំណត់សម្គាល់៖ F: ការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ

F1: ធ្លាប់បានស្គាល់យុទ្ធសាស្ត្រសហគមន៍សាលារៀន

F2: ទំនាក់ទំនងសហគមន៍និងសាលារៀនពិតជាមានសារៈសំខាន់

F3: បង្កើតទំនាក់ទំនងជាមួយអាណាព្យាបាលសិស្ស ឬសហគមន៍ និងភាគីពាក់ព័ន្ធ

F4: នៅក្នុងសហគមន៍ធ្លាប់បានរៀបចំកម្មវិធីដែលទាក់ទាញសិស្ស គ្រូឱ្យចូលរួម និងការយកចិត្តទុកដាក់សហការជាមួយសហគមន៍ក្នុងការអភិវឌ្ឍសាលារៀន

F5: សាលារៀនរបស់លោក/លោកស្រីធ្លាប់អញ្ជើញឱ្យសហគមន៍ចូលរួមក្នុងកិច្ចការធ្វើផែនការអភិវឌ្ឍន៍សាលារៀន

F6: សង្កេតឃើញថាសាលារៀនបានពង្រឹងតម្លាភាពក្នុងការចូលរួមរបស់សហគមន៍

F7: សាលារៀនរបស់លោក/ លោកស្រីបានផ្តល់ភាពជឿជាក់តាមរយៈតម្លាភាពថវិកាសាលារៀននៅក្នុងការចំណាយនៃគម្រោងអភិវឌ្ឍន៍នានា

តាមលទ្ធផលនៃក្រាបទី១៨ បានបង្ហាញអំពីការបង្កើតទំនាក់ទំនងជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ មានកម្រិតមធ្យមភាគ ២.៥០ ដែលស្ថិតនៅកម្រិតទាបជាងគេ និងទំនាក់ទំនងសហគមន៍និងសាលារៀនពិតជាមានសារៈសំខាន់មានកម្រិតមធ្យមភាគ ៣.៦៥ ស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោមចំណុចរងទាំងប្រាំពីរគឺ ៣.១៩។ ចំណុចដែលជាបញ្ហាប្រឈមនៅត្រង់ សាលារៀនធ្លាប់អញ្ជើញឱ្យសហគមន៍ចូលរួមក្នុងកិច្ចការធ្វើផែនការ អភិវឌ្ឍសាលារៀន ដែលបញ្ហាត្រង់នេះតម្រូវឱ្យសាលារៀនពង្រឹងទំនាក់ទំនងជាមួយសហគមន៍ឱ្យប្រសើរឡើង ដើម្បីផ្សាភ្ជាប់ក្នុងភាពជឿទុកចិត្ត គ្រប់ភាគីទាំងអស់។ មួយវិញទៀត ក៏ដើម្បីឱ្យសហគមន៍បានស្គាល់នូវតួនាទី និងភារកិច្ចរបស់ខ្លួនដើម្បីជួយជំរុញការអភិវឌ្ឍសាលារៀន និងជាប្រភពនៃធនធានដែលមិនចេះរីងស្ងួតសម្រាប់អភិវឌ្ឍសាលារៀន។ តាមក្រាបក៏បានបង្ហាញចំណុចល្អផងដែរថា លោកគ្រូអ្នកគ្រូមានការយល់ឃើញថា ទំនាក់ទំនងសហគមន៍និងសាលារៀនពិតជាមានសារៈសំខាន់ ដែលកត្តានេះធ្វើឱ្យមានការសហការគ្នារវាងសាលារៀន សហគមន៍ និងអ្នកពាក់ព័ន្ធដទៃដើម្បីរួមរួមគ្នាក្នុងការចូលរួមអភិវឌ្ឍសាលារៀន។

### ៤.២.៤ ផ្នែកទី៤៖ បញ្ហាប្រឈម និងសំណូមពរ

### ក. បញ្ហាប្រឈមក្នុងការគៀងគរសហគន៍ចូលរួមជាមួយសាលារៀន

តាមការសម្ភាសន៍និងការឆ្លើយរបស់លោកគ្រូ អ្នកគ្រូស្តីអំពីបញ្ហាប្រឈមដែលប្រឈមផ្សេងៗជាមួយនិងសហគន៍និងសាលារៀន។ អ្នកស្រាវជ្រាវបានសង្កេតឃើញថា៖

- ការផ្សព្វផ្សាយមិនទាន់បានទូលំទូលាយ និយាយនៅមានកម្រិតនៅឡើយ
- ការចូលរួមរបស់សហគមន៍នៅមានកម្រិតដោយសារតែពួកគាត់រវល់និងកិច្ចការរកស៊ី
- កត្តាដោយសារតែប្រជាពលរដ្ឋនៅតំបន់មួយចំនួនមានជីវភាពទន់ខ្សោយ
- ការបង្ហាញអំពីតម្លាភាពនៅមានកម្រិតដែលធ្វើឱ្យសហគមន៍បាត់បង់ជំនឿ
- គ្រូបង្រៀនមួយចំនួនតូចមិនទាន់យល់បានស៊ីជម្រៅអំពី សារៈសំខាន់ការចូលរួមរបស់សហគមន៍

### ខ. សំណូមពរ

- ឱ្យគណៈគ្រប់គ្រងសាលារៀនមានតម្លាភាពឱ្យបានទូលំទូលាយ
- ការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងសហការជាមួយភាគីពាក់ព័ន្ធ
- ការបង្កើតកិច្ចពិភាក្សាជាមួយសហគន៍ឱ្យបានញឹកញាប់ដើម្បីឱ្យមានចំណុចស៊ីចង្វាក់គ្នា
- ពង្រឹងសាមគ្គីភាពជាមួយលោកគ្រូអ្នកគ្រូ គណៈគ្រប់គ្រង និងសហគមន៍ឱ្យបានល្អ
- ត្រូវផ្តល់ព័ត៌មានអំពី ការសិក្សារបស់សិស្សឱ្យបានទៀងទាត់

## ៤.៣ ការវិភាគលើកម្រងសំណួរសហគមន៍

### ៤.៣.១ ផ្នែកទី១៖ ព័ត៌មានទូទៅរបស់សហគមន៍

ក្រាបទី១៩៖ សំណាករបស់សហគន៍




ក្រាបទី១៩ បានបង្ហាញថា អ្នកដែលបានចូលរួមបំពេញកម្រងសំណួរសម្រាប់សហគមន៍ រួមមានភេទប្រុស ៦០.០០% ភេទស្រី ៤០.០០% ដែលអ្នកបំពេញកម្រងសំណួរមកពីបីឃុំស្រុកគឺ ឃុំពោធិ៍អង្គ្រង ស្រុកបសេដ្ឋ ៣៣.៣៣% ឃុំគីរីវន្ត ស្រុកភ្នំស្រួច ៣៣.៣៣% និងឃុំវល្លិសរ ស្រុកសំរោងទង ៣៣.៣៣% ដែលស្រុកទាំងបីតំណាងឱ្យទូទាំងខេត្រកំពង់ស្ពឺ។ ជាមួយគ្នានោះដែរក្នុងកម្រងសំណួរក៏បានរំលេច នូវអាយុតិចជាង៤០ឆ្នាំមាន ២១.៦៧% អាយុ៤១ទៅ៥០ ឆ្នាំមាន ៣៣.៣៣% និងអាយុលើសពី ៥០ ឆ្នាំឡើងមាន ៤៥%។ ក្នុងសំណាករបស់សហគមន៍ មានអ្នកចូលរួមជាស្ត្រី មានភាគរយតិចជាងបុរស ដែលមិនមានសមភាពយេនឌ័ររវាងស្ត្រីនិងបុរស។ ជាងនេះចំនួនសំណាក ដែលមានអាយុលើសពីហាសិបឆ្នាំមានចំនួនច្រើនជាងគេ ដែលសរបញ្ជាក់ថា ការសម្ភាសន៍អ្នកដែលមានបទពិសោធន៍ និងមានការយល់ដឹងច្រើនក្នុងការប្រឡូកជាមួយសង្គម ដែលទាំងនេះមិនទាន់បង្ហាញអំពីសមភាពយុវជនដែលជាទំពាំងស្នងឬស្សីជំនាក់ក្រោយ ដែលពួកគាត់មានការយល់ដឹងកាន់តែស៊ីជម្រៅ។

### ៤.៣.២ ការចូលរួមរបស់សហគន៍ក្នុងការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ

**ក្រាបទី២០៖ ការចូលរួមរបស់សហគន៍ក្នុងការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ**




កំណត់សម្គាល់៖ A: ការចូលរួមរបស់សហគន៍ក្នុងការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់ភាគីពាក់ព័ន្ធ

A1: បានចូលរួមជាមួយសាលារៀនបាន

A2: មាតាបិតា អាណាព្យាបាលសិស្សបានជំរុញកូនៗមករៀនទៀងទាត់ និងគោរពពេលវេលា

A3: ប្រជុំពិគ្រោះយោបល់រវាងមាតាបិតាសិស្ស គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សិស្ស និងភាគីពាក់ព័ន្ធ

A4: មាតាបិតា អាណាព្យាបាលសិស្សបានជួយបង្រៀន ឬចែករំលែកចំណេះដឹងបន្ថែមនៅផ្ទះដល់កូន

A5: មាតាបិតា អាណាព្យាបាលសិស្សបានតាមដាន យកចិត្តទុកដាក់ដល់ការសិក្សារបស់កូន

A6: មាតាបិតា អាណាព្យាបាលរបស់សិស្សបានជំរុញ និងតាមដានកូនធ្វើកិច្ចការផ្ទះ និងលំហាត់

A7: បានអប់រំណែនាំកូនបន្ថែម

A8: បង្កើតឱកាសឱ្យកូនបានបញ្ចេញទស្សនៈគំនិត

A9: មាតាបិតា អាណាព្យាបាលបានចូលរួមវិភាគទានដល់ការអភិវឌ្ឍសាលា

A10: បានចូលរួមក្នុងកម្មវិធីរបស់សាលារៀន ដូចជាកម្មវិធីសប្បុរសធម៌ បុណ្យផ្ការស្មី បុណ្យសាមគ្គីដើម្បីអែង្គាសបច្ច័យកមកកសាង និង អភិវឌ្ឍន៍សាលារៀន

A11: បានចូលរួមក្នុងការរៀបចំព្រឹត្តិការណ៍ ឬកម្មវិធីផ្សេងៗនៅសាលារៀន

A12: ទទួលបានព័ត៌មានអំពីសាលារៀនផ្តល់មកពីការសិក្សារបស់កូន

A13: មាតាបិតា អាណាព្យាបាលសិស្សបានចូលរួមឧបត្ថម្ភថវិកា ឬសម្ភារៈក្នុងការជួយគាំទ្រដល់ការសិក្សារបស់សិស្ស

A14: បានចូលរួមក្នុងការត្រួតពិនិត្យការធ្វើតេស្តប្រចាំខែ ប្រចាំឆមាស និងការបិទផ្សាយលទ្ធផលតេស្តរបស់សិស្ស

A15: គណៈគ្រប់គ្រងសាលារៀនធ្លាប់បានអញ្ជើញលោក លោកស្រីជាមាតាបិតា អាណាព្យាបាលសិស្សឱ្យចូលរួមធ្វើផែនការ និងអនុវត្តផែនការសាលារៀនបានញឹកញាប់

A16: អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរដែនដីបានចូលរួមជាមួយកិច្ចការសាលារៀន

A17: អាជ្ញាធរមូលដ្ឋានបានសហការក្នុងការរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខជុំវិញសាលារៀន

A18: មាតាបិតា អាណាព្យាបាលសិស្សយល់ថាការចូលរួមរបស់ពួកគាត់ក៏ដូចជា សហគមន៍ទាំងមូលជាមួយសាលារៀន បានផ្តល់នៅអត្ថប្រយោជន៍ និងជួយជ្រោមជ្រែងសាលារៀន

A19: មាតាបិតា អាណាព្យាបាលសិស្សផ្តល់ការជឿទុកចិត្តក្នុងការធានានិរន្តរភាព នៃការអភិវឌ្ឍសាលារៀន

A20: មានទំនុកចិត្តលើការអភិវឌ្ឍសាលារៀនក្នុងការអប់រំដើម្បីសិស្សទាំងអស់

តាមទិន្នន័យក្រាបទី២០ បានបង្ហាញឱ្យដឹងថា ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន និងការចូលរួមរបស់ភាគីពាក់ព័ន្ធនៅមានកម្រិតមធ្យមនៅឡើងទៅលើ មាតាបិតា អាណាព្យាបាលរបស់សិស្សបានជំរុញ និងតាមដានកូនធ្វើកិច្ចការផ្ទះ និងលំហាត់ ការចូលរួមក្នុងការត្រួតពិនិត្យការធ្វើតេស្តប្រចាំខែ ប្រចាំឆមាស និងការបិទផ្សាយលទ្ធផលតេស្តរបស់សិស្ស ការទំនាក់គណៈគ្រប់គ្រងសាលារៀនធ្លាប់បានអញ្ជើញមាតាបិតា អាណាព្យាបាលសិស្សឱ្យចូលរួមធ្វើផែនការ និងអនុវត្តផែនការសាលារៀន

នៅមានកម្រិតមធ្យមនៅឡើយ ដែលមានកម្រិតមធ្យមភាគ ៣.០៥ ស្ថិតនៅកម្រិតទាបជាងមធ្យមភាគរួមក្នុងចំណោមសំណួរទាំងម្ភៃគឺ ៣.៦៣។ ហេតុផលទាំងនោះ កើតមកពីទំនាក់ទំនងសហគមន៍ និងសាលារៀនមានភាពមិនទុកចិត្តគ្នា ការផ្សព្វផ្សាយមានកម្រិតនៅឡើយ ការយល់ដឹងរបស់សហគមន៍មិនទាន់បានទូលំទូលាយអំពីការចូលរួមដើម្បីអភិវឌ្ឍសាលារៀន ទំនាក់ទំនងរវាងសហគមន៍ និងសាលារៀនមិនទាន់ស៊ីចង្វាក់និងគ្នាដែលធ្វើឱ្យមានគម្លាតនៃទំនាក់ទំនងព័ត៌មានគ្រប់ជ្រុងជ្រោយ។

## ៤.៤ ការវិភាគលើកម្រងសំណួររបស់សិស្ស

### ៤.៤.១ ផ្នែកទី១៖ អំពីព័ត៌មាន

**ក្រាបទី២១៖ សំណាករបស់សិស្ស**




ក្រាបទី២១ បានបង្ហាញឱ្យដឹងថា អ្នកដែលបានចូលរួមក្នុងការបំពេញកម្រងសំណួរសម្រាប់សិស្សដែលមានភេទប្រុសមាន ៣៨% និងភេទស្រីមាន៦២%។ ហើយសិស្សានុស្សិតបានបំពេញកម្រងសំណួរមកពី បីកម្រិតថ្នាក់គឺ ថ្នាក់ទី១០មាន ១២.៦៧% សិស្សថ្នាក់ទី១១មាន ៤៤.០០% សិស្សថ្នាក់ទី១២ មាន ៤៣.៣៣%។ ក្នុងនោះមានវិទ្យាល័យជាគោលដៅមានបីគឺ វិទ្យាល័យ២៤កញ្ញា ៣៣.៣៣% វិទ្យាល័យហ៊ុនសែនចំបក់ ៣៣.៣៣% និងវិទ្យាល័យហ៊ុនសែនភ្នំស្រួច ៣៣.៣៣%។ មួយវិញទៀត អាយុមានភាពខុសគ្នានៃកម្រិតថ្នាក់ សិស្សដែលមានអាយុចន្លោះ ១៥ទៅ១៦ឆ្នាំមាន ៤៤.% អាយុចន្លោះ១៧ទៅ១៨មាន ៥៤.០០% និងអាយុ១៩ឆ្នាំឡើងមាន ២.០០%។ បញ្ជាក់ថា ចំនួនសិស្សស្រីមានការចូលរួមក្នុងការឆ្លើយ

សំណួរសម្ភាសន៍មានភាគរយច្រើនជាងសិស្សប្រុស ហើយសិស្សដែលរៀនថ្នាក់ទី១២មានចំនួនសំណាកច្រើន រីឯអាយុអ្នកចូលរួមភាគច្រើនជាយុវជនមានចំនួនភាគរយខ្ពស់ជាងក្នុងចំណោមទាំងបីកម្រិត។

### ៤.៤.២ ផ្នែកទី២៖ អំពីការសិក្សារបស់សិស្ស

**ក្រាបទី២២៖ ការប្រតិបត្តិនៃការបង្រៀន និងរៀន**




កំណត់សម្គាល់៖ A: ការប្រតិបត្តិនៃការបង្រៀន និងរៀន

A:1 ចូលចិត្តក្នុងការសិក្សារបស់ខ្លួន

A2: ការគោរពបទបញ្ជាសាលារបស់ប្អូន

A3: ការចូលរៀនរបស់ប្អូនគោរពទៅតាមម៉ោង និងពេលវេលា

A4: រៀនទៀងទាត់តាមកាលវិភាគជាប្រចាំ

A5: រយៈពេលក្នុងមួយថ្ងៃប្អូនបានចំណាយពេលក្នុងការសិក្សាទាំងក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា

A6: ចំនួនម៉ោងតាមកាលវិភាគនៃមុខវិជ្ជានីមួយៗមិនគ្រប់គ្រាន់សម្រាប់ប្អូនៗ

A7: ចំនួនម៉ោងតាមកាលវិភាគនៃមុខវិជ្ជានីមួយៗគ្រប់គ្រាន់សម្រាប់ប្អូនៗ

A8: កាលវិភាគសិក្សារបស់ប្អូនមានម៉ោងបណ្ណាល័យសម្រាប់ឱ្យប្អូនពង្រឹងទៅលើការសិក្សារៀនសូត្រ

A9: លោកគ្រូ អ្នកគ្រូប្អូនមានទំនួលខុសត្រូវនៅក្នុងការគោរពពេលវេលា

A10: ស្តាប់ការបង្ហាញវត្ថុបំណងមេរៀនបានច្បាស់លាស់

A11: ប្អូនស្តាប់បានការណែនាំរបស់គ្រូប្អូនអំពីការអានមេរៀន និងការអានមេរៀនទុកមុន

A12: ប្អូនលេងហ្គេមសិក្សា (ល្បែងការសិក្សា)

A13: គ្រូប្អូនបានពន្យល់ពាក្យពិបាក ដែលមានក្នុងមេរៀន

A14: លោកគ្រូ អ្នកគ្រូប្អូនបានផ្លាស់ប្តូរឱ្យសិស្សអានមេរៀនបានញឹកញាប់

A15: លោកគ្រូ អ្នកគ្រូប្អូនបានផ្តល់ឱកាសឱ្យសិស្សពូកែ និងសិស្សខ្សោយបានអានមេរៀនឆ្លើយសំណួរ និងធ្វើលំហាត់ស្មើៗគ្នា

A16: លោកគ្រូ អ្នកគ្រូប្អូនឱ្យពិភាក្សាក្រុមញឹកញាប់

A17: គ្រូប្អូនបានណែនាំ និងចង្អុលបង្ហាញឱ្យអានមេរៀននៅផ្ទះត្រៀមមុន

A18: មុនពេលរៀន និងក្រោយពេលរៀនចប់គ្រូប្អូនបានរំលឹកមេរៀន

A19: គ្រូប្អូនតែងតែបំផុសសកម្មភាព និងលើកទឹកចិត្តឱ្យសិស្សចូលអានសៀវភៅនៅបណ្ណាល័យ

A20: ប្អូនធ្លាប់បានចូលអានសៀវភៅក្នុងបណ្ណាល័យ ឬក៏ស្វែងរកឯកសារបន្ថែមទៀតទាក់ទងនឹងការសិក្សារបស់ប្អូន

A21: គ្រូប្អូនធ្លាប់ជួយបង្រៀនបំប៉នបន្ថែមទៅលើសិស្សខ្សោយនៅម៉ោងចេញលេង

A22: គ្រូប្អូន បានដាក់កិច្ចការផ្ទះ បានត្រួតពិនិត្យកិច្ចការផ្ទះ និងកែសម្រួលកិច្ចការរបស់ប្អូន

A23: ប្អូនបានធ្វើកិច្ចការងារផ្ទះ (សំណួរ ឬក៏លំហាត) ដែលគ្រូប្អូនដាក់ឱ្យ

A24: ប្អូនបានចូលរួមក្លឹមសិក្សាជាមួយមិត្តភក័

A25: គ្រូប្អូនបានលើកទឹកចិត្តសិស្សពេលបង្រៀន

A26: ប្អូនមានសៀវភៅគោលសម្រាប់សិក្សារៀនសូត្រ

A27: ប្អូនបានចែករំលែកចំណេះដឹងរបស់ប្អូនដល់មិត្តរួមថ្នាក់

A28: គ្រូប្អូនបានប្រើប្រាស់ប័ណ្ណរូបភាពសម្រាប់បង្ហាញប្អូន

A29: គ្រូប្អូនបានប្រើប្រាស់ប័ណ្ណសំណួរ

ក្រាបទី២២ បានបង្ហាញថា ការប្រតិបត្តិនៃការបង្រៀន និងរៀនមានកម្រិតមធ្យមភាគ ២.៥៨ ដែលស្ថិតនៅទាបជាងគេ និងការពិភាក្សាក្រុមមានកម្រិតមធ្យមភាគ ៤.៣៣ ស្ថិតនៅកម្រិតខ្ពស់ជាងគេ ក្នុងចំណោមចំណុចរងទាំងម្ភៃប្រាំបួនគឺ ៣.៦៤។ បញ្ហាដែលប្រឈមក្នុងការប្រតិបត្តិនៃការបង្រៀន និងរៀនទៅលើការផ្លាស់ប្តូរតាក់ទិចក្នុងការផ្លាស់ប្តូរការបង្រៀន កាលវិភាគក្នុងការបង្រៀន និងការយកចិត្តទុកដាក់ទៅលើការសិក្សារបស់សិស្សដែលរៀនខ្សោយ។

**ក្រាបទី២៣៖ វង្វាយតម្លៃលទ្ធផលនៃការសិក្សា**




កំណត់សម្គាល់៖ B: វង្វាយតម្លៃលទ្ធផលនៃការសិក្សា

B1: ការចោទសួរសំណួរមានជាប្រចាំ

B2: ការវាយតម្លៃរំលឹកមេរៀនបាន

B3: ការឆ្លើយសំណួរបាន

B4: ការធ្វើកិច្ចផ្ទះតាមមេរៀននីមួយៗ

B5: ការធ្វើតេស្តប្រចាំខែរបស់ប្អូន

B6: ការធ្វើតេស្តប្រចាំឆមាស

B7: ការដាក់ពិន្ទុរបស់គ្រូមានតម្លាភាព

ក្រាបទី២៣ បានបង្ហាញថា វង្វាយតម្លៃលទ្ធផលនៃការសិក្សា ការឆ្លើយសំណួររបស់សិស្សមានកម្រិតមធ្យមភាគ ៣.៣៩ ដែលស្ថិតនៅកម្រិតទាប និង ៤.២៩ ស្ថិតនៅកម្រិតមធ្យមភាគខ្ពស់ជាង កម្រិត

មធ្យមភាគក្នុងចំណោមចំណុចរងទាំងប្រាំពីរគឺ ៣.៨២។ ទាំងនេះបានសបញ្ជាក់ឱ្យយើងដឹងថា ការឆ្លើយសំណួររបស់សិស្សស្ថិតនៅ កម្រិតមធ្យម ដែលជាចំណុចត្រូវពង្រឹងបន្ថែមទៀតទៅ លើការចោទឆ្លើយឱ្យបានត្រឹមត្រូវ ហើយជាពិសេសគ្រូត្រូវរំលឹកមេរៀនឱ្យបានទៀងទាត់ដើម្បីការរៀននិងបង្រៀនមានដំណើរការទៅដោយរលូន និងទទួលបានលទ្ធផលជាទីគាប់ចិត្ត។

### ៤.៤.៣ ផ្នែកទី៣៖ ការបង្កើតទំនាក់ទំនង និងការសហការគ្នា

**ក្រាបទី២៤៖ ការបង្កើតទំនាក់ទំនង និងការសហការគ្នា**




កំណត់សម្គាល់៖ C: ការបង្កើតទំនាក់ទំនង និងការសហការគ្នា

C1: ប្អូនធ្លាប់បានចូលរួមកម្មវិធីផ្សេងៗ

C2: គ្រួសារ បងប្អូន ញាតិសន្តានប្អូន បានគាំទ្រលើកទឹកចិត្តដល់ការសិក្សារបស់ប្អូន

C3: ប្អូនបានបង្កើតទំនាក់ទំនងជាមួយមិត្តភក្រ័

C4: ប្អូនមានទំនាក់ទំនងជាមួយលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលារៀន

C5: គ្រូបង្រៀនប្អូនប្រឹងប្រែងបង្រៀន និងពន្យល់មេរៀនដល់ប្អូន

C6: គ្រូប្អូនបានជំរុញលើកទឹកចិត្តឱ្យប្អូនខិតខំប្រឹងប្រែងរៀនសូត្រ

C7: សាលារៀនមានការរៀបចំកម្មវិធីដែលទាក់ទាញសហគមន៍ឱ្យចូលរួមដើម្បីអភិវឌ្ឍសាលារៀន

C8: ឪពុកម្តាយប្អូនមានទំនាក់ទំនងជាមួយសាលារៀនដែលប្អូនបានរៀន

តាមលទ្ធផលនៃក្រាបទី២៤ បានបង្ហាញថា ការបង្កើតទំនាក់ទំនង និងការសហការគ្នា (C8) ការទំនាក់ទំនងរបស់មាតាបិតាសិស្សជាមួយសាលារៀន នៅកម្រិតមធ្យមនៅឡើយ ដែលមានកម្រិតមធ្យមភាគ ២.៦៣ ស្ថិតនៅកម្រិតទាប និង ៤.៣១ ដែលស្ថិតនៅកម្រិតខ្ពស់ជាងមធ្យមភាគក្នុងចំណោមចំណុចរងទាំងប្រាំបីគឺ ៣.៦៩។ បញ្ហាដែលបង្ហាញក្នុងក្រាបទី២៤ នេះជាការទំនាក់ទំនងមាតាបិតាសិស្សជាមួយសាលារៀនមិនទាន់បានល្អប្រសើរនៅឡើយទេ ហើយសាលារៀនត្រូវបន្ថែមឱ្យមានកម្មវិធី ទាក់ទាញសហគន៍ឱ្យចូលរួមជាមួយសាលារៀនឱ្យបានកាន់តែច្រើនបន្ថែមទៀត។

### **៤.៤.៤ បញ្ហាប្រឈម និងសំណូមពរ**

**បញ្ហាប្រឈមដែលកើតមានឡើងផ្សេងៗ**

ផ្អែកតាមលទ្ធផលចេញពីការឆ្លើយនៅសំណួរពីសិស្សានុសិស្ស ដែលជាសំណាកគោលដៅក្នុងការចែកកម្រងសំណួរដើម្បី ជ្រើសរើសនិងឆ្លើយសំណួរក្នុងផ្នែកនីមួយៗបានបង្ហាញថា អ្នកសិក្សាស្រាវជ្រាវបានប្រទះឃើញថា បញ្ហាដែលចោទមានឡើងរួមមាន៖

- ការចូលរៀនយឺត ប៉ុន្តែចេញវិញលឿន
- ម៉ោងសិក្សាបន្ថែមតាមបណ្ណាល័យខ្វះខាត
- ការរៀបចំសណ្តាប់ធ្នាប់សាលារៀនមិនទាន់មានរបៀបគ្រប់គ្រាន់
- ការគោរពវិន័យរបស់សិស្សានុសិស្សនៅមានកង្វះខាត
- សិស្សប្រជុំគ្នាលេងទូរស័ព្ទច្រើនជាងការអានសៀវភៅ

**មតិយោបល់ និងសំណូមពរបន្ថែមរបស់សិស្សានុសិស្ស**

- ឱ្យសាលារៀនរៀបចំបរិស្ថានជុំវិញសាលារៀនប្រកបដោយផាសុខភាព
- សាលារៀនត្រូវពង្រឹងឱ្យបានម៉ឺងមាត់ទៅលើវិន័យ ទាំងការរៀបចំសម្លៀកបំពាក់ និងគោរពពេលវេលារៀនសូត្របានទៀងទាត់
- សាលារៀនគួរតែមានក្លឹមសិក្សាដើម្បីចែករំលែកចំណេះដឹង ជាមួយគ្នានិងគ្នា
- សាលាត្រូវតែមានតម្លាភាព និងសុច្ចរិតភាពត្រឹមត្រូវដោយមិនលំម្អៀងរវាងសិស្សនិងសិស្ស

- ការកែកិច្ចការត្រូវឈរទៅលើភាពយុទ្ធធម៌គ្រប់សិស្ស
- មិនត្រូវប្រកាន់បក្សពួកនិយម (គ្រូមួយចំនួនតូចស្រឡាញ់សិស្សរៀនគួរជាមួយគាត់)
- គ្រូត្រូវជួយសិស្សដែលរៀនខ្សោយ មិនត្រូវផ្តោតតែលើសិស្សរៀនពូកែនោះទេ
- ស្នើសាលារៀនពង្រឹងគុណភាពគ្រូ និងឱ្យគ្រូមកបង្រៀនបានទាន់ពេលវេលា

## ៤.៥ ការពិភាក្សា

### ៤.៥.១ ការពិភាក្សាលើសំណួរស្រាវជ្រាវទី១

**ក្រាបទី២៥៖ ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន**




តាមរយៈទិន្នន័យដែលទទួលបានពីកម្រងសំណួរសម្រាប់សម្ភាសន៍ ជាមួយកម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន កម្រងសំណួរសម្រាប់គ្រូបង្រៀន កម្រងសំណួរសម្រាប់សហគមន៍ និងកម្រងសំណួរសម្រាប់សិស្ស បានបង្ហាញឃើញអំពី ការចូលរួមរបស់សហគន៍ ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ ស្ថិតនៅកម្រិតខ្ពស់ដែលមានតម្លៃជាមធ្យមភាគរួម Mean= ៣.៦៧ , SD= 0.05 ដែលក្នុងនោះសម្រាប់គណៈគ្រប់គ្រងសាលារៀនមានកម្រិតមធ្យមភាគ Mean= ៣.៧៣, SD= 0.43 គ្រូបង្រៀនមានកម្រិតមធ្យមភាគ Mean= ៣.៦០, SD= 0.39 សហគមន៍មានកម្រិតមធ្យមភាគ Mean= ៣.៦៣, SD= 0.25 និងសិស្សមានកម្រិតមធ្យមភាគ Mean= ៣.៧១, SD= 0.07។

ទន្ទឹមនិងនោះដែរ ក្នុងក្រាបដដែលក៏បានបង្ហាញអំពីធាតុសំខាន់ៗនៃការអភិវឌ្ឍសាលារៀន មានដូចជា កត្តាគណៈគ្រប់គ្រងសាលារៀន កត្តាគ្រូបង្រៀន កត្តាសហគមន៍ និងកត្តាសិស្ស ដែលសមាសភាពទាំងអស់នេះហើយ ជាកម្លាំងចលករដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍសាលារៀន។ សហគមន៍មានតួនាទីដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសលារៀន ទំនាក់ទំនងល្អរវាងសាលារៀននិងសហគមន៍ជាកត្តាចាំបាច់មិនអាចខ្វះបានហើយសាលារៀនដំណើរការបានល្អ គឺអាស្រ័យដោយមានថវិកាទ្រទ្រង់។

### ៤.៥.២ ការពិភាក្សាលើសំណួរស្រាវជ្រាវទី២

បញ្ហាប្រឈមចម្បងៗ របស់សាលារៀនក្នុងការទាក់ទាញសហគមន៍ឱ្យចូលរួមអភិវឌ្ឍសាលារៀន

® **សកម្មភាពនៃការដឹកនាំសហគមន៍ចូលរួមអភិវឌ្ឍសាលារៀន**

ការគ្រប់គ្រងតាមសាលារៀនគឺជាដំណោះស្រាយដ៏មានប្រសិទ្ធភាព ដោយសារស្ថាប័នមានភាពរឹងមាំ ហើយសាលារៀនមានភាពស្វ័យភាព និងគណនេយ្យភាព (Eurydice, 2007)។ ជាហេតុក្នុងការស្រាវជ្រាវនេះក៏បានការបង្ហាញលទ្ធផលផងដែរថា ការកៀរគរសហគមន៍ គឺជាការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងសហគមន៍លើសកម្មភាពអភិវឌ្ឍន៍នានា ដោយការចាត់អាទិភាព ធនធាន តម្រូវការ និងដំណោះស្រាយនានាដើម្បីភាពប្រសើរឡើងនៃការចូលរួមឱ្យមានការអភិវឌ្ឍ អភិបាលកិច្ចល្អ គណនេយ្យភាព និងសន្តិភាព។ ការរំពឹងថា សហគមន៍នឹងអាចកំណត់បានអំពីបញ្ហាដែលពួកគេជួបប្រទះត្រូវការដំណោះស្រាយ ការកៀរគរធនធាន ការអនុវត្ត និងគ្រប់គ្រងគម្រោង និងធ្វើឱ្យសហគមន៍មានការផ្លាស់ប្តូរជាវិជ្ជមានប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចគោលដៅទាំងនេះថ្នាក់ដឹកនាំសាលា ត្រូវផ្តល់វគ្គបណ្តុះបណ្តាលជាប្រចាំដល់ថ្នាក់ដឹកនាំសហគមន៍ដើម្បីកសាងជំនាញ និងបទពិសោធន៍ បង្កើនឱកាស និងបង្កើនការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តផងដែរ។ ដើម្បីជំរុញឱ្យសហគមន៍មានសិទ្ធអំណាច និងមានស្វ័ភាពក្នុងការដឹកនាំ និងគ្រប់គ្រងក្នុងសហគមន៍ ដើម្បីឱ្យការអភិវឌ្ឍមាននិរន្តរភាព។

ក្រៅពីនេះការសិក្សាក៏បានរកឃើញដែរថា ការអញ្ជើញសហគមន៍ឱ្យចូលរួមក្នុងការរៀបចំផែនការនិងការរៀបចំកម្មវិធីផ្សេងៗដែលធ្វើឱ្យសហគមន៍មានភាពស្និតស្នាល បង្កើតឱកាសឱ្យពួកគាត់បញ្ចេញ

ស្នាដៃ បណ្តុះបណ្តាលអំពីការដឹកនាំសហគមន៍និងសហគមន៍ដែលធ្វើឱ្យមានទំនុកចិត្ត ហើយការចូលរួមរបស់សហគមន៍បានកាន់តែច្រើន និងយូរអង្វែងដោយតម្លាភាព។

® **ការគាំទ្រ និងការផ្សព្វផ្សាយរបស់សហគមន៍**

ពិតណាស់ក្នុងការអភិវឌ្ឍត្រូវការចំបាច់ត្រូវមានការគាំទ្រពីមជ្ឈដ្ឋានទូទៅ ជាពិសេសសហគមន៍ជាកម្លាំងជួយផ្សព្វផ្សាយ និងការគាំទ្រគ្រប់បែបយ៉ាងដើម្បីលើកស្ទួយវិស័យអប់រំមានលក្ខណៈល្អប្រសើរ និងសាលារៀនមានការអភិវឌ្ឍ។ ដូចជាការលើកឡើងរបស់ក្រសួងអប់រំ យុវជន និងកីឡា (២០២១) សហគមន៍បានដើរតួនាទីយ៉ាងសំខាន់ និងមានសក្តានុពលសម្រាប់អនុវត្តកម្មវិធី កំណែទម្រង់វិស័យអប់រំ ។ សក្តានុពលទាំងនោះមានដូចជា សហគមន៍ជាមន្ត្រីដែលមិនទាមទារប្រាក់ខែ សហគមន៍ជាមន្ត្រីដែលសម្បូរដោយទ្រព្យសម្បត្តិ មានចំណេះដឹង និងមានការប្តេជ្ញាចិត្តដើម្បីសហគមន៍ ដែលសហគមន៍ត្រូវការ គឺក្រុមប្រតិបត្តិដែលឯកភាពគ្នាក្នុងសហគមន៍ ដើម្បីពួកគេប្រើប្រាស់សក្តានុពលរបស់ពួកគេបានក្នុងការជួយសហគមន៍សាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១)។ ធនធានមនុស្សក្នុងសហគមន៍ គឺជាធនធានប្រកបដោយសក្តានុពលសម្រាប់ដំណើរការអភិវឌ្ឍសហគមន៍ ការផ្សព្វផ្សាយ និងសហគមន៍មានសមត្ថភាពក្នុងការច្នៃប្រឌិត វិភាគ ប្រាស្រ័យទាក់ទង កសាងទំនុកចិត្ត និងធ្វើសកម្មភាពរួមគ្នាដើម្បីប្រយោជន៍រួម។ ការចូលរួម និងគាំទ្ររបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ គឺជាបេះដូងនៃការចងក្រងសហគមន៍ ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តគម្រងកម្មវិធី។ ក្នុងន័យនោះ គឺការចងក្រងសហគមន៍ត្រូវមានប្រព័ន្ធសកម្មភាពច្បាស់លាស់ មានន័យថា ត្រូវចាប់ផ្តើមពីត្រង់ណា បញ្ចប់នៅត្រង់ណា ហើយសកម្មភាពអ្វីខ្លះដែលត្រូវបំពេញ។

® **សហគមន៍ចូលរួមកៀងគរដៃគូអភិវឌ្ឍន៍សាលារៀន**

ការសិក្សាជាច្រើនបានលើកហេតុផលថា ការចូលរួមរបស់សហគមន៍ជាប្រភពធនធានដែលមិនចេះរីងស្ងួត។ ការចូលរួមរបស់សហគមន៍ សំដៅដល់ប្រជាជន ការចូលរួមសកម្មភាពក្នុងវិស័យប្រព័ន្ធអប់រំ ហើយវាដើរតួយ៉ាងសំខាន់ និងយូរអង្វែង ដែលជាតួនាទីក្នុងការលើកកម្ពស់គុណភាពជីវិត (Putnam, 2000)។ ការចូលរួម និងការប្តេជ្ញាចិត្តរបស់មន្ត្រីអប់រំនៅគ្រប់កម្រិត របស់សិស្សានុសិស្ស របស់សហគមន៍

និងមានតាបិតា/អ្នកអាណាព្យាបាល ជាកត្តាចាំបាច់ដែលមិនអាចខ្វះបាន(ក្រសួងអប់រំ យុវជន និងកីឡា ,២០១៨)។ ការរៀបចំឱ្យមានសមាសភាពមកពីក្រុមប្រឹក្សាឃុំ គណៈកម្មការភូមិ នគរបាលប៉ុស្តិ៍ និងមន្ត្រីមណ្ឌលសុខភាព ជាមួយនាយកសាលា គ្រូបង្រៀន និងក្រុមប្រឹក្សាយុវជននិងកុមារ នៅក្នុងក្រុមការងារសម្រាប់អភិវឌ្ឍន៍សាលារៀន ដែលជាផ្នែកនៃគណៈកម្មការទ្រទ្រង់សាលារៀន។ ការរៀបចំឱ្យមានដំណើរការធ្វើការរួមគ្នា អាចផ្តោតទៅលើ ការគ្រប់គ្រងស្ថិតិអប់រំ សុខភាព សង្គមនិងសេដ្ឋកិច្ចក្នុងភូមិសាស្ត្រឃុំដើម្បីជានាបានពីការធ្វើបច្ចុប្បន្នភាពនូវផែនទីខ្នងផ្ទះ និងធ្វើរួមគ្នាក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន ការរៀបចំឱ្យមានការតាមដាន និងវាយតម្លៃគ្នាលើការងារអប់រំ និងការងារគណនេយ្យភាពសង្គម ទៅលើសាលារៀន។ ធនធានទាំងអស់នោះហើយ ដែលជាសេណាធិកាក្នុងការជួយកៀងគរធនធានផ្សេងៗសម្រាប់យកមកធ្វើការអភិវឌ្ឍសាលារៀន ហើយក៏ជាប្រភពធនធានដែលមិនចេះរីងស្ងួត។

❖ **អត្ថប្រយោជន៍សហគមន៍ដែលបានចូលរួមជាមួយសាលារៀន**

ឆ្លងតាមការវិភាគទិន្នន័យ និងការសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធអ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា សារៈប្រយោជន៍នៃការចូលរួមរបស់សហគមន៍ គឺបង្កើតការទុកចិត្តគ្នារវាងសហគមន៍ គ្រូបង្រៀន និងសាលារៀនដែលជាគណៈគ្រប់គ្រង ព្រមទាំងការចូលរួមរបស់មាតាបិតា និងសិស្សក្នុងការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀនដែលមានសារៈសំខាន់ដើម្បី បំពេញចន្លោះខ្វះខាតនៃការពិនិត្យតាមដានកិច្ចការរបស់នាយកសាលា និងគ្រូបង្រៀនដើម្បីឱ្យការអប់រំ និងលទ្ធផលការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អប្រសើរ។ ការទុកចិត្តនេះអាចធ្វើឱ្យមានការចូលរួម និងការបរិចាករបស់សហគមន៍ជួយដល់សាលារៀន ហើយសាលារៀន និងគ្រូបង្រៀនត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ និងមាតាបិតាតាមគោលការណ៍គណនេយ្យភាព។ សហគមន៍បានចូលរួមចំណែកដ៏សំខាន់ ជាមួយសាលារៀន ដើម្បីប្រើសក្តានុពលរបស់ខ្លួន ក្នុងការអភិវឌ្ឍសាលារៀន ចូលរួមជាគំនិតយោបល់ ដើម្បីបុព្វហេតុមនុស្សគ្រប់គ្នាក្នុងសហគមន៍ ហើយបុគ្គលទាំងអស់នោះប្រឹងប្រែងដើម្បីសហគមន៍ទាំងមូលផលដែរ។

## ៤.៦ ចំណុចខ្លាំង និងចំណុចខ្សោយ

### ៤.៦.១ ចំណុចខ្លាំង

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ «ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ» បានបង្ហាញចំណុចខ្លាំងមួយចំនួនដូចខាងក្រោមៈ

- ការស្រាវជ្រាវបានបង្ហាញថា សាលាបានធ្វើផែនការរំពឹងទុក ការបែងចែកតួនាទី ភារកិច្ច និងចំណុចទទួលខុសត្រូវតាមផ្នែកនីមួយៗ និងសហគមន៍
- ការសិក្សាស្រាវជ្រាវដែលជា ចំណុចពាក់ព័ន្ធនិងគោលនយោបាយក្រសួងអប់រំនានា ដែលជាការពន្លឿនការអភិវឌ្ឍសាលារៀន និងការអប់រំប្រកបដោយនិរន្តរភាព
- គណៈគ្រប់គ្រងសាលាមានគំនិតផ្តួចផ្តើមធ្វើកិច្ចការ ជាមួយភាគីពាក់ព័ន្ធដើម្បីកៀងគរ និងស្វែងរកមូលនិធិមកគាំពារក្នុងការអភិវឌ្ឍសាលារៀន។
- ការស្រាវជ្រាវបានរំលេចចេញនូវបញ្ហាដែលសាលារៀន និងសហគមន៍ជួបទះដូចជា សកម្មភាពនៃការដឹកនាំសហគមន៍ចូលរួមអភិវឌ្ឍន៍សាលារៀន ការគាំទ្រនិងការផ្សព្វផ្សាយរបស់សហគមន៍នឹងសហគមន៍ចូលរួមកៀងគរដៃគូអភិវឌ្ឍសាលារៀន។
- បានផ្តល់នូវចំណេះដឹងទាក់ទៅនិងតួនាទី ភារកិច្ច និងសារៈប្រយោជន៍សំខាន់ៗចំពោះការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន។
- ជាការស្រាវជ្រាវមួយដែលផ្តល់ផលប្រយោជន៍នៃចំណេះដឹង ដល់គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សិស្ស សហគមន៍ និងភាគីពាក់ព័ន្ធដើម្បីយកទៅបំរើជាផលប្រយោជន៍សង្គមជាតិទាំងបច្ចុប្បន្ន និងអនាគត។
- ជំរុញឱ្យមានទំនុកចិត្ត និងការកសាងភាពជឿជាក់ជាមួយ។
- មានផលប្រយោជន៍ជាយុទ្ធសាស្ត្រក្នុងការជួយដល់សាលារៀន និងភាគីពាក់ព័ន្ធដើម្បីចូលរួមក្នុងការអភិវឌ្ឍសាលារៀនឱ្យមានភាពផុសផុល និងសកម្មក្នុងកិច្ចការអភិវឌ្ឍសាលារៀន។
- ជាប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត យកទៅសិក្សាស្រាវជ្រាវ និងវិភាគបន្ត។

### ៤.៦.២ ចំណុចខ្សោយ

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ «ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ» បានបង្ហាញចំណុចខ្សោយមួយចំនួនដូចខាងក្រោម៖

- ការផ្សព្វផ្សាយរបស់សាលារៀនទៅកាន់មជ្ឈដ្ឋានទូទៅនៅមានកម្រិតនៅឡើយ។
- មាតាបិតា និងអាណាព្យាបាលរបស់សិស្សានុសិស្ស និងសហគមន៍ មិនទាន់មានការយល់ដឹងអំពីសារៈសំខាន់នៃការចូលរួមជាមួយសាលារៀនបានផុសផុលនៅឡើយទេ។
- ការយកចិត្តទុកដាក់អំពីការសិក្សារបស់កូន ពីសំណាក់មាតាបិតា និងអាណាព្យាបាលពុំទាន់បានច្រើននោះទេដោយសារតែ ពួកគាត់មួយចំនួនធំជាប់រវល់ និងកិច្ចការងាររកស៊ី នឹងគ្មានពេលវេលាគ្រប់គ្រាន់ ដែលធ្វើឱ្យទំនាក់ទំនងមាតាបិតា និងសាលារៀនមានភាគអសកម្មមួយចំនួនតូច។

# ជំពូក ៥

# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

# ជំពូក ៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការវិភាគទិន្នន័យដែលទទួលបានខាងលើ តាមរយៈការបំពេញកម្រងសំណួរពីភាគីពាក់ព័ន្ធដែលមាន គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សហគមន៍ និងសិស្ស និងលទ្ធផលបានបង្ហាញខាងលើ អ្នកសិក្សាស្រាវជ្រាវអាចធ្វើការសន្និដ្ឋានបានថា ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ មានស្ថានភាពល្អទាំងផ្នែកភាពជាអ្នកដឹកនាំគ្រប់គ្រង និងការអភិវឌ្ឍសាលារៀនជាមួយសហគមន៍ ការប្រាស្រ័យទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ ការសម្របសម្រួលនិងការដោះស្រាយវិវាទជាមួយសហគមន៍ ដំណើរការបង្រៀននិងរៀន ការវាយតម្លៃការសិក្សា ការបង្កើតទំនាក់ទំនងនិងការសហការគ្នាជាមួយសិស្ស និងការគៀងគរមូលនិធិពីដៃគូផ្សេងៗទៀត។ ទាំងអស់នេះក៏បានបង្ហាញ និងឆ្លុះបញ្ចាំងឱ្យឃើញថា ការខិតខំប្រឹងប្រែងដឹកនាំ និងការគ្រប់គ្រងពីគណៈគ្រប់គ្រង ឱ្យអនុវត្តន៍បាននូវគោលនយោបាយរបស់ក្រសួងអប់រំ អំពីសហគមន៍សាលារៀនដែលជាការជំរុញឱ្យមានការចូលរួមពីសហគមន៍ និងភាគីពាក់ព័ន្ធ ដើម្បីអភិវឌ្ឍសាលារៀន ហើយក៏ជាប្រភពធនធានដែលមិនចេះរីងស្ងួត។

មួយវិញទៀត ក្នុងកិច្ចការស្រាវជ្រាវក៏រកឃើញនូវចំណុចមួយចំនួន ដែលគួរអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរឡើងគឺ ត្រូវបានបង្កើតនូវសេចក្តីទុកចិត្តរវាងគណៈគ្រប់គ្រង និងសហគមន៍ដើម្បីឱ្យមានភាពជឿជាក់ទៅលើគ្នាទៅវិញទៅមកដើម្បីអភិវឌ្ឍសាលារៀន។ លើសពីនេះទៀតនោះ ក្នុងការធ្វើកិច្ចការ និងអនុវត្តន៍ផែនការអភិវឌ្ឍសាលារៀនត្រូវមានការចូលរួមជាមួយភាគីពាក់ព័ន្ធដោយភាពស្មោះត្រង់ ការប្រាស្រ័យទំនាក់ទំនងឱ្យកាន់តែប្រសើរឡើង និងការសម្របសម្រួល ដើម្បីដោះស្រាយបញ្ហា និងការលើកកម្ពស់គុណភាពអប់រំ និងការអភិវឌ្ឍសាលារៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

## ៥.២ សំណូមពរ

ក្នុងកិច្ចការស្រាវជ្រាវទៅលើប្រធានបទ «**ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យក្នុងខេត្តកំពង់ស្ពឺ**» ឃើញថា ការចូលរួមរបស់សហគមន៍ និងភាគីពាក់ព័ន្ធដើម្បីអភិវឌ្ឍន៍សាលារៀន ពិតជាមានសារៈសំខាន់ដែលមិនអាចខ្វះបាន ដូច្នេះស្នើភាគីពាក់ព័ន្ធនិងគណៈគ្រប់គ្រងបង្កើតការសហការគ្នាដើម្បីបន្តនិរន្តរភាពអភិវឌ្ឍសាលារៀន និងគៀងគររកមូលនិធិបន្ថែមទៀតដើម្បីទ្រទ្រង់សាលារៀន។

### ៥.២.១ ចំពោះគណៈគ្រប់គ្រងសាលារៀន

- សូមគណៈគ្រប់គ្រងបង្កើនសមត្ថភាពក្នុងការអភិវឌ្ឍជំនាញលើវិជ្ជាជីវៈរបស់ខ្លួនឱ្យបានជាប្រចាំតាមដែលអាចធ្វើទៅបាន ក្នុងការជួយប្រសិទ្ធភាពការងារឱ្យបានកាន់តែប្រសើរឡើង។
- សូមគណៈគ្រប់គ្រងពង្រឹងការទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដោយមានការទទួលខុសត្រូវខ្ពស់ដោយមិនមានការរើសអើង និងការប្រកាន់បក្សពួកនិយម។
- សូមគណៈគ្រប់គ្រងបង្កើនការផ្សព្វផ្សាយ និងជួបពិភាក្សាជាមួយមាតាបិតារបស់សិស្ស សហគមន៍ និងភាគីពាក់ព័ន្ធឱ្យបានកាន់តែញឹកញាប់បន្ថែមទៀត។
- សូមគណៈគ្រប់គ្រងផ្តល់នូវព័ត៌មានឱ្យបានទៀងទាត់ និងច្បាស់លាស់ដល់មាតាបិតា អាណាព្យាបាល និងអ្នកពាក់ព័ន្ធដទៃទៀតឱ្យបានទូលំទូលាយ។

### ៥.២.២ ចំពោះគ្រូបង្រៀន

- សូមគ្រូបង្រៀនមកបង្រៀនឱ្យបានទៀងទាត់ ជៀសវាងការចូលយឺតហើយចេញមុន
- សូមគ្រូបង្រៀនជួយពង្រឹង និងណែនាំសិស្សឱ្យអស់ពីសមត្ថភាព ទៅលើសិស្សដែលរៀនយឺតទៅលើមេរៀន និងមុខវិជ្ជារបស់ខ្លួន
- សូមលោកគ្រូ អ្នកគ្រូបង្កើនការស្រាវជ្រាវទៅលើវិធីសាស្ត្របង្រៀន និងពង្រឹងទៅលើមុខវិជ្ជាឯកទេសរបស់ខ្លួនឱ្យបានជាប្រចាំ និងទៀតទាត់ដើម្បីមានភាពងាយស្រួលក្នុងការផ្ទេរ ចំណេះដឹងទាំងទ្រឹស្តីនិងការអនុវត្តទៅកាន់សិស្សមានភាពប្រសិទ្ធភាពខ្ពស់ជាងនេះ។

- សូមលោកគ្រូ អ្នកគ្រូធ្វើការទំនាក់ទំនងជាសហគមន៍ឱ្យបានញឹកញាប់ ដើម្បីជាផ្តល់ព័ត៌មាន និង ការទទួលព័ត៌មានត្រឡប់មកវិញ ហើយក៏ជាការជួយពន្យល់ណែនាំដល់សហគមន៍ ឱ្យមានការ យល់ដឹងបានកាន់តែស៊ីជម្រៅអំពីការអប់រំ និងការចូលរួមរបស់ពួកគាត់ជាមួយសាលារៀន។

**៥.២.៣ ចំពោះសហគមន៍**

- សូមមាតាបិតា ព្យាយាមស្វែងយល់អំពីព័ត៌មានការអប់រំ និងសាលារៀន ក្នុងការតាមដានត្រួត ពិនិត្យ ការវាយតម្លៃការសិក្សារបស់កូនៗបានទៀងទាត់ ហើយដើម្បីបង្កើតទំនាក់ទំនងល្អជាមួយ សាលារៀន ដែលជាការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ
- សូមសហគមន៍ និងភាគីពាក់ព័ន្ធ ត្រូវមានសាមគីភាពល្អ មានការសហការ ព្រមទាំងផ្តល់ជា យោបល់ដល់សាលារៀនដើម្បីកែលម្អ ហើយជួយគៀងគរកមូលនិធិក្នុងការជួយទ្រទ្រង់សាលា រៀនឱ្យមានការអភិវឌ្ឍ
- សូមមាតាបិតាសិស្ស និងមជ្ឈដ្ឋានទូទៅ ធ្វើជាគំរូល្អសម្រាប់ប្រជាពលរដ្ឋទូទៅក្នុងការចូលរួមជា មួយសាលារៀនមានដូចជា មូលនិធិជាថវិកា និងសម្ភារៈផ្សេងៗសម្រាប់គាំពារការអប់រំ និងការ អភិវឌ្ឍសាលារៀន។

**៥.២.៤ សម្រាប់សិស្សានុសិស្ស**

- សូមសិស្សានុសិស្សពង្រឹងបន្ថែមសមត្ថភាពលើចំណេះដឹងរបស់ខ្លួន ដោយធ្វើការស្វ័យសិក្សា បន្ថែមទៀតដើម្បីបំពេញចន្លោះខ្វះខាត ដើម្បីធ្វើការឆ្លើយតបក្នុងតម្រូវការទីផ្សារបច្ចុប្បន្ន និង ការប្រកួតប្រជែងនាពេលខាងមុខ។
- សូមសិស្សានុសិស្ស ធ្វើជាគំរូល្អ ដោយខិតខំប្រឹងប្រែងរៀនសូត្រ មានគោលដៅនិងផែនការសិក្សា របស់ខ្លួនច្បាស់លាស់ ការគ្រប់គ្រងពេលវេលាសិក្សាឱ្យបានត្រឹមត្រូវ និងធ្វើកិច្ចដែលលោកគ្រូ អ្នក គ្រូដាក់ឱ្យធ្វើដោយទៀងទាត់និងទាន់ពេលវេលា។

### ៥.២.៥ សំណូមពរដល់អ្នកជំនាន់ក្រោយ

- កិច្ចស្រាវជ្រាវនេះ សិក្សាទៅលើប្រធានបទ ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ ដែលជាការបកស្រាយអំពីការចូលរួមរបស់គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ សហគមន៍ និងសិស្សានុសិស្សដើម្បីអភិវឌ្ឍសាលារៀន។ ទោះបីជាមានការបង្ហាញនិងការបកស្រាយយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវនេះក៏នៅមានចំនុចខ្វះខាត និងត្រូវបំពេញបន្ថែមទៀត។ ដើម្បីឱ្យមានលក្ខណៈប្រសើរជាងនេះ ស្នើដល់អ្នកស្រាវជ្រាវជំនាន់ក្រោយៗធ្វើការស្រាវជ្រាវទៅលើប្រធានបទនេះបន្ថែមទៀត។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *សៀវភៅណែនាំប្រតិបត្តិ ស្តីពីការគ្រប់គ្រងតាមសាលារៀន*។ រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) *ការរៀបចំផែនការអភិវឌ្ឍសាលារៀន* រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១០) *គោលនយោបាយស្តីពី ការអភិវឌ្ឍកម្រងសាលារៀន*។ រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *សេចក្តីណែនាំប្រតិបត្តិយុទ្ធសាស្ត្រសហគមន៍សាលារៀន*។ រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *ផែនទី បង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ ២០៣០*។ រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) *សៀវភៅណែនាំសម្រាប់សាលារៀន និងសហគមន៍*។ រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤*។ រាជធានីភ្នំពេញ។

គម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) (២០១៦) *ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់*។ រាជធានីភ្នំពេញ។

ណាត ជួន (១៩៦៧) *វចនានុក្រមសម្តេចពោធិញាណជួនណាត*។ រាជធានីភ្នំពេញ

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩ - ២០២៣*។ រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) *ស្តង់ដានាយកសាលារៀន*។ រាជធានីភ្នំពេញ។

គម្រោងកែលម្អការអប់រំចំណេះទូទៅ(GEIP) (២០២២) *ឯកសារស្តីពីយុទ្ធសាស្ត្រសហគមន៍សាលារៀនទី១*។ រាជធានីភ្នំពេញ។

រាជរដ្ឋាភិបាលកម្ពុជា (២០២១) *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១ - ២០៣៥* ។ រាជធានីភ្នំពេញ។

ក្រសួងមហាផ្ទៃ (២០២២) *ការគ្រប់គ្រងដំណើរការអប់រំឳពុកម្តាយ អាណាព្យាបាល ក្នុងការគាំពារនិងអភិវឌ្ឍកុមារតូច សម្រាប់ឃុំ សង្កាត់*។ រាជធានីភ្នំពេញ។

ថៅ លិន (២០០៥) *សង្គមវិទ្យាអប់រំ*។ រាជធានីភ្នំពេញ, ទំព័រ ៦៧- ៦៨។

Aref, A. (2011). *Community Participation for Educational Planning and Development*. Islamic Azad University, Fars, Iran.

Fariborz A., Ma′rof R., and Sarjit S.G. (2009). Dimensions of Community Capacity Building: A eview of its Implications in Tourism Development. Journal of American Science 5 (8):74- 82.

Arnstein, Sherry R. (1969). A ladder of citizen participation. Journal of American in statute of planners 35 (4):216-224.

Choguill, Marisa B.G. (1996).*A ladder of community participation for underdevelopment countries*. Habitat international 30 (Ed.3):431-444.

Cole, Stroma. (2007). *Tourism, culture and development: hopes, dreams and realities in East Indonesia*. Clevedon, UK: Channel View Publications.

Lasker, R.D, Weiss E.S., and Miller R. (2001). *Partnership synergy: A practical framework for studying and strengthening the collaborative advantage*. The Milbank Quarterly 79 (2):179-205.

Leksakundilok, A. (2006). *Community Participation in Ecotourism Development in Thailand.*, University of Sydney. Geosciences.

Miranda, Eduardo M. (2007). *Gang injunctions and community participation, Faculty of The School of Policy, Planning, and Development University of Southern*. California.

Sa′ad, T. U., & Sadiq, A. M. (2014). The Relevance of School Community Relationship on the Development of Primary Education in Azare Metropolis of Bauchi State, Nigeria. IOSR Journal of Research & Method in Education (IOSR-JRME), 4(6), 23-29.

Mikiko, N. (2017). *Community participation in school management in developing countries*. NewYork, https://doi.org/10.1093/acrefore/9780190264093.013.6 (29 March 2017)

Somerset, A. (2009). *Universalising primary education in Kenya: The elusive goal*. Comparative Education, 45(2), 233–250.

Shaeffer, Sheldon, ed. (1992). Collaborating for Educational Change: the Role of Teachers, Parents and the Community in School Improvement. Paris: UNESCO, International Institute for Educational Planning.

Shaeffer, S.E. (1994). *Partnerships and Participation in Basic Education: A Series of Training Modules and Case Study Abstracts for Educational Planners and Mangers*. Paris: UNESCO, International Institute for Educational Planning.

Jennefer, S.M. (2006). *Community Participation in Schooling*. Harvard Educational Review 76 (3): 339–368.

Molles, M. (2010). *Ecology and community, 5th ed.*. McGraw-Hill Publishing Company, New York.

Pretty, Jules N. (1995). *Participatory learning for sustainable agriculture*. World development 23 (8):1247-1263

Putnam, R. D. (2000). Bowling Alone: *The collapse and Revival of American Community*. Edited by S. a. Schuster. New York.

Uemura, Mitsue. (1999). *Community Participation in Education*. New York

UNICEF. (1992). *Strategies to Promote Girls' Education: Policies and Programmes that Work.* New York: UNICEF.

# ឧបសម្ព័ន្ធទី១៖ លិខិតបង្គាប់ការរបស់គណៈកម្មការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :** ៤៨០......**វជអ.** សក

## លិខិតបង្គាប់ការ

យោង៖ - លិខិតឧទ្ទេសនាមលេខ៨៤៧៣ អយក.ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការមេប្រយោគ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

- លិខិតឧទ្ទេសនាមលេខ៨៥០១ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៤ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការរៀបចំ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៦ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការគណនេយ្យ និងសម្ភារៈ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៥ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការកណ្តាល សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

បុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៨-៩ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៨:០០នាទីព្រឹក នៅវិទ្យាស្ថានជាតិអប់រំ៖

I. **គណៈកម្មការការពារនិក្ខេបបទ**

**ក្រុមទី១ នៅអគារ** B07 **បន្ទប់** 101

| **គោត្តនាម និងនាម** | | **អង្គភាព** | **តួនាទី** |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិកា |
| ៣- លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

| | | | |
|---|---|---|---|
| ៥- លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី២ នៅអគារ** B07 **បន្ទប់** 105

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | ប៊ិច សៀង | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៣- លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកបណ្ឌិត | ទៀង សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន គឹមរៀង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៣ នៅអគារ** B07 **បន្ទប់** 107

| | | | |
|---|---|---|---|
| ១- លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | អែ សុងហ៊ាង | មជ្ឈមណ្ឌល SEAMEO TED | សមាជិក |
| ៣- លោកបណ្ឌិត | កាន់ ពុទ្ធី | នាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៤- លោកស្រី | សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៥- លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន ស៊ីណូត | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៤ នៅអគារ** B07 **បន្ទប់** 109

| | | | |
|---|---|---|---|
| ១- លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៣- លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៤- លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | ណុច ស្រីនាង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៥ នៅអគារ** B07 **បន្ទប់** 110

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២- លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៤- លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

| | | | |
|---|---|---|---|
| ៦- លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨- កញ្ញា | ភាព សុខនី | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៦ នៅ B07 បន្ទប់ 111**

| | | | |
|---|---|---|---|
| ១- លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ៣- លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោកបណ្ឌិត | អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

II. **គណៈកម្មការកណ្តាល** B07 **បន្ទប់ 103**

| | | | |
|---|---|---|---|
| ១- លោកស្រី | ធុក ផល្លីនី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | ធ្វើកំណត់ហេតុ |
| ៣- លោកស្រី | ទៀប ច័ន្ទវត្តី | វិទ្យាស្ថានជាតិអប់រំ | រៀបចំជាប់/ធ្លាក់ |
| ៤- កញ្ញា | ឈឹន លីន | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |
| ៥- លោកស្រី | ម៉ម ចំប៉ី | វិទ្យាស្ថានជាតិអប់រំ | បូកពិន្ទុ/ផ្ទៀងផ្ទាត់ |

III. **គណៈកម្មការរដ្ឋបាល និងគណនេយ្យ**

| | | | |
|---|---|---|---|
| ១- លោក | គិន កោសល្ល | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក | ឡេង បូរី | វិទ្យាស្ថានជាតិអប់រំ | រៀបចំបន្ទប់/សម្ភារៈ |
| ៣- លោកស្រី | អ៊ុំ សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | រៀបចំហិរញ្ញវត្ថុ |
| ៤- លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |

ថ្ងៃ ច័ន្ទ ៩រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការអំណែនាំទម្រង់**

**បណ្ឌិត ឱ្យ ខាំបូលី**

**កន្លែងទទួល៖**

- ការិយាល័យ/ដេប៉ាតឺម៉ង់នៃ វជអ ដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ.វជអ

3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ៧៤៧ វជអ. ៨៩

## ប្រធានបទនិក្ខេបបទស្រាវជ្រាវ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម-នាមនិស្សិត |
|---|---|---|
| ១ | ទស្សនៈគ្រូបង្រៀនចំពោះការគ្រប់គ្រងសាលារៀនរបស់នាយកសាលារៀនមធ្យមសិក្សាក្នុងខេត្តកណ្តាល | កង សុផារ៉ាមី |
| ២ | ទស្សនសហគមន៍ចំពោះកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ករណីសិក្សាខេត្តកំពង់ចាម | កន កុល |
| ៣ | កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាករណីសិក្សាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបាវិតខេត្តស្វាយរៀង | គង់ បូរ៉ា |
| ៤ | ឥរិយាបថ និងសមត្ថភាពគ្រូបង្រៀនចំពោះការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)នៅសាលាមធ្យមសិក្សាជនជាតក្នុងខេត្តតាកែវ | គុយ វឌ្ឍា |
| ៥ | គោលការណ៍ណែនាំអំពីការគ្រប់គ្រងការអនុវត្តអធិការកិច្ចនៅកម្រិតបឋមសិក្សាក្នុងក្រុងស្ទឹងសែន ខេត្តកំពង់ធំ | គៅ លីមហ៊ាត់ |
| ៦ | ទស្សនៈរបស់បុគ្គលិកអប់រំ និងសហគមន៍ទៅលើប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាបឋមភូមិករណីសិក្សាក្នុងស្រុករមាសហែកខេត្តស្វាយរៀង | ជុំ ជឿន |
| ៧ | ប្រសិទ្ធភាពនៃការគ្រប់គ្រងអគារធនធាន និងសាលាបណ្តាញក្នុងខេត្តរតនគិរី | ឈឹម ឌីនគោ |
| ៨ | ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាជនជានក្នុងខេត្តស្វាយរៀង | ញ៉ឹក កិត្យា |
| ៩ | ការសិក្សាប្រៀបធៀបនៃការអនុវត្តគោលការណ៍គណនេយ្យភាពសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | ទឿន រតនៈ |
| ១០ | តម្រូវការអន្តរកម្មឌីជីថលលើការបំពេញការងាររបស់គ្រូបង្រៀនក្នុងខេត្តកំពង់ស្ពឺ | ជឿន វឌ្ឍា |
| ១១ | ស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំរបស់នាយកសាលាមធ្យមសិក្សាក្នុងខេត្តកំពង់ចាម | ពុំ សុធីតាមុនី |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ www.nie.edu.kh

| | | |
|---|---|---|
| ១២ | ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង | ពៅ ស្រីម៉ៅ |
| ១៣ | ស្ថានភាពនៃការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាធនធាននៅក្នុងខេត្តកំពង់ឆ្នាំង | ព្រុំ ណារិន |
| ១៤ | ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ | ម៉ុល មួយគា |
| ១៥ | ស្ថានភាពនៃការគ្រប់គ្រងការអនុវត្តដឹកនាំដំណើរការសាលារៀននៅតាមអនុវិទ្យាល័យក្នុង តំបន់លិចទឹកករណីសិក្សាខេត្តកំពង់ឆ្នាំង | ម៉ោញ សុធារ័ត្ន |
| ១៦ | ស្ថានភាពនៃការបង្រៀន និងរៀនតាមបែបស្ទែម(STEM)នៅសាលារៀនជំនាន់ថ្មី ក្នុងខេត្តកណ្តាល | មឿន ផល្លា |
| ១៧ | កម្រិតយល់ដឹងដោយគរុសិស្សលើអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាននៅគ្រឹះស្ថាន បណ្តុះបណ្តាលគ្រូក្នុងខេត្តព្រៃវែង | យ៉ម រិទ្ធី |
| ១៨ | ស្ថានភាពនៃការគ្រប់គ្រងធនធានរូបវន្តនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម | យឹម ធារ៉ា |
| ១៩ | ស្ថានភាពនៃការអនុវត្តគណនេយ្យភាពអ្នកដឹកនាំរបស់នាយកសាលាបឋមសិក្សាក្នុង ខេត្តត្បូងឃ្មុំ | លី សុផា |
| ២០ | ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យក្នុង ខេត្តកំពង់ស្ពឺ | សឹម កក្កី |
| ២១ | ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត | សួង គឹមសាន |
| ២២ | ស្ថានភាពនៃការគ្រប់គ្រងនិងប្រើប្រាស់បណ្ណាល័យនៅបឋមសិក្សាក្នុងខេត្តកំពត | សេន ម៉ៅ |
| ២៣ | ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យម សិក្សាទុតិយភូមិនៅកម្ពុជាករណីសិក្សាខេត្តតាកែវ | សែម ជ្រាន |
| ២៤ | ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងសុខភាពសិក្សានៅសាលាបឋមសិក្សាក្នុងខេត្តតាកែវ | សោ សុផាត |
| ២៥ | ស្ថានភាពនៃការរៀបចំ និងអនុវត្តតេស្តស្តង់ដាកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង | ហ៊ឹង សុវណ្ណា |
| ២៦ | កត្តាជះឥទ្ធិពលលើជម្រើសសិក្សាសម្រាប់អាជីពនាពេលអនាគតរបស់សិស្សមធ្យមសិក្សា បច្ចេកទេសនៅខេត្តកំពង់ឆ្នាំង កំពង់ធំ និងកំពង់ស្ពឺ | ហឿន សារ៉ុត |
| ២៧ | កត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេសសិស្សមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ | អិន ផល្លាក់ |
| ២៨ | ប្រសិទ្ធភាពនៃការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបដំណោះស្រាយបញ្ហាដោយបញ្ចូល ICT ក្នុងការបង្រៀនគណិតវិទ្យានៅវិទ្យាល័យនៅរាជធានីភ្នំពេញ | អ៊ាង ប៊ុនរឿង |
| ២៩ | ការសិក្សាឥទ្ធិពលលក្ខណៈនៃភាពជាអ្នកដឹកនាំបែបស្វ័យភាពរបស់នាយកទៅលើការពេញចិត្ត ក្នុងការបម្រើការងាររបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យ | អូន ពិសី |
| ៣០ | ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យខេត្តតាកែវ | អៀក ចន្ទី |
| ៣១ | ស្ថានភាពការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិត បឋមសិក្សាក្នុងខេត្តស្វាយរៀង | វ៉ា សុភ័ក្រ្តា |

| | | |
|---|---|---|
| ៣២ | ការអភិវឌ្ឍយុទ្ធសាស្ត្រលើកកម្ពស់គុណសម្បទាសតវត្សទី២១របស់យុវជនករណីសិក្សាខេត្តសៀមរាប | មៀច បូរ៉ា |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១៣រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខណ្ណា

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

**កន្លែងទទួល៖**

-សាមីខ្លួន " ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ ជេអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ៦៤៧ វជអ. ៥៨

## ប្រធានបទនិក្ខេបបទស្រាវជ្រាវ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

និស្សិតបង់ថ្លៃសេវាសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម-នាមនិស្សិត |
|---|---|---|
| ១ | ស្ថានភាពនៃការអនុវត្តគោលការណ៍អភិបាលកិច្ចនៅសាលារៀនជំនាន់ថ្មី នៅរាជធានីភ្នំពេញ | គៀត គីក |
| ២ | ឧត្តមានុវត្តន៍នៃការដឹកនាំគ្រប់គ្រងរបស់នាយកសាលាវេស្ទើនអន្តរជាតិ ករណីសិក្សាសាលាវេស្ទើនអន្តរជាតិសាខាStadium | ឌី ភារុន |
| ៣ | ស្ថានភាពនៃភាពជាអ្នកដឹកនាំគ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តស្វាយរៀង | ប៉ែន បារាំង |
| ៤ | ស្ថានភាពនៃការអនុវត្តគោលនយោបាយអប់រំស្នែម នៅសាលារៀនជំនាន់ថ្មីក្នុងប្រទេសកម្ពុជា | រស់ រដ្ឋា |
| ៥ | ទស្សនៈសហគមន៍ចំពោះកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិពីឆ្នាំ២០២១ដល់ឆ្នាំ២០២២ករណីសិក្សាក្នុងខេត្តកំពង់ចាម | លឿង កុសល |
| ៦ | ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងក្រុមបច្ចេកទេសមុខវិជ្ជានៅវិទ្យាល័យក្នុងខេត្តពោធិ៍សាត | វ៉ាន់ ចាន់រ៉ាត |
| ៧ | ឥទ្ធិពលនៃការប្រើប្រាស់ស្មាតហ្វូនលើការសិក្សារបស់សិស្សវិទ្យាល័យក្នុងខេត្តរតនគិរី | សន សុភារ៉ា |
| ៨ | ស្ថានភាពនៃការគ្រប់គ្រងការបង្រៀនកុមារបញ្ញាសតិបញ្ញានិងអូទីសឹមក្នុងខេត្តកណ្តាល និងរាជធានីភ្នំពេញ | សុខ កែវរតនា |
| ៩ | ស្ថានភាពនៃការគ្រប់គ្រងសាលារៀនដោយប្រើប្រាស់ប្រព័ន្ធ CAMEMIS នៅវិទ្យាល័យក្នុងរាជធានីភ្នំពេញ | សេង សាដាត់ |
| ១០ | ការអភិវឌ្ឍធនធានមនុស្សក្នុងបរិវត្តកម្មឌីជីថលនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងរាជធានីភ្នំពេញ | ហុង លក្ខិណា |
| ១១ | ស្ថានភាពនៃការអនុវត្តស្តង់ដាកម្មវិធីសិក្សាបឋមសិក្សាក្នុងរាជធានីភ្នំពេញ | អ៊ុក រតនា |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៣រោច ៨ ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**
**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី ខាំបូលី

**កន្លែងទទួល៖**
-សាមីខ្លួន " ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វដអ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**

**គោរពជូន**
**ឯកឧត្តមបណ្ឌិតនាយក វិទ្យាស្ថានជាតិអប់រំ**

អនុញ្ញាតឲ្យនិស្សិតឈ្មោះ ៖ **ស៊ឹម ភក្តី**
ប្រធានបទស្រាវជ្រាវ ៖ **ការចូលរួមរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលារៀន នៅកម្រិតវិទ្យាល័យ ក្នុងខេត្តកំពង់ស្ពឺ**
ដើម្បីចូលរួម ៖ ការពារនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០
កាលបរិច្ឆេទការពារបញ្ចប់ ៖ ថ្ងៃទី០៩-១០ ខែធ្នូ ឆ្នាំ២០២៣ ម៉ោង០៧:០០នាទីព្រឹក
ទីកន្លែង ៖ **វិទ្យាស្ថានជាតិអប់រំ**

យើងខ្ញុំជាគ្រូណែនាំបង្គោល និងគ្រូណែនាំរង ពិតជាបានអនុញ្ញាតឱ្យនិស្សិតមានឈ្មោះខាងលើចូលរួមការពារនិក្ខេបបទដើម្បីបំពេញក្របខ័ណ្ឌការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ តាមការកំណត់របស់ វិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃ **ពុធ ៣ កើត** ខែ **កត្តិក** **ឆ្នាំថោះ** បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី **១៥** ខែ **វិច្ឆិកា** ឆ្នាំ២០២៣

**គ្រូណែនាំបង្គោល** | **គ្រូណែនាំរង**

**បណ្ឌិត គួយ សូគាន** | **បណ្ឌិត នី រដ្ឋា**

## ឧបសម្ព័ន្ធទី២៖ លិខិតចាត់តាំងគ្រូដឹកនាំគោល និងគ្រូដឹកនាំរង សម្រាប់សរសេរនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៧៤៧២អយក.ខធក

### លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | គោត្តនាម-នាម និស្សិត |
|---|---|---|---|
| ១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | កង សុផារ៉ាមី |
| ២ | បណ្ឌិត នី វដ្ឋា | បណ្ឌិត ទី សុផល | កន កុល |
| ៣ | បណ្ឌិត អាន វ៉ុប្រាវ | បណ្ឌិត ទី សុផល | គង់ បូរ៉ា |
| ៤ | បណ្ឌិត ឌី ខាំបូលី | បណ្ឌិត កាន់ ពុទ្ធី | គុយ វដ្ឋា |
| ៥ | បណ្ឌិត ម៉ម ចាន់សៀន | បណ្ឌិត ប៊ិច សៀង | គៅ លឹមហ៊ាត់ |
| ៦ | បណ្ឌិត ឡឹយ សុខគា | បណ្ឌិត គួយ សូគាន | ជុំ ជឿន |
| ៧ | លោក លឹម វ៉ាន់ | បណ្ឌិត គួយ សូគាន | ឈឹម ឌីនគោ |
| ៨ | បណ្ឌិត សៀង សុវណ្ណា | បណ្ឌិត នៀ សុផន | ញ៉ឹក កិត្យា |
| ៩ | លោកស្រី នូ ចន្នី | បណ្ឌិត ឈាង សង្វាត | ទឿន រតនៈ |
| ១០ | បណ្ឌិត ឈាង សង្វាត | លោក ម៉ន មុនិន្ទ | ជឿន វដ្ឋា |
| ១១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | ពុំ សុជីតាមុនី |
| ១២ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត សោម វណ្ណៈ | ពៅ ស្រីម៉ៅ |
| ១៣ | បណ្ឌិត នូវ វីរ៉ា | បណ្ឌិត នៀ សុផន | ព្រុំ ណារិន |
| ១៤ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត នី វដ្ឋា | ម៉ុល មួយគា |
| ១៥ | បណ្ឌិត នូវ វីរ៉ា | លោក ចាប រតនា | ម៉ោញ សុជាត័ន្ទ |
| ១៦ | លោកស្រី ប៊ុន សុផានី | លោក ថៃ ហេង | មឿន ផល្លា |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ១៧ | បណ្ឌិត លី គិមឡុង | លោក ចាន់ រ៉ាដា | យ៉ម វុទ្ធី |
| ១៨ | លោក ឡុច ចាន់ថន | បណ្ឌិត បូ ច័ន្ទគុលិកា | យីម ផារ៉ា |
| ១៩ | បណ្ឌិត សិត សេង | បណ្ឌិត អាន វ៉ូប្រាវ | លី សុផា |
| ២០ | បណ្ឌិត គួយ សូគាន | បណ្ឌិត នី វឌ្ឍា | សឹម ភក្តី |
| ២១ | លោក ចាន់ ធឿន | បណ្ឌិត ឈន ថន | សួង គីមសាន |
| ២២ | បណ្ឌិត ឈន ថន | បណ្ឌិត សោន វណ្ណៈ | សេន ម៉ៅ |
| ២៣ | បណ្ឌិត សិត សេង | បណ្ឌិត នូវ វីរ៉ា | សែម ជ្រាន |
| ២៤ | បណ្ឌិត លី គិមឡុង | បណ្ឌិត ឌី ខាំបូលី | សោ សុផាត |
| ២៥ | បណ្ឌិត អាន វ៉ូប្រាវ | លោក ឡុច ចាន់ថន | ហ៊ីង សុវណ្ណា |
| ២៦ | លោក ចាប រតនា | បណ្ឌិត ម៉ម ចាន់សៀន | ហឿន សារ៉ុត |
| ២៧ | បណ្ឌិត សោន វណ្ណៈ | លោក ប៉ូ ប៊ុន្នន | អ៊ិន ផល្លាក់ |
| ២៨ | លោក ចាន់ រ៉ាដា | បណ្ឌិត សិត សេង | អ៊ាង ប៊ុនរឿង |
| ២៩ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត លី គិមឡុង | អួន ពិសី |
| ៣០ | បណ្ឌិត ឡឹយ សុខគា | បណ្ឌិត ឈន ថន | អៀក ចន្ទី |
| ៣១ | បណ្ឌិត ម៉ម ចាន់សៀន | លោក ចាប រតនា | រ៉ា សុភ័ក្ត្រា |
| ៣២ | បណ្ឌិត ជ័យ សារិន | បណ្ឌិត ឡឹយ សុខគា | មៀច បូរ៉ា |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៥ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ ដេអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៤៧៣ អយក.ខ៩ន

# លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតបង់ថ្លៃសេវាសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំៈ

| ល.រ | គោត្តនាម-នាម<br>គ្រូណែនាំគោល | គោត្តនាម-នាម<br>គ្រូណែនាំរង | គោត្តនាម-នាម<br>និស្សិត |
|---|---|---|---|
| ១ | លោក ម៉ៅ សារឿន | បណ្ឌិត អាន វ៉ូប្រាវ | គៀត កឹក |
| ២ | បណ្ឌិត សៀង សុវណ្ណា | លោក ម៉ៅ សារឿន | ឌី ភារុន |
| ៣ | បណ្ឌិត គួយ សូគាន | បណ្ឌិត ទៀង សោភទ្រា | ប៉ែន បារាំង |
| ៤ | លោក ម៉ន មុនិន្ទ | បណ្ឌិត ឈាង សង្វាត | រស់ វដ្ឋា |
| ៥ | បណ្ឌិត នី វដ្ឋា | បណ្ឌិត សិត សេង | លឿង កុសល |
| ៦ | បណ្ឌិត ឈន ថន | លោក ចាន់ ធឿន | វ៉ាន់ ចាន់វ៉ាត |
| ៧ | បណ្ឌិត សោន វណ្ណៈ | លោកស្រី សាំង សុចិន្តា | សន សុភារ៉ា |
| ៨ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត អែ សុងហ៊ាង | សុខ កែវរតនា |
| ៩ | លោក ថៃ ហេង | បណ្ឌិត នូវ វីរ៉ា | សេង សាដាត់ |
| ១០ | បណ្ឌិត ឈាង សង្វាត | លោកស្រី នូ ចន្នី | ហុង លក្ខិណា |
| ១១ | បណ្ឌិត សឿង សុផា | បណ្ឌិត ម៉ម ចាន់សៀន | អ៊ុក រតនា |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមាននាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១០កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វដអ

# ឧបសម្ព័ន្ធទី៣៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៤០៨៧ អយក.វដស

ថ្ងៃ ចន្ទ ៨ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣

**ជម្រាបជូន**

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា**
- **លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ លោក លោកស្រី ថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន ៤៣នាក់ ស្រី ១០នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមបណ្តាអង្គភាពមួយចំនួន ក្រោមឱវាទទីស្តីក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ចាប់ពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ផ្តល់កិច្ចសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវគោរពរាប់អានដ៏ស្មោះពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក "ដើម្បីជ្រាបព័ត៌មាន និងសហការ"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤០៧២ អយក.វិឯអ

មន្ទីរអប់រំយុវជន និងកីឡាខេត្ត[illegible]
ចូល លេខ [illegible]
ថ្ងៃទី 21 ខែ 07 ឆ្នាំ 2023
ម៉ោង [illegible]

ថ្ងៃ ច័ន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០២៣

**ជម្រាបជូន**

- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការ ក្រសួងអប់រំ យុវជន និងកីឡា**
- **លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន ៤៣នាក់ ស្រី ១០នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមបណ្តាអង្គភាពមួយចំនួន ក្រោមឱវាទទីស្តីក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ចាប់ពី**ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣** ដល់**ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣**។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** លោក លោកស្រី ផ្តល់កិច្ចសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម** លោកជំទាវ លោក លោកស្រី ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក "ដើម្បីជ្រាបព័ត៌មាន និងសហការ"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធទី៤៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកំពង់ស្ពឺ
មន្ទីរអប់រំយុវជន និងកីឡា

## កំណត់បង្ហាញ

**គោរពជូន:** [illegible]

**កម្មវត្ថុ:** [illegible]

**លិខិតយោង:** [illegible]

**ខ្លឹមសារ:** [illegible]

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
កំពង់ស្ពឺ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៣

**បញ្ជាក់/ផ្សេងៗ**

**មន្ត្រីជំនាញ**

[illegible]

| យោបល់របស់ប្រធានការិយាល័យរដ្ឋបាល | យោបល់របស់ប្រធានការិយាល័យជំនាញ |
|---|---|
| [illegible] | [illegible] |
| le 21.07.2023 | 21/7/2023 |
| **យោបល់របស់ប្រធានមន្ទីរ** | **យោបល់របស់អនុប្រធានមន្ទីរ** |
| [illegible] | |
| 21/7/23 | |
| [illegible] | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សំណើសុំចុះកម្មសិក្សាស្រាវជ្រាវ**

ខ្ញុំបាទឈ្មោះ **សឹម ភក្តី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលកំពុងទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ។

**សូមគោរពជូន**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ**

កម្មវត្ថុ៖ សំណើអនុញ្ញាតចុះកម្មសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបទបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ។

យោង៖ - ប្រកាសលេខ ១០៥៨ អយក.ប្រកចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។

- បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- លិខិតលេខ ២៨៨៩ អយក. វជអ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការប្រឡងជ្រើសរើសនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- យោងលិខិតលេខ ៤០៨២ អយក. វជអ ដែលអនុញ្ញាតឱ្យនិស្សិតសរសេរនិក្ខេបបទស្រាវជ្រាវ និងចុះប្រមូលទិន្នន័យចាប់ពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

